ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ប្រវត្តិវិទ្យា

(សម័យអាណាព្យាបាលបារាំង-ព្រះរាជាណាចក្រទី២)

សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ
សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២
២០១៧

facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឯកសារសង្ខេបនេះរៀបរៀងដោយ៖** ឯកឧត្តមបណ្ឌិតសភាចារ្យស៊ន សំណាង, លោក មាស ភិរុណ, លោកស្រីបណ្ឌិត យួន វិច្ឆិកា និងលោកបណ្ឌិត ឌី ខាំបូលី

**ត្រួតពិនិត្យ និងកែលម្អដោយ៖** ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន,
ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន, លោកជំទាវ ទន់ សាអ៊ីម, ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងសមាជិកអនុគណៈកម្មការមុខវិជ្ជាប្រវត្តិវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡាដែលមានសមាសភាពដូចតទៅ៖ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន, ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង, លោកស្រីបណ្ឌិត យួន វិច្ឆិកា, លោកបណ្ឌិត វង់ សុធារ៉ា, លោកបណ្ឌិត ឌី ខាំបូលី, លោក សំបូរ មាណ្ណារ៉ា, លោក មួង សុផាត, លោក មាស ភិរុណ, លោក ចេង ហុង, លោក ស៊ីវ ធួន, លោកបណ្ឌិត តឹក ម៉េង, លោក អ៊ីវ សៅសុខា, លោក ណុប សុខា, លោក ប៉ូ សុខា, លោកស្រី សុន វណ្ណា, កញ្ញា ហ៊ា ស៊ីរី, លោក ឈឹម ឌីណា, លោកស្រី ជា កល្យាណ, លោក ទី សុផល និង លោក លី រមនី

**វាយអត្ថបទដោយ៖** និស្សិតដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
កញ្ញា ស៊ាម រីណា, កញ្ញា វន វន្នី, កញ្ញា អួម បូផាន់ណា, កញ្ញា សុខ គឹមសី, កញ្ញា សួន សុវណ្ណ, លោក សុង ភក្រ្តា, លោក កែវ សីហា, លោក មៀវ សារ៉េត, លោក គៀវ ម៉េងគ័ង, លោក រឿន វណ្ណដេត និងលោក សេង សុវណ្ណរិទ្ធិ

**រៀបចំទំព័រដោយ៖** លោកស្រីបណ្ឌិត យួន វិច្ឆិកា

ភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧

រក្សាសិទ្ធិគ្រប់យ៉ាងដោយអនុគណៈកម្មការមុខវិជ្ជាប្រវត្តិវិទ្យា នៃក្រសួងអប់រំ យុវជន និងកីឡា

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អារម្ភកថា

ប្រវត្តិសាស្ត្រគឺជាផ្នែកមួយនៃអត្តសញ្ញាណ និងមោទនភាពនៃប្រជាជាតិមួយ ដែលប្រជាជននៃប្រជាជាតិនោះមានកាតព្វកិច្ចសិក្សា ស្វែងយល់ វិភាគ វាយតម្លៃ និងទាញយកបទពិសោធន៍ពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួន ទោះបីជាប្រវត្តិសាស្ត្រមួយចំនួនមានលក្ខណៈរន្ធត់ និងប្រកបដោយភាពអាម៉ាស់ ដូចជាអំពើប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ។ ការទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រ ការចងចាំ និងការចង់ដឹងចង់ឮពីប្រវត្តិសាស្ត្រគឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ និងការកសាងសន្តិភាពជានិរន្តរ៍ ជាពិសេសសម្រាប់ប្រទេសដែលទើបរួចផុតពីជម្លោះដូចជាប្រទេសកម្ពុជា។ ចំណេះដឹងប្រវត្តិសាស្ត្រមានឥទ្ធិពលទៅលើឥរិយាបថផ្លូវចិត្ត និងការប្រព្រឹត្តរបស់ប្រជាជននាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។ កង្វះខាតចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ការយល់ខុស និងការបកស្រាយដោយគ្មានមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវទាក់ទងនឹងប្រវត្តិសាស្ត្រអាចបង្កជាជម្លោះនៅក្នុងប្រទេសមួយទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។

បេសកកម្មនៃការសិក្សាប្រវត្តិសាស្ត្ររបស់សិស្សានុសិស្ស គឺដើម្បីយល់ដឹងឱ្យបានច្បាស់ពីខ្លួនឯង ពិចារណាអំពីផលប៉ះពាល់និងផលវិបាកនៃប្រវត្តិសាស្ត្រ និងប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងការទទួលខុសត្រូវនៅក្នុងសង្គម។ ចំណេះដឹងប្រវត្តិសាស្ត្រប្រកបដោយការត្រិះរិះពិចារណា និងការទទួលខុសត្រូវ នឹងប្រែក្លាយសិស្សឱ្យទៅជាពលរដ្ឋសកម្ម ប្រកបដោយសមត្ថភាព និងមនសិការ។ អតីតកាលជាប្រទីបបំភ្លឺបច្ចុប្បន្នកាលនិងបង្ហាញផ្លូវទៅកាន់អនាគតកាល និងមានទំនាក់ទំនងរវាងគ្នា ដែលមិនអាចកាត់ផ្ដាច់បាន។ បើអ្នកដឹងអតីតកាលកាន់តែច្រើន អ្នករៀបចំអនាគតកាលបានកាន់តែល្អ។ ប្រជាជាតិមួយដែលគ្មានចំណេះដឹងអំពីអតីតកាល គឺគ្មានអត្ត-សញ្ញាណ និងវង្វេងក្នុងសមុទ្រគ្មានកោះត្រើយឡើយ។ ពលរដ្ឋដែលស្គាល់ច្បាស់អំពីអត្តសញ្ញាណជាតិរបស់ខ្លួន មានសេចក្ដីស្រឡាញ់ជាតិ និងខិតខំកសាងនិងការពារជាតិ ដោយមនសិការ។

សៀវភៅប្រវត្តិវិទ្យាសម្រាប់ថ្នាក់ទី១២ ត្រូវបានបែងចែកជា៣ជំពូក និង២២មេរៀន ដែលនៅក្នុងនោះ ប្រវត្តិសាស្ត្រប្រទេសកម្ពុជាមាន៥មេរៀន ចាប់ពីសម័យអាណាព្យាបាលបារាំង រហូតដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ ដើម្បីឱ្យការសិក្សាប្រវត្តិសាស្ត្រខ្មែរគ្រប់ដណ្ដប់មកដល់សម័យថ្មីបំផុតនោះ អនុគណៈកម្មការមុខវិជ្ជាប្រវត្តិវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡាបានរៀបរៀងសេចក្ដីសង្ខេបក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២បន្ថែមទៀត។

សេចក្ដីសង្ខេបនៃមេរៀនប្រវត្តិសាស្ត្រខ្មែរសម្រាប់ថ្នាក់ទី១២នេះ គ្រាន់តែជាឯកសារជំនួយដើម្បីសម្រួលដល់សិស្សក្នុងការយល់ និងវិភាគព្រឹត្តិការណ៍សំខាន់ៗ ចំណុចចម្រូងចម្រាសនៅក្នុងប្រវត្តិសាស្ត្រខ្មែរ និងជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវបន្ថែមតែប៉ុណ្ណោះ។ ឯកសារនេះពុំមែនជាឯកសារពេញលេញសម្រាប់កម្មវិធីសិក្សាថ្នាក់ទី១២ទាំងមូលនោះទេ។

អនុគណៈកម្មការមុខវិជ្ជាប្រវត្តិវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡា

facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# មាតិកា

**សេចក្ដីផ្ដើមនៃប្រវត្តិវិទ្យា** .......... ១
**ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា** .......... ៣
មេរៀនទី១ ៖ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) .......... ៥
មេរៀនទី២ ៖ របបសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០) .......... ២៥
មេរៀនទី៣ ៖ សាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) .......... ៣៣
មេរៀនទី៤ ៖ កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) .......... ៣៩
មេរៀនទី៥ ៖ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣) .......... ៤៩
មេរៀនទី៦ ៖ ព្រះរាជាណាចក្រកម្ពុជា«ទី២»(១៩៩៣-បច្ចុប្បន្ន) .......... ៥៩
**សេចក្ដីថ្លែងអំណរគុណ** .......... ៦៥

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# សេចក្តីផ្តើមនៃប្រវត្តិវិទ្យា

## I.និយមន័យ

**ប្រវត្តិសាស្ត្រ**គឺជា៖

- កម្រងហេតុការណ៍ និងព្រឹត្តិការណ៍[1]អតីតកាលរបស់មនុស្សជាតិ
- ចំណេះដឹងអំពីអតីតកាលនៃមនុស្សជាតិ និងសង្គមមនុស្ស។

**ប្រវត្តិវិទ្យា**គឺជា៖

- ការសិក្សាអំពីហេតុការណ៍ ព្រឹត្តិការណ៍ បទពិសោធន៍អតីតកាលរបស់មនុស្សជាតិដោយពឹងផ្អែកលើកំណត់ត្រានិងសក្ខីកម្ម[2] សម្រាប់សហសម័យ
- មុខវិជ្ជាដែលសិក្សាអំពីអតីតកាលនៃមនុស្សជាតិ និងសង្គមមនុស្សដែលប្រវត្តិវិទូព្យាយាមកសាងឡើងវិញ និងបកស្រាយឡើងវិញដោយពឹងផ្អែកលើកំណត់ត្រាប្រវត្តិសាស្ត្រនិងសក្ខីកម្មសម្រាប់សហសម័យ។

## II.សារប្រយោជន៍ និងគុណតម្លៃនៃប្រវត្តិវិទ្យា

ប្រវត្តិវិទ្យាផ្តល់នូវសារប្រយោជន៍ និងគុណតម្លៃយ៉ាងច្រើនដូចជា៖

### តម្លៃអប់រំ

- ផ្តល់ចំណេះដឹងដល់អ្នកសិក្សាឱ្យប្រកាន់យកគំរូល្អ៖ បទពិសោធន៍អតីតកាលដែលមានភាពប្រទាក់ក្រឡាគ្នាអាចធ្វើឱ្យអ្នកអានជក់ចិត្ត និងអាចយកទៅនិទានប្រាប់ដល់មិត្តភក្តិកូនចៅជំនាន់ក្រោយ ដើម្បីប្រកាន់យកគំរូល្អ និងជៀសវាងគំរូអាក្រក់
- ផ្តល់ចំណេះដឹងដល់អ្នកសិក្សាឱ្យមានឧត្តមគតិជាតិនិយម ស្នេហាជាតិ និងឆន្ទៈចូលរួមការពារជាតិ មាតុភូមិ៖ ប្រវត្តិដែលគេយកមកបង្រៀន មានបំណងផ្តល់នូវការអប់រំ និងបណ្តុះឧត្តមគតិដល់អ្នកស្តាប់អំពីបញ្ហាអ្វីមួយ...។

---

* **ប្រវត្តិ**គឺជាកម្រងព្រឹត្តិការណ៍ ហេតុការណ៍ និងដំណាក់កាល ដែលកំណត់នូវការវិវត្តនៃមនុស្សមួយក្រុម តំបន់ណាមួយ ឬទីក្រុងណាមួយ។

[1]ហេតុការណ៍ គឺអ្វីដែលពិត ជាក់ស្តែង មិនអាចប្រែកែបាន(មិនមែនជាពាក្យចចាមអារាមទេ)។
ព្រឹត្តិការណ៍ គឺជាហេតុការណ៍ដែលសំខាន់ ដូចជាព្រឹត្តិការណ៍ជាតិ ព្រឹត្តិការណ៍អន្តរជាតិជាដើម។

[2]ភស្តុតាងផ្ទាល់មាត់(Oral evidence) ពីអ្នកដែលដឹងឮព្រឹត្តិការណ៍។



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia www.moeys.gov.kh

- ឧទាហរណ៍ ៖ ប្រវត្តិអ្នកតាក្រហមក ឬតេជោមាសបង្ហាញពីឧត្តមគតិបម្រើជាតិ អាចារ្យ ហែម ចៀវ...គឺឧត្តមគតិជាតិនិយម និងព្រះរាជបូជនីយកិច្ចនៃព្រះបាទ នរោត្តម សីហនុ គឺឧត្តមគតិឯករាជ្យជាតិ ជាដើម។

### តម្លៃជាវប្បធម៌

- ផ្ដល់ចំណេះដឹងដល់អ្នកសិក្សាឱ្យស្គាល់ពីអត្តសញ្ញាណអរិយធម៌ជាតិ និងអន្តរជាតិ
- បណ្ដុះស្មារតីស្នេហាបេតិកភណ្ឌជាតិ និងអន្តរជាតិ
- បណ្ដុះស្មារតីទទួលខុសត្រូវចំពោះរាល់ការប្រព្រឹត្តរបស់ខ្លួន
- បង្កើនការយល់ដឹងពីអតីតកាលដើម្បីរៀបចំអនាគតកាលឱ្យកាន់តែប្រសើរឡើង និងជៀសវាងកំហុសច្រំដែល។

### តម្លៃជាសីលធម៌

- បណ្ដុះមនោសញ្ចេតនាសាមគ្គីជាតិ-អន្តរជាតិ
- បង្កើតទំនាក់ទំនងល្អជាសកល មិនរើសអើងពូជសាសន៍
- បណ្ដុះស្មារតីកតញ្ញូកតវេទី កោតសរសើរនិងយកគំរូល្អតាមបុព្វបុរសដើម្បីជានានិរន្តរភាព និងសុខដុមភាពនៃប្រជាជាតិរបស់ខ្លួន
- បណ្ដុះគំនិតត្រិះរិះពីចំណុចខុសឆ្គង និងខ្វះខាតរបស់បុព្វបុរស ដើម្បីពិចារណារកផ្លូវវិជ្ជមានសម្រាប់ជាតិ និងក្លាយជាពលរដ្ឋល្អប្រកបដោយការទទួលខុសត្រូវ

ដូច្នេះ ការសិក្សាប្រវត្តិវិទ្យាមានសារៈសំខាន់ណាស់សម្រាប់ប្រជាជាតិនីមួយៗ។

## III.លក្ខណៈវិនិច្ឆ័យនៃប្រវត្តិសាស្ត្រ

ប្រវត្តិសាស្ត្រជាចំណេះដឹង និងមិនមែនជាគម្ពីរដែលមិនអាចកែប្រែបាននោះទេ។ ប្រវត្តិវិទូចងក្រងអត្ថបទប្រវត្តិសាស្ត្រតាមរយៈការវិភាគទៅលើព័ត៌មាន និងប្រភពឯកសារដែលរកឃើញ។ ដូច្នេះប្រវត្តិសាស្ត្រអាចមានការផ្លាស់ប្ដូរនៅពេលដែលគេចង់បានលទ្ធផលអ្វីមួយ ឬនៅពេលគេរកឃើញនូវសំណាកឯកសារ ឬភស្តុតាងជាក់លាក់ ដែលផ្ដល់ព័ត៌មានបន្ថែមផ្សេងទៀត ឬខុសពីមុន។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា

ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងអស់រយៈពេល៩០ឆ្នាំ(១៨៦៣-១៩៥៣)។ ក្រោយសម័យអាណាព្យាបាល កម្ពុជាបានឆ្លងកាត់សម័យ និងរបបជាច្រើនដូចជា ៖

- សង្គមរាស្ត្រនិយម(ចុងព្រះរាជាណាចក្រកម្ពុជា[3]«ទី១») ៖១៩៥៥-១៩៧០
- សាធារណរដ្ឋខ្មែរ ៖១៩៧០-១៩៧៥
- កម្ពុជាប្រជាធិបតេយ្យ ៖១៩៧៥-១៩៧៩
- សាធារណរដ្ឋប្រជាមានិតកម្ពុជា ៖១៩៧៩-១៩៨៩
- រដ្ឋកម្ពុជា ៖១៩៨៩-១៩៩១
- អន្តរកាល(អ៊ុនតាក់ UNTACនិងឧត្តមក្រុមប្រឹក្សាជាតិ SNC) ៖១៩៩១-១៩៩៣
- ព្រះរាជាណាចក្រកម្ពុជា«ទី២» ៖១៩៩៣-បច្ចុប្បន្ន

សម្តេច នរោត្តម សីហនុបានទាមទារឯករាជ្យពីបារាំងដោយជោគជ័យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣។ បន្ទាប់មក នៅឆ្នាំ១៩៥៥ ព្រះអង្គបានបង្កើតអង្គការនយោបាយមួយមានឈ្មោះថា«សង្គមរាស្ត្រនិយម» និងបានកាន់អំណាចពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០។

នៅឆ្នាំ១៩៧០ ដោយកម្ពុជារងឥទ្ធិពលសង្គ្រាមត្រជាក់ សង្គ្រាមបានផ្ទុះឡើងនៅក្នុងប្រទេស និងបញ្ចប់នៅឆ្នាំ១៩៧៥ ហើយរបបកម្ពុជាប្រជាធិបតេយ្យដែលមានការសម្លាប់មនុស្សអស់ជាងពីរលាននាក់នោះបានចូលមកបន្តរហូតដល់ដើមឆ្នាំ១៩៧៩។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាត្រូវបានរំដោះឱ្យរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយផ្តើមកសាងប្រទេសឡើងវិញ ដោយបង្កើតឡើងនូវរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ប៉ុន្តែសង្គ្រាមក្នុងស្រុកនៅតែបន្ត។

ចាប់ពីឆ្នាំ១៩៨៧ ដើម្បីសន្តិភាព សម្តេច នរោត្តម សីហនុ និងលោក ហ៊ុន សែន បានរកឃើញមាគ៌ាបញ្ចប់សង្គ្រាមតាមកិច្ចចរចារវាងភាគីទំនាស់ និងធ្វើការបង្រួបបង្រួមជាតិខ្មែរឡើងវិញ។ កិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ បានបើកផ្លូវមកកាន់ការបោះឆ្នោតឆ្នាំ១៩៩៣ ការបង្កើតរបបប្រជាធិបតេយ្យសេរីពហុបក្ស និងព្រះរាជាណាចក្រទី២ ព្រមទាំងការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ ក្នុងសម័យក្រោយសង្គ្រាម។

---

[3]«រាជាណាចក្រទី១» គឺរាប់ចាប់ពីសម័យនគរគោកធ្លក ពីសតវត្សរ៍ទី៣មុនគ.ស. មកដល់ឆ្នាំ១៩៧០។ មុនរដ្ឋធម្មនុញ្ញដំបូងរបស់កម្ពុជាឆ្នាំ១៩៤៧ និងក្នុងសម័យបារាំង គេប្រើពាក្យ «ក្រុងកម្ពុជាធិបតី» និងជាភាសាបារាំង«Royaume du Cambodge»សម្រាប់ហៅប្រទេសកម្ពុជា។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**មេរៀនទី១**

# ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង[4]
# (១៨៦៣-១៩៥៣)

សម័យអាណាព្យាបាលបារាំងមានព្រះរាជាខ្មែរសោយរាជ្យ៤អង្គគឺ៖
- ព្រះបាទ នរោត្តម ១៨៦០-១៩០៤
- ព្រះបាទ ស៊ីសុវត្ថិ ១៩០៤-១៩២៧
- ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ១៩២៧-១៩៤១
- ព្រះបាទ នរោត្តម សីហនុ ១៩៤១-១៩៥៥«លើកទី១»។

## I . ការស្វែងរកកិច្ចការពារពីបារាំង (១៨៥៣-១៨៦០)

### ១. ការធ្វើទំនាក់ទំនងរបស់ព្រះបាទអង្គដួង[5]ជាមួយបារាំង

**មូលហេតុ**

- ព្រះបាទអង្គដួងមានការព្រួយបារម្ភចំពោះការប៉ុនប៉ងបែងចែកទឹកដីកម្ពុជាពីសំណាក់សៀម និងអណ្ណាម[6] ដោយយកទន្លេមេគង្គជាព្រំប្រទល់នៃប្រទេសទាំងពីរ ដែលនឹងអាចធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី និងឈ្មោះពីផែនទីពិភពលោក
- ដើម្បីបញ្ចៀសប្រទេសកម្ពុជាឱ្យរួចផុតពីមហិច្ឆតារបស់សៀម និងអណ្ណាម ដំណោះស្រាយតែមួយគត់នោះ គឺត្រូវតែមានមហាអំណាចណាមួយជាបង្អែកដើម្បីការពារកម្ពុជា ពោលគឺបារាំង។

**ទំនាក់ទំនង និងលទ្ធផល**

ព្រះបាទអង្គដួងបានផ្ញើព្រះរាជសារទៅថ្វាយអធិរាជណាប៉ូលេអុងទី៣ នៃប្រទេសបារាំង ចំនួន២លើក គឺ ៖

- លើកទី១នៅឆ្នាំ១៨៥៣៖ នៅក្នុងព្រះរាជសារនេះ ព្រះបាទអង្គដួងចង់ស្ថាបនាសម្ពន្ធភាពជាមួយបារាំង។ ព្រះរាជសារនេះមានខ្លឹមសារថា៖ «ពួកបេសកបព្វជិតបារាំងបានប្រាប់ឱ្យយើងដឹងថាអធិរាជបារាំងមានចិត្តសប្បុរសចំពោះគ្រប់ប្រជាជាតិ។ ព្រះអង្គជួយការពារប្រជាជាតិទាំងនោះ ដើម្បីជានាស្ថិរភាព និងសុខុមាលភាពដោយមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនម្ចាស់ស្រុក និងថាអធិរាជបារាំងល្អ និងពុំមានការប៉ុនប៉ងដូចព្រះមហាក្សត្រនានានៃទ្វីបអឺរ៉ុប ដែលគិតតែជិះជាន់

---

[4]ពាក្យផ្លូវការដែលគេប្រើនៅសម័យនោះគឺ«អាណាព្យាបាល» មិនមែន«អាណានិគម»។

[5]តាមរាជពង្សាវតារ ត្រូវសរសេរ«អង្គដួង» មិនមែន«អង្គឌួង»ទេ។

[6]ពាក្យផ្លូវការដែលគេប្រើសម្រាប់សម្គាល់វៀតណាម ដែលចិនហៅថា «អានណាម»។



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសដទៃក្រៅពីប្រទេសរបស់ខ្លួន។ ដោយហេតុនេះ យើងមានសេចក្តីរីករាយនឹងចងសម្ពន្ធភាពមួយរឹងមាំ ជាមួយព្រះចៅអធិរាជដែលនឹងធ្វើឱ្យប្រទេសរបស់យើងធំ និងសម្បូណ៌ ដើម្បីសេចក្តីរុងរឿងរបស់ប្រទេសយើង»[7]។

- លើកទី២នៅឆ្នាំ១៨៥៦ ៖ ព្រះរាជសារនេះ មានខ្លឹមសារជាអាទិ៍ថា៖«ចាប់ពីឆ្នាំ១៨៤៦ ស្តេចនៅកូសាំងស៊ីនបានប្រកាសថា បណ្តាខេត្តដែលគេយកបានពីកម្ពុជានោះ មិនត្រូវស្តាប់បង្គាប់ខ្ញុំ និងមិនត្រូវបង់សួយសាអាករមកឱ្យខ្ញុំទៀតទេ។ លើសពីនេះ គេបានរាំងមិនឱ្យធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសខ្ញុំ និងនៅតាមកំពង់ផែនានា។ នេះហើយជាស្ថានភាពជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា។ សូមព្រះអង្គទទួលស្គាល់ខេត្តទាំងនោះ ដែលមានឈ្មោះដូចតទៅ៖ ខេត្តដូនណៃ[8] ដែលបានបាត់ជាង២០០ឆ្នាំមកហើយ ប៉ុន្តែខេត្តជាច្រើនទើបបានបាត់ពេលថ្មីៗនេះគឺ៖ ខេត្តព្រៃនគរ លង់ហោ ផ្សារដែក មេសរ ព្រះត្រពាំង អុងម៉ ក្រមួនស ទឹកខ្មៅ ពាម ឬហាទៀង កោះត្រល់ និងកោះត្រឡាច។ ប្រសិនបើ ដោយចៃដន្យ ពួកអណ្ណាមប្រគល់ខេត្តណាមួយថ្វាយព្រះអង្គ សូមព្រះអង្គកុំទទួលពីព្រោះគឺជាខេត្តរបស់កម្ពុជាទេ។ សូមព្រះអង្គមេត្តាករុណាដល់ខ្ញុំ និងប្រជាជនខ្ញុំផង ដើម្បីបញ្ចប់នូវការបាត់បង់នេះ»[9]។

លោកសាល ដឺ ម៉ុងទីញី(Charles de Montigny)អ្នកការទូតបារាំងបានមកដល់កំពតនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៨៥៦ ដោយមានបំណងចុះហត្ថលេខាលើអនុសញ្ញាពាណិជ្ជកម្ម និងសាសនា ជាមួយព្រះបាទអង្គដួង។ នៅទីនោះ លោកបានតាក់តែងអត្ថបទអនុសញ្ញានេះ ដែលចុះកាលបរិច្ឆេទថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៥៦ ហើយបានចុះហត្ថលេខា មុននឹងបន្តដំណើរទៅកាន់អណ្ណាម និងផ្ញើមកថ្វាយព្រះបាទអង្គដួង នៅរាជវាំងឧដុង្គ។ ព្រះអង្គមិនបានឡាយព្រះហស្តលេខាលើអនុសញ្ញានេះទេ ដោយសារមានការគាបសង្កត់ពីសៀម។ ដូច្នេះ ព្រះរាជបំណងចង់ស្ថាបនាសម្ពន្ធភាពជាមួយបារាំងនៅពេលនោះត្រូវទទួលបរាជ័យ។

## ២. វត្តមានបារាំងនៅប្រទេសអណ្ណាម និងការមើលឃើញពីអត្ថប្រយោជន៍របស់កម្ពុជា

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ ទ័ពបារាំង និងអេស្ប៉ាញបានវាយចូលក្រុងដាណាង ដើម្បីស្រោចស្រង់ជីវិតពួកអ្នកផ្សព្វផ្សាយសាសនាកាតូលិក ដែលសេសសល់ពីការសម្លាប់របស់ស្តេចអណ្ណាមឈ្មោះ ធូ ឌឹក (Tu Duc)។

---

[7]ប្រែសម្រួលពីភាសាបារាំងដោយឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង ពីព្រះរាជសាររបស់ព្រះបាទអង្គដួង៖ Lettre de S.M. Ang Duong à l’Empereur Napoléon III, in Norodom Sihanouk, La Monarchie cambodgienne et la croisade royale pour l’indépendance,Ministère de l'Education Nationale, Direction des Services Péagogiques, (sans date de publication), p. 34.

[8]គឺតំបន់វាលប្រើស( សតវត្សរ៍ទី១៧ )តាមត្រាំងឆាតប៊ុតុ,កម្ពុជាក្រោមអំណាចគ្មានខ្មែរក្រោម,ការផ្សាយរបស់ឥន្រ្ទទេវី, ឆ្នាំ២០០៥, ទំព័រ៤១។

[9]ប្រែសម្រួលពីភាសាបារាំងដោយអនុគណៈកម្មការប្រវត្តិវិទ្យាពីនិក្ខេបបទKhin Sok, Le Cambodge entre le Siam et le Vietnam, (1775 à 1860), EFEO, 1991, p. 268.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៨៥៩ កងទ័ពបារាំងបានចូលកាន់កាប់ក្រុងព្រៃនគរ និងតំបន់ជិតខាង។ បារាំងបានធ្វើដំណើរឡើងតាមដងទន្លេមេគង្គ ក្នុងបំណងចូលទៅកាន់ប្រទេសចិនប៉ែកខាងត្បូង ប៉ុន្តែបេសកកម្មនេះត្រូវបរាជ័យ ដោយសារទន្លេមេគង្គមានឧបសគ្គច្រើន។ ក្នុងដំណើរនេះបារាំងបានយល់ថា កម្ពុជាជាប្រទេស ៖

- សម្បូរទៅដោយទន្លេ ដែលជាផ្លូវគមនាគមន៍យ៉ាងសំខាន់សម្រាប់ដឹកជញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារអឺរ៉ុប
- មានផ្ទៃដីកសិកម្មច្រើន មានប្រជាជនតិច អាចបង្កើតជាដីដាំដំណាំកសិកម្មបានផលច្រើន
- សម្បូរដោយព្រៃភ្នំប្រកបដោយឈើដែលមានគុណភាពខ្ពស់
- សម្បូរទៅដោយរ៉ែនៅក្រោមដី ដែលធ្វើឱ្យបារាំងប៉ុនប៉ងយកទៅបម្រើវិស័យឧស្សាហកម្មជាតិខ្លួន។

## II. ដំណាក់កាលស្ថាបនាគ្រឹះនៃរបបអាណាព្យាបាល(១៨៦៣-១៨៩៧)

### ១. ទំនាក់ទំនងរបស់ព្រះបាទនរោត្តមជាមួយបារាំង

បន្ទាប់ពីព្រះបាទអង្គដួងសោយទិវង្គតនៅឆ្នាំ១៨៦០ ក្រុមប្រឹក្សារាជបល្ល័ង្កបានលើកក្សត្រអង្គវតីឱ្យស្នងរាជ្យបន្ត។ ដោយមានការប្រឆាំងពីអនុជទាំងពីរ(ស៊ីវត្ថា និងសិរីវង្ស)[10] និងការបះបោរដឹកនាំដោយស្នងសួរ ដែលបណ្តាលមកពីប្រពៃណី«រាជាធិបតេយ្យជ្រើសតាំង»[11]នោះ អង្គវតីបាននាំយកគ្រឿងរាជាភិសេក[12]ទៅបាងកកនាខែសីហា ឆ្នាំ១៨៦១។ ក្នុងឱកាសនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិទទួលរ៉ាប់រងកិច្ចការប្រទេស និងរុញច្រានចលនាបះបោររបស់ស៊ីវត្ថាឱ្យថយទៅខាងជើងប្រទេស។ អង្គវតីបានយាងពីបាងកកមកកាន់ក្រុងឧដុង្គវិញនៅខែមីនា ឆ្នាំ១៨៦២។

នៅខែមេសា ឆ្នាំ១៨៦២ ទេសាភិបាលបារាំងប្រចាំនៅកូសាំងស៊ីនឈ្មោះ ដឺឡាក្រង់ឌីយែរ (De La Grandière)បានបញ្ជូននាយទាហានជើងទឹកឈ្មោះ ឌូដាដឺឡាក្រេ(Doudart de Lagrée) មកកាន់ព្រះបរមរាជវាំងឧដុង្គដើម្បីបញ្ចុះបញ្ចូលអង្គវតីឱ្យចងមិត្តភាពជាមួយបារាំងវិញ ប្រសិនបើព្រះអង្គម្ចាស់ចង់គេចចេញពីអំណាចសៀម និងអណ្ណាម។ ក្រោយពីមានសន្ធិសញ្ញាអាណាព្យាបាលនៅឆ្នាំ១៨៦៣ បារាំងបានជួយឱ្យអង្គវតីបានឡើងសោយរាជ្យនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤ ជាស្ថាពរនៅក្រុងឧដុង្គ ដោយមាននាមសម្រាប់រាជ្យថា«ព្រះបាទនរោត្តម»[13]។

---

[10]បើតាមសៀវភៅប្រវត្តិសាស្ត្រកម្ពុជារបស់លោកAdhémard Leclère, Histoire du Cambodge, Paris, 1914, p. 479 សិរីវង្សជាព្រះជាយារបស់ស៊ីវត្ថា ចំណែកព្រះរាជពង្សាវតារព្រះអង្គម្ចាស់នុប្បរតណ៍(នព្វរ័ត្ន) ឆ្នាំ១៨៧៧ ថា សិរីវង្សជាព្រះអនុជ និងជារាជបុត្រា។

[11]តាមប្រពៃណី«រាជាធិបតេយ្យជ្រើសតាំង»(Elective monarchy/ Monarchie élective) ការជ្រើសតាំងព្រះមហាក្សត្រថ្មីឱ្យស្នងរាជ្យ ធ្វើឡើងក្រោយពីពេលចូលទិវង្គតនៃព្រះមហាក្សត្រមុន ដែលជាញឹកញាប់បានបណ្តាលឱ្យមានវិបត្តិរាជបល្ល័ង្ក ដោយសារការប្រកួតប្រជែងគ្នាពីរាជបុត្រាច្រើនអង្គ ដែលសុទ្ធតែជាបេក្ខជនសម្រាប់រាជបល្ល័ង្កនោះ។

[12]ព្រះរាជពង្សាវតារ ប្រទេសកម្ពុជា ទំព័រ១.១១៦។

[13]A. Dauphin-Meunier, Histoire du Cambodge, PUF, 1961, p. 104.



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia www.moeys.gov.kh

## ២. សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ត្រូវបានចុះហត្ថលេខា នៅរាជវាំងឧដុង្គ ដោយចំណុចសំខាន់បំផុតមានចែងថា៖

- ព្រះចៅអធិរាជបារាំងផ្តល់នូវកិច្ចការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា(មាត្រា១)
- ព្រះចៅអធិរាជបារាំង ដែលទទួលស្គាល់អធិបតេយ្យភាពនៃព្រះរាជាកម្ពុជានោះ សន្យាថានឹងជួយរក្សាសណ្តាប់ធ្នាប់ និងភាពស្ងប់ស្ងាត់នៅក្នុងប្រទេស ព្រមទាំងការពារកម្ពុជាទល់នឹងរាល់ការវាយប្រហារពីខាងក្រៅ ជួយកម្ពុជាក្នុងការទារពន្ធដារពាណិជ្ជកម្ម និងផ្តល់នូវភាពងាយស្រួលក្នុងការស្ថាបនាគមនាគមន៍រវាងកម្ពុជា និងដែនសមុទ្រ(មាត្រា១៦)[14]។

## ៣. សន្ធិសញ្ញាបារាំង-សៀមថ្ងៃទី១៥ខែកក្កដាឆ្នាំ១៨៦៧[15]

៤ខែក្រោយចុះសន្ធិសញ្ញាដាក់កម្ពុជានៅក្រោមអាណាព្យាបាលបារាំង ព្រះបាទ នរោត្តមបានចុះសន្ធិសញ្ញាសម្ងាត់មួយជាមួយសៀម។ សៀមដែលធ្លាប់តែមានអំណាចលើកម្ពុជា និងផ្អែកលើសន្ធិសញ្ញាសម្ងាត់នេះមិនទទួលស្គាល់ការដាក់កម្ពុជាជាប្រទេសក្រោមអាណាព្យាបាលបារាំងតាមសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣នោះទេ។ បញ្ហានេះតម្រូវឱ្យបារាំងចរចាជាមួយសៀម។ ជាលទ្ធផលបារាំង និងសៀមបានចុះសន្ធិសញ្ញានៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧ ដែលមានខ្លឹមសារសំខាន់ដូចតទៅ ៖

- ព្រះរាជាសៀមទទួលស្គាល់ជាឱឡារិកនូវរបបអាណាព្យាបាលរបស់ព្រះចៅអធិរាជបារាំងលើប្រទេសកម្ពុជា(មាត្រា១)។
- សន្ធិសញ្ញាដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៨៦៣ រវាងព្រះរាជាណាចក្រសៀម និងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសជាមោឃៈ ដោយរដ្ឋាភិបាលសៀមមិនអាចលើកយកមកសំអាងនៅពេលអនាគត ក្នុងកាលៈទេសៈណាក៏ដោយ(មាត្រា២)។
- ព្រះរាជាសៀមលែងទទួលរាល់សួយសារអាករវត្ថុអនុស្សាវរីយ៍ ឬសញ្ញាផ្សេងៗទៀតនៃភាពជាចំណុះពីសំណាក់ប្រទេសកម្ពុជា សម្រាប់ព្រះអង្គ ឬអ្នកស្នងរាជ្យនានាបន្តពីព្រះអង្គ។ ចំណែកព្រះចៅអធិរាជបារាំងវិញសន្យាថា នឹងមិនដណ្តើមយករាជាណាចក្រនេះ(សៀម) ទៅបញ្ចូលក្នុងទឹកដីជាកម្មសិទ្ធិរបស់ខ្លួន នៅកូសាំងស៊ីនឡើយ(មាត្រា៣)។
- ខេត្តបាត់ដំបង និងអង្គរ(សៀមរាប) នឹងស្ថិតនៅក្នុងរាជាណាចក្រសៀម។ ព្រំប្រទល់នៃខេត្តនេះ និងខេត្តផ្សេងៗទៀតនៅជាប់អាណាខេត្តសៀម ដែលសព្វថ្ងៃនេះ(ឆ្នាំ១៨៦៧)មានការទទួលស្គាល់ទៅវិញទៅមកនោះ នឹងត្រូវកំណត់ដោយបង្គោលព្រំដែន ឬដោយសញ្ញាផ្សេងៗ

---

[14]ប្រែសម្រួលពីអត្ថបទដើមជាភាសាបារាំងដោយអនុគណៈកម្មការប្រវត្តិវិទ្យា។ សន្ធិសញ្ញានេះមានចំនួន១៩មាត្រា។

[15]ប្រែសម្រួលពីអត្ថបទដើមជាភាសាបារាំង ដោយបណ្ឌិតស៊ន សំណាង ៖ Traité franco-siamois du 15 juillet 1867 signé à Paris et promulgué le 14 juillet 1870។



facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទៀត នៅពេលឆាប់ៗ ដោយគណៈកម្មការមួយមានសមាសភាពនាយទាហានសៀម និងខ្មែរ ដោយមានវត្តមាន និងជំនួយពីនាយទាហានបារាំង ដែលចាត់តាំងដោយទេសាភិបាលកូសាំង-ស៊ីន។ នៅពេលណាដែលមានការកំណត់ព្រំដែនរួចហើយនោះ ផែនទីដាក់លាក់មួយនឹងត្រូវគូរដោយនាយទាហានបារាំង(មាត្រា៤)។

## ៤. បារាំងដណ្តើមអំណាចមិនបានជោគជ័យ(អនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤)

បារាំងបានសាកល្បងដណ្តើមអំណាចពីព្រះរាជាកម្ពុជា តាមរយៈអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដែលកើតចេញពីការបង្ខិតបង្ខំ និងនៅក្រោមផ្លាកកំណែទម្រង់[16]។ ទោះជាយ៉ាងនេះក្តី ក៏អនុសញ្ញានេះត្រូវបានចាត់ទុកថា ជាចំណុចចាប់ផ្តើមនៃវិស័យរដ្ឋបាលទំនើបនៅក្នុងប្រទេសកម្ពុជា ហើយមាត្រាសំខាន់ៗមួយចំនួន មានខ្លឹមសារជាអាទិ៍ ដូចខាងក្រោមនេះ៖

ព្រះរាជាកម្ពុជាទទួលយកនូវកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មសម្រាប់អនុវត្តរបបអាណាព្យាបាលរបស់ខ្លួន នៅពេលអនាគត[17](មាត្រា១)។

ព្រះរាជាកម្ពុជានឹងបន្តគ្រប់គ្រងរដ្ឋ និងដឹកនាំរដ្ឋបាល ដូចក្នុងអតីតកាល លើកលែងតែការកម្រិតនានា ដែលមានចែងនៅក្នុងអនុសញ្ញានេះ(មាត្រា២)។

មន្ត្រីខ្មែរនឹងនៅបន្តគ្រប់គ្រងអាណាខេត្តក្រោមការត្រួតពិនិត្យពីអាជ្ញាធរបារាំង លើកលែងតែកិច្ចការណាដែលទាក់ទងនឹងការធ្វើបញ្ជី និងការទារពន្ធដារ គយ វិភាគទានមិនផ្ទាល់ សាធារណការ និងជាទូទៅកិច្ចការដែលតម្រូវឱ្យមានការដឹកនាំតែមួយ ឬការប្រើប្រាស់វិស្វករ ឬ ភ្នាក់ងារអឺរ៉ុប(មាត្រា៣)។

ទាសភាពត្រូវលុបចោល នៅលើផ្ទៃនៃព្រះរាជាណាចក្រទាំងមូល(មាត្រា៨) ។

ទីក្រុងភ្នំពេញនឹងគ្រប់គ្រងដោយគណៈកម្មការក្រុងមួយ ដែលមានសមាសភាព ៖

- អគ្គរ៉េស៊ីដង់ ឬអ្នកតំណាង ជាប្រធាន
- មន្ត្រី ឬ ពាណិជ្ជករបារាំង ៦នាក់ តែងតាំងដោយទេសាភិបាលកូសាំងស៊ីន
- ជនជាតិខ្មែរ៣នាក់
- ជនជាតិអណ្ណាម ១នាក់
- ជនជាតិចិន ២នាក់
- ជនជាតិឥណ្ឌា ១នាក់
- ជនជាតិម៉ាឡេ ១នាក់

---

[16]បារាំងបានបង្ខំឱ្យព្រះបាទ នរោត្តម ឡាយព្រះហស្តលេខាទាំងយប់ ដោយមិនមានការយល់ព្រមអ្វីឡើយ ហើយយកលេសថាធ្វើកំណែទម្រង់។ ដូច្នេះហើយបានជាមានការបះបោរប្រឆាំងបារាំង នៅពេលបន្ទាប់មក។

[17]របបអាណាព្យាបាលជារបបដែលកើតចេញពីកិច្ចព្រមព្រៀង ដែលនៅក្នុងនោះ រដ្ឋពីរធ្វើការបែងចែកអំណាចមិនស្មើគ្នា។ រដ្ឋអាណាព្យាបាលទទួលសិទ្ធិផ្តាច់មុខខាងកិច្ចការបរទេស ចំណែករដ្ឋក្រោមអាណាព្យាបាលនៅបន្តកិច្ចការគ្រប់គ្រងក្រោមការត្រួតពិនិត្យពីអាជ្ញាធរនៃរដ្ឋអាណាព្យាបាល។ រដ្ឋអាណាព្យាបាលដូចជាបារាំង ចំណែករដ្ឋក្រោមអាណាព្យាបាលដូចជាកម្ពុជា។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជនជាតិទាំង៥ខាងលើនេះត្រូវតែងតាំងដោយព្រះរាជាកម្ពុជា តាមបញ្ជីមួយដែលដាក់ជូនទេសាភិបាលកូសាំងស៊ីន ។ ដូច្នេះអ្នកតំណាងជនជាតិខ្មែរមានតែ៣នាក់ក្នុងចំណោម១៥នាក់ ឬ១/៥(មាត្រា១០)។

បារាំងសាកល្បងដណ្តើមអំណាចពីព្រះរាជាខ្មែរ តាមរយៈអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ប៉ុន្តែមិនបានសម្រេច ដោយសារមានការបះបោរប្រឆាំងនៅឆ្នាំ១៨៨៤-១៨៨៧។ បារាំងបានបោះបង់ការប៉ុនប៉ងនេះទៅវិញ ហើយបានសាកល្បងម្តងទៀត ដោយបានជោគជ័យនៅឆ្នាំ១៨៩៧ តាមរយៈព្រះរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧។

## ៥.ការបះបោររបស់ប្រជាជនកម្ពុជាឆ្នាំ១៨៨៤-១៨៨៧

### មូលហេតុ

កិច្ចព្រមព្រៀងឆ្នាំ១៨៨៤ បានធ្វើឱ្យមន្ត្រីខ្មែរ និងជាពិសេសព្រះមហាក្សត្រខ្មែរបាត់បង់សិទ្ធិអំណាចដែលធ្លាប់មានពីមុនមក ទើបនាំឱ្យមានចលនាប្រឆាំងបារាំងពីខែវិច្ឆិកា ឆ្នាំ១៨៨៤ ដល់ខែមករា ឆ្នាំ១៨៨៧[18]។

### ការចរចា និងលទ្ធផល

ដោយខ្លាចចលនាបះបោរក្លាយជាការទាមទារឯករាជ្យ បារាំងបានសម្រេចសម្របសម្រួលជាមួយមន្ត្រីខ្មែរដើម្បីចរចារកដំណោះស្រាយ។ នៅឆ្នាំ១៨៨៦ កិច្ចព្រមព្រៀងទ្វេភាគីបារាំង-ខ្មែរត្រូវបានចុះហត្ថលេខាដែលបាននាំមកនូវ ៖

- បារាំងសន្យាថា នឹងមិនអនុវត្តខ្លឹមសារអនុសញ្ញាឆ្នាំ១៨៨៤
- ព្រះមហាក្សត្រ និងមន្ត្រីរាជការខ្មែរបានទទួលមកវិញនូវតួនាទីក្នុងរដ្ឋបាល
- រ៉េស៊ីដង់ជាន់ខ្ពស់បារាំងបន្តការងារជាទីប្រឹក្សាព្រះមហាក្សត្រខ្មែរដូចមុនដដែល។

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៧ ប្រព័ន្ធរដ្ឋបាលកម្ពុជាបានស្តារឡើងវិញ ឯការប៉ុនប៉ងរបស់បារាំងដើម្បីកែប្រែសង្គម ប្រពៃណី និងទំនៀមទម្លាប់ខ្មែរឱ្យទៅជាបែបផែនផលិតកម្ម(កម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្ម)មូលធននិយម មិនទាន់បានទទួលជោគជ័យទេ។

## ៦.បារាំងដណ្តើមអំណាចបានជោគជ័យ(ព្រះរាជប្រកាស ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧)

ក្រុមប្រឹក្សាមួយ ដែលមានមន្ត្រីធំបំផុត៥នាក់ នឹងមានភារកិច្ចពិនិត្យ និងអនុវត្តច្បាប់ព្រមទាំងធ្វើការសិក្សាលើកំណែទម្រង់ ឬការផ្លាស់ប្តូរ ដែលអាចនឹងកើតមាន។ ក្រុមប្រឹក្សានេះមានឈ្មោះថា កុង្ស៊ីយ៍សេនាបតី(Conseil des Ministres)និងមានរដ្ឋមន្ត្រី៥រូបគឺ អគ្គមហាសេនា យមរាជ ក្រឡាហោម ចក្រី វាំង។ ក្រុមប្រឹក្សានឹងធ្វើការសម្រេច ដោយមិនមានវត្តមានរបស់ព្រះមហាក្សត្រខ្មែរ នៅក្រោមអធិបតីភាព

[18]ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ, ១៩៧៣ ភាគ២ ទំព័រ២៧៥-២៧៨។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់រ៉េស៊ីដង់ជាន់ខ្ពស់ បន្ទាប់មកដាក់ថ្វាយមកព្រះមហាក្សត្រខ្មែរនូវវិធានការនយោបាយ និងរដ្ឋបាលដែលមានប្រយោជន៍ចំពោះប្រទេស(មាត្រា១)។

ព្រះមហាក្សត្រខ្មែរតែងតាំង និងដកតំណែងពួកមន្ត្រី តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ រាល់សេចក្ដីសម្រេច ឬប្រកាស ដែលចេញពីព្រះមហាក្សត្រខ្មែរ បោះត្រារបស់ព្រះមហាក្សត្រខ្មែរត្រូវចុះហត្ថលេខាអម និងប្រកាសឱ្យប្រើដោយរ៉េស៊ីដងជាន់ខ្ពស់(មាត្រា២) ។

មន្ត្រី៥រូបដែលជាជំនួយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ចជំនួសរដ្ឋមន្ត្រីនីមួយៗ នៅពេលអវត្តមាន ឬមានឧបសគ្គ និងជាជំនួយក្នុងរដ្ឋបាលទូទៅ ដោយមានលេខារក្សាឯកសារម្នាក់(មាត្រា៣) ។

ទោះជាយ៉ាងនេះក្ដី ក៏អាជ្ញាធរបារាំងនៅតែបន្តការគ្រប់គ្រងបែបអាណាព្យាបាល ពោលគឺឱ្យមានកិច្ចសហការពីព្រះរាជា និងមន្ត្រីកម្ពុជានៅក្នុង«រដ្ឋបាលមិនផ្ទាល់»(Administration indirecte)។

## ៧.ការស្ដាបនាគ្រឹះខាងវិស័យអប់រំ និងបណ្ដុះបណ្ដាលធនធានមនុស្ស

បំណងរបស់បារាំង និងខ្មែរដែលចង់បើកសាលារៀនមួយហៅថា«សាលារៀនខ្មែរ» នៅក្រុងភ្នំពេញបានចាប់ផ្ដើមពីឆ្នាំ១៨៦៩ ពោលគឺ ៦ឆ្នាំក្រោយសន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ។ បន្ទាប់មក នៅឆ្នាំ១៨៧៣ សាលារៀននោះមានដំណើរការក្រោមការដឹកនាំរបស់លោកហ្វេរីរ៉ូឡិច(FerreyRollex)ដែលជានាយទោនៃកងទ័ពថ្មើរជើងអាណានិគម(Caporal d’Infanterie Coloniale)។

ក្រោយអនុសញ្ញាបារាំង-ខ្មែរ ឆ្នាំ១៨៨៤ មានការបើកសាលារៀននៅតាមខេត្ត។ អាជ្ញាធរបារាំងបានអះអាងថា «ដោយសារកូនសិស្សខ្មែរ ដែលជានិច្ចកាលបង្ហាញសម្បទា និងចំណង់ក្នុងការងារខ្លាំងជាងមិត្តរួមថ្នាក់របស់គេ ជាងពូជសាសន៍ដទៃនោះ ខ្ញុំយល់ថាមានផលប្រយោជន៍នឹងបង្កើតសាលារៀនមួយចំនួនទៀតនៅតាមខេត្ត»។

នៅឆ្នាំ១៨៨៤ លោក សាល ថមសុន(Charles Thomson)ដែលជាទេសាភិបាលកូសាំងស៊ីន បានអនុញ្ញាតឱ្យបើកសាលារៀនមួយនៅខេត្តកំពត។ នៅក្នុងឆ្នាំ១៨៨៥ មានការបើកសាលាបឋមសិក្សានៅក្នុងខេត្តក្រចេះ និងកំពង់ចាម[19] ។

នៅឆ្នាំ១៨៨៥ កូនខ្មែរជាច្រើននាក់ត្រូវបានបញ្ជូនទៅក្រុងប៉ារីស និងខ្លះទៀតឱ្យទៅរៀននៅអនុវិទ្យាល័យអ្នកបកប្រែនៅក្រុងព្រៃនគរ។ នៅសម័យនោះគេបានចាត់ទុកថា«សិស្សខ្មែរវៃឆ្លាតជាងគេបង្អស់ក្នុងការប្រើប្រាស់ភាសាបារាំង» ។

## ៨.ការស្ដាបនាគ្រឹះខាងវិស័យសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម

### ការពង្រឹងកម្លាំងនគរបាលក្រុងភ្នំពេញ១៨៨៤

នៅខែធ្នូ ឆ្នាំ១៨៨៤ ទេសាភិបាលកូសាំងស៊ីនបានផ្ញើលិខិតមួយច្បាប់ជូនដំណឹងមកអ្នកតំណាងអាណាព្យាបាលបារាំងនៅភ្នំពេញថា ដាវមានខ្សែក្រវាត់ចំនួន៣៦ កាំភ្លើងរ៉េវ៉ុលវែរចំនួន៦ដើម និងគ្រាប់

---

[19]Simples notes sur l’histoire de l’enseignement au Cambodge de 1863 à 1890 នៅក្នុងព្រឹត្តិបត្តិប្រចាំខែលេខ១ របស់សមាគមអ្នកប្រវត្តិសាស្ត្រ ខែកញ្ញា ឆ្នាំ២០១៣ ទំព័រ១៦។



facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាំភ្លើងចំនួន៥០០គ្រាប់នឹងត្រូវបញ្ជូនឱ្យមកនគរបាលក្រុងភ្នំពេញ ដោយជាវសេម្រាប់ផ្តល់ឱ្យភ្នាក់ងារម្ចាស់ស្រុក ឬស្រុកអាយ ឯកាំភ្លើងខ្លីសម្រាប់ផ្តល់ឱ្យស្នងការបារាំង។

### ការរៀបចំកំពង់ផែក្រុងភ្នំពេញឆ្នាំ១៨៨៥

ឆ្នាំ១៨៨៥ នាយកំពង់ផែពាណិជ្ជកម្មបានស្នើសុំអ្នកតំណាងអាណាព្យាបាលបារាំងឱ្យមាន«ការរៀបចំនគរបាលកំពង់ផែ» ទីក្រុងភ្នំពេញដើម្បីបង្កើនការត្រួតពិនិត្យលើនាវា។

### កំណើតមន្ទីរពេទ្យព្រះកេតុមាលាឆ្នាំ១៨៨៥

នៅខែសីហា ឆ្នាំ១៨៨៥ មន្ទីរពេទ្យប្រក់ស្លឹកមួយនៅខាងជើងវត្តភ្នំត្រូវបានសាងសង់ឡើងសម្រាប់ព្យាបាលទាហានបារាំងដែលរងរបួសដោយសារចលនាបះបោរប្រឆាំងនឹងបារាំង ហើយក្រោយមកបានក្លាយជាមន្ទីរពេទ្យព្រះកេតុមាលា។ គួរកត់សម្គាល់ថា ចាប់ពីឆ្នាំ១៨៨៥ កងទ័ពបារាំងបានកើនឡើងពី៦០នាក់ទៅដល់១ ២០០នាក់។

សរុបសេចក្តីមក នៅពាក់កណ្តាលទី២នៃសតវត្សរ៍ទី១៩ អ្នករដ្ឋបាលបារាំងបានព្យាយាមគ្រប់គ្រងប្រទេសកម្ពុជា តាមរយៈការខិតខំស្វែងយល់អំពីប្រវត្តិសាស្ត្រ វប្បធម៌ នីតិសាស្ត្រ និងអតីតកាលនៃប្រទេសកម្ពុជា ក្នុងបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងបានទទួលនូវសមានចិត្តពីប្រជាជនកម្ពុជា។ ពួកអ្នករដ្ឋបាល និងនាយទាហានបារាំង បានបំពេញការងារជាអ្នកគ្រប់គ្រងផង និងជាអ្នកស្រាវជ្រាវផង ដូចជាលោកអេដែន អៃមូនីញេ៉ (Etienne Aymonier) លោកហ្សង់ មូរ៉ា(Jean Moura)[20] និងលោកអាដេម៉ា ឡឺគ្លែរ (Adhémard Leclère)[21] ជាដើម។

## III. ដំណាក់កាលអភិវឌ្ឍរបបអាណាព្យាបាល(១៩០០-១៩៤៥)

ចាប់ពីដើមសតវត្សរ៍ទី២០ របបអាណាព្យាបាលបារាំងបានឈានចូលក្នុងដំណាក់កាលនៃការអភិវឌ្ឍ ដោយបានធ្វើកំណែទម្រង់លើស្ថាប័នមួយចំនួនដែលមានស្រាប់ និងបានបង្កើតថ្មីនូវបណ្តាស្ថាប័នគ្រប់គ្រង(ខាងរដ្ឋបាល តុលាការ សន្តិសុខ...) ស្ថាប័នបណ្តុះបណ្តាលបញ្ញាញាណជាតិ(ខាងអប់រំគ្រប់ផ្នែក និងគ្រប់កម្រិត) និងស្ថាប័នវប្បធម៌(សម្រាប់កសាងកិត្យានុភាពជាតិ)។ល។ជាបន្តបន្ទាប់ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេសកម្ពុជានាពាក់កណ្តាលទី១ នៃសតវត្សរ៍ទី២០។

[20] Jean Moura, Le Royaume du Cambodge, 1883 : « Le Cambodge, autrefois riche et puissant empire sous le nom d'empire des Khmers" (Préface). (Moura : Représentant du Protectorat).

[21] Adhémard Leclère, Histoire du Cambodge depuis le 1er siècle de notre ère, 1914.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១. ស្ថាប័នសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

**នគរបាលរដ្ឋបាល និងយុត្តិធម៌(ឆ្នាំ១៩០៣)**

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩០៣ អគ្គទេសាភិបាលឥណ្ឌូចិនបានចេញសេចក្តីប្រកាស ស្តីពីការរៀបចំនគរបាលរដ្ឋបាលនិងយុត្តិធម៌និងនគរបាលក្រុងភ្នំពេញ ។

**នគរបាលត្រួតពិនិត្យផ្លូវទឹក(ឆ្នាំ១៩០៥)**

នគរបាលមួយកងទទួលបន្ទុកត្រួតពិនិត្យផ្លូវទឹកនៅប្រទេសកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈប្រកាសចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩០៥[22]។

**នគរបាលសុខាភិបាលសត្វពាហនៈ(ឆ្នាំ១៩០៨)**

លោកអគ្គទេសាភិបាលឥណ្ឌូចិនចេញបញ្ជាឱ្យលោករ៉េស៊ីដង់ជាន់ខ្ពស់អនុវត្តច្បាប់ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៨៨១ ស្តីពី«នគរបាលសុខភាពសត្វពាហនៈ» ដោយតម្រូវឱ្យសម្លាប់សត្វដែលមានជំងឺឆ្លង និងឱ្យសងតម្លៃ៣/៤នៃតម្លៃសត្វដែលសម្លាប់នោះទៅឱ្យម្ចាស់។

### ២. សារមន្ទីរជាតិ និងការជួសជុលព្រះរាជវាំង

សារមន្ទីរជាតិត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ១៩០៥ នៅក្នុងអគារព្រះបរមរាជវាំងសម្រាប់ព្រះស៊ីសុវត្ថិ។ នៅឆ្នាំ១៩១៤ មានការសម្រេចកសាងសារមន្ទីរជាតិនៅទីតាំងបច្ចុប្បន្ន ហើយពិធីសម្ពោធបានប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩២០ ក្រោមអធិបតីភាពរបស់សម្តេចព្រះ ស៊ីសុវត្ថិ និងមានឈ្មោះតាមអគ្គ-ទេសាភិបាលកូសាំងស៊ីនថា សារមន្ទីរ អាល់ប៊ែរ សារ៉ូ(Musée Albert Sarraut)។

ចាប់ពីឆ្នាំ១៩០៤ នយោបាយរបស់បារាំងគឺជួយលើកតម្កើងកិត្យានុភាព នៃរាជវង្សឡើងវិញ តាមរយៈការជួសជុលអគារមួយចំនួននៅក្នុងព្រះបរមរាជវាំង នៅដើមរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ(១៩០៤-១៩២៧)[23]។

### ៣. ការទទួលបានទឹកដីពីសៀមមកវិញ

ដោយសារកិច្ចសហការបារាំង-ខ្មែរ សៀមបានប្រគល់ទឹកដីមកឱ្យខ្មែរវិញចាប់ពីឆ្នាំ១៨៩០ ចំនួន ៤ ដំណាក់កាល៖

- នៅឆ្នាំ១៨៩០ ៖ តំបន់ខ្ពង់រាប(ខេត្តមណ្ឌលគិរីសព្វថ្ងៃ)
- នៅឆ្នាំ១៨៩៣ ៖ ត្រើយខាងកើតទន្លេមេគង្គ(ខេត្តស្ទឹងត្រែង)

---

[22]Arrêté du 19 septembre 1905 portant création d’une brigade de police chargée de la surveillance des cours d’eaux au Cambodge.

[23] Alain Forest, Le Cambodge et la colonization française, op.cit., p. 78.



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

- នៅឆ្នាំ១៩០៤ ៖ ខេត្តស្ទឹងត្រែង និងទន្លេរពៅ ដែលស្ថិតនៅតាមជួរភ្នំដងរែក និងក្រាត(ត្រាត)[24] ដែលស្ថិតនៅតាមតំបន់ឆ្នេរសមុទ្រ
- នៅឆ្នាំ១៩០៧ ៖ ខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ។

## ៤. កិច្ចអភិរក្សអង្គរ

សាលាបារាំងចុងបូព៌ាប្រទេសរបស់ពួកអ្នកប្រាជ្ញបារាំងចាប់ផ្តើមស្រាវជ្រាវចងក្រង និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ បុរាណវិទ្យា និងវប្បធម៌ខ្មែរ ព្រមទាំងចាប់ផ្តើមនូវកិច្ចអភិរក្សអង្គរចាប់ពីឆ្នាំ១៩០៨ បន្ទាប់ពីបានទទួលខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណនៅឆ្នាំ១៩០៧ពីប្រទេសសៀម។ ចាប់ពីពេលនោះមក កិច្ចការរបស់សាលាបារាំងចុងបូព៌ាប្រទេសមិនសូវបានផ្តោតទៅលើបណ្តាប្រទេសនៅអាស៊ីចុងបូព៌ាទេ ដោយហេតុថា កិច្ចការរបស់ពួកគេបានផ្តោតជាពិសេសលើកិច្ចអភិរក្សតំបន់ប្រាសាទអង្គរ ដែលជាស្ថានីយ៍បុរាណវិទ្យាធំជាងគេលើពិភពលោក។ កិច្ចអភិរក្សអង្គរបានបន្តរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៧០(បន្ទាប់ពីសង្គ្រាមបានផ្ទុះឡើងនៅកម្ពុជា)។

## ៥. កំណែទម្រង់ផ្ទៃក្នុងរបស់បារាំង នៅឆ្នាំ១៩១១

នៅឆ្នាំ១៩១១ រដ្ឋាភិបាលបារាំងបានធ្វើកំណែទម្រង់នៅសហភាពឥណ្ឌូចិន តាមរយៈក្រឹត្យ ចំនួន៤ របស់ប្រធានាធិបតី ដែលបានចែងអំពី៖ ការកំណត់អំណាចរបស់អគ្គទេសាភិបាលឥណ្ឌូចិន, ការកំណត់សមាសភាពនិងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋាភិបាលឥណ្ឌូចិន, ការកំណត់អំណាចរបស់ទេសាភិបាលកូសាំងស៊ីននិងបណ្តារ៉េស៊ីដង់ជាន់ខ្ពស់(នៅកម្ពុជា អណ្ណាម តុងកឹង និងឡាវ) និងការរៀបចំឡើងវិញនូវថវិកាឥណ្ឌូចិន និងថវិកាតាមរដ្ឋនីមួយៗនៃឥណ្ឌូចិន។ នេះជារបត់មួយយ៉ាងធំនៃគោលនយោបាយគ្រប់គ្រងរបស់បារាំងនៅកម្ពុជា ពីព្រោះរាល់ប្រកាសរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់បារាំងនៅកម្ពុជា រហូតដល់ទសវត្សរ៍ឆ្នាំ១៩៤០បានផ្អែកលើក្រឹត្យទាំងនេះ[25]។

## ៦. ដំណើរការអភិវឌ្ឍនៅប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩១១

បន្ទាប់ពីបានធ្វើកំណែទម្រង់ផ្ទៃក្នុងនៅសហភាពឥណ្ឌូចិន បារាំងបានបង្កើតស្ថាប័នបញ្ញាញាណជាតិ និងកិត្យានុភាពជាតិ ដែលជាស្ថាប័នសាធារណៈ សម្រាប់បង្កើនសមត្ថភាពធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់ដូចខាងក្រោមនេះ៖

- ទីចាត់ការដំបូងនៃការអប់រំចំណេះទូទៅត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១១ ដែលជាការចាប់ផ្តើមនូវការអប់រំទៅតាមវិធីសាស្ត្រនិងជាប្រព័ន្ធនៅកម្ពុជា[26]។ មានការអប់រំបីយ៉ាងនៅសម័យនោះគឺ៖

---

[24] ខេត្តត្រាតត្រូវប្រគល់ឱ្យសៀមវិញនៅឆ្នាំ១៩០៧។

[25] Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse d'Histoire, Université Paris 7, 1995, p. 7.

[26] Service local de l'enseignement du Cambodge dirigé par Mr. Henri Russier, Inspecteur de l'Enseignement Primaire, dans Sorn Samnang, op.cit., p. 238, Chapitre II, L'enseignement officiel.



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

- ○ **ការអប់រំផ្លូវការក្នុងសាលាបារាំង-ខ្មែរ៖** អនុវិទ្យាល័យអាណាព្យាបាលដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៩៣ និងក្លាយជាសាលាបឋមសិក្សាជាន់ខ្ពស់នៅឆ្នាំ១៩០៥នោះ បានឡើងជាអនុ-វិទ្យាល័យស៊ីសុវត្ថិនៅឆ្នាំ១៩១១[27] និងបានក្លាយជាវិទ្យាល័យនៅឆ្នាំសិក្សា១៩៣៥-១៩៣៦។ មានគ្រឹះស្ថានឧត្តមសិក្សាពីរនៅឆ្នាំ១៩៤៨ គឺវិទ្យាស្ថានជាតិខាងនីតិសាស្ត្រ នយោបាយ និងសេដ្ឋកិច្ច និងសាលាភូមិន្ទវេជ្ជសាស្ត្រ[28]។
- ○ **ការអប់រំតាមប្រពៃណីក្នុងសាលាវត្តបែបថ្មី៖** បន្ទាប់ពីមានការបង្កើតសាលាវត្តកែប្រែថ្មីនៅឆ្នាំ១៩០៨នៅខេត្តកំពង់ចាម មានព្រះរាជប្រកាសចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩១១ ដែលតម្រូវឱ្យរៀនភាសាខ្មែរនៅគ្រប់វត្តអារាមទូទាំងប្រទេស។ ឪពុកម្តាយដែលមានកូនប្រុសគ្រប់អាយុ៨ឆ្នាំត្រូវបញ្ជូនកូនឱ្យទៅរៀននៅសាលាវត្ត។ ចាប់ពីឆ្នាំ១៩១២ អ្នកមិនគោរពតាមព្រះរាជប្រកាសនេះត្រូវទទួលការពិន័យ[29]។ សាលាវត្តកែប្រែថ្មីមានជោគជ័យពិតប្រាកដនៅខេត្តកំពត ពីឆ្នាំ១៩២៤ ដល់ឆ្នាំ១៩៣០ និងមានការអភិវឌ្ឍទូទាំងប្រទេសចាប់ពីឆ្នាំ១៩៣១[30]។
- ○ **ការអប់រំបែបសាសនាក្នុងសាលាបាលី៖** ព្រះរាជប្រកាសចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩១៤បានបង្កើតសាលាបាលីនៅភ្នំពេញសម្រាប់បណ្តុះបណ្តាលព្រះសង្ឃខ្មែរនៅក្នុងប្រទេស និងទប់ស្កាត់មិនឱ្យទៅបន្តការសិក្សានៅឯប្រទេសសៀម។ សាលាបាលីនេះបានក្លាយជាសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២ និងប្រែឈ្មោះមកជាពុទ្ធិកវិទ្យាល័យនៅឆ្នាំ១៩៥៥។

- ការរៀបចំកងទ័ពខ្មែរត្រូវបានចាប់ផ្តើមជាពិសេសចាប់ពីសង្គ្រាមលោកលើកទី១[31]
- សាលាសិល្បៈខ្មែរ ឬសាលារចនាត្រូវបានបង្កើតនៅឆ្នាំ១៩១៧ ដើម្បីប្រមែប្រមូលសិល្បករខ្មែរទូទាំងប្រទេសឱ្យមកជួយស្តារវិស័យវប្បធម៌ខ្មែរឡើងវិញ
- សាលាក្រមការសម្រាប់បណ្តុះបណ្តាលមន្ត្រីដែលបានបង្កើតឡើងនៅឆ្នាំ១៩១៤នោះ បានក្លាយជាសាលារដ្ឋបាលតុលាការខ្មែរនៅឆ្នាំ១៩១៧ និងបានក្លាយជាវិទ្យាស្ថានជាតិខាងនីតិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច នៅឆ្នាំ១៩៤៨
- ច្បាប់ស្តីពីការបង្ក្រាបភាពស្រវឹងនៅទីសាធារណៈ ត្រូវប្រកាសឱ្យប្រើដោយប្រកាសរបស់អគ្គទេសាភិបាលចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩១៧[32]

---

27 Sorn Samnang, L’évolution de la société cambodgienne…, op.cit., p. 250.
28 Ibid., p. 258.
29 Ibid, p. 182. (Note : Ordonnance royale du 10 novembre 1911 rendant obligatoire l’enseignement de la langue cambodgienne dans toutes les pagodes du royaume)
30 Sorn Samnang, L’évolution de la société cambodgienne…, op.cit., p. 182.
31 Alain Forest, Le Cambodge et la colonisation française, Histoire d’une colonisation sans heurts (1897-1920), L’Harmattan, 1980, p. 136-139.
គួរបញ្ជាក់ដែរថា ទាហានខ្មែរជាង១ ០០០នាក់ ត្រូវបានរៀបចំសម្រាប់ទៅច្បាំងនៅទ្វីបអឺរ៉ុបក្នុងសង្គ្រាមលោកលើកទី១។
32 Loi sur la répression de l’ivresse publique et sur la police des débits de boissons, Promulguée en Indochine par arrêté du Gouverneur Général du 10 décember 1917.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នគរបាលចរាចរណ៍ និងបទបញ្ញត្តិពីចរាចរណ៍នៅប្រទេសកម្ពុជា សម្រាប់រថយន្តដឹកទំនិញ និងដឹកអ្នកដំណើរត្រូវបានចុះហត្ថលេខានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩១៨[33]
- រាជការឃុំត្រូវបានបង្កើតឡើងតាមព្រះរាជប្រកាសចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩។

## ៧. ដំណើរការអភិវឌ្ឍស្ថាប័នរដ្ឋបាល និងសន្តិសុខចាប់ពីឆ្នាំ១៩២១

### ការរៀបចំវិស័យរដ្ឋបាលឡើងវិញ

នៅថ្ងៃទី១១ខែធ្នូឆ្នាំ១៩២១ វិស័យរដ្ឋបាលត្រូវបានរៀបចំឡើងវិញតាមរយៈព្រះរាជប្រកាសលេខ ១០២ ដោយមានការបង្កើត«ខណ្ឌ» នៅចន្លោះ«ស្រុក» និង«ឃុំ» ពោលគឺរដ្ឋបាលថ្នាក់ខេត្តមានខេត្តស្រុកខណ្ឌឃុំ។ ប៉ុន្តែគេបានលុបខណ្ឌចេញវិញនៅឆ្នាំ១៩៣៤។

### ការរៀបចំនគរបាលចល័តនៅឈូងសមុទ្រ

កិច្ចការរបស់នគរបាលចល័តតាមឈូងសមុទ្រមានដូចជា ការស្វែងរកជនបរទេសដែលគ្មានលិខិតអនុញ្ញាតស្នាក់នៅ នៅតាមសមុទ្រជាដើម[34]។

### ការបង្កើតនិងការរៀបចំកងក្រវែលឃុំឬនគរបាលជនបទ

កងក្រវែលឃុំ និងនគរបាលជនបទនៅកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈព្រះរាជប្រកាសចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ១៩២៥។ កងក្រវែលឃុំស្ថិតនៅក្រោមឱវាទអាជ្ញាធរឃុំ ជាពិសេសមេឃុំ និងក្រោមការត្រួតពិនិត្យជាអចិន្ត្រៃយ៍ពីចៅហ្វាយខណ្ឌ។ នៅឆ្នាំ១៩២៨ កងក្រវែលឃុំក្នុងខេត្តទាំង១៤មានចំនួន៣៦៤នាក់។

ការបង្កើតកងក្រវែលឃុំនេះ គឺជាវិធានការនគរបាលដើម្បីពង្រឹងសន្តិសុខនៅតាមឃុំក្រោយពីមានឧប្បត្តិហេតុសម្លាប់លោករ៉េស៊ីដង់បាដេស(Bardez)ក្នុងខែមេសា ឆ្នាំ១៩២៥នៅឃុំក្រាំងលាវខេត្តកំពង់ឆ្នាំង។

### ការបង្កើតកងក្រវែលខេត្ត ឬនគរបាលខេត្ត

វិបត្តិសេដ្ឋកិច្ចពិភពលោកបានផ្ទុះឡើងនៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩២៩ ហើយបានជះឥទ្ធិពលអវិជ្ជមានដល់ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៣០។ កម្រិតជីវភាពរស់នៅរបស់ប្រជាជនត្រូវបានធ្លាក់ចុះ អសន្តិសុខកើតមានលើផ្ទៃប្រទេសបណ្តាលមកពីការកើនឡើងនៃអំពើចោរកម្ម។

---

Fond de le Résidence supérieure du Cambodge, No. 33798 – 1917.
Article premier : Sera puni d'une amende de 1 à 5 frs inclusivement, quiconque sera trouvé en état d'ivresse manifeste dans les rues, chemins, places, cafés, caberets ou autres lieux publics.

[33]Le 10 décembre 1918 : Règlement sur la circulation au Cambodge des automobiles de charge ou de transport de voyageur en commun (Police de la route, No. 30627).

[34]របាយការណ៍ថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩២៤ស្តីពីដំណើរការបេសកកម្មនៃនគរបាលចល័តនៅឈូងសមុទ្រសៀមដើម្បីស្វែងរកជនជាតិអាស៊ីជាច្រើននាក់ដែលគ្មាន«លិខិតអនុញ្ញាតស្នាក់នៅ » ជាពិសេសជនជាតិចិនហៃណាំនៅក្នុងបណ្តាភូមិតាមឆ្នេរសមុទ្រ។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងទិសដៅ រក្សាសណ្តាប់ធ្នាប់សាធារណៈ ការពារប្រជាពលរដ្ឋនិងទ្រព្យសម្បត្តិ ពិនិត្យលើបទល្មើសនិងបទឧក្រិដ្ឋ តាមរកនិងចាប់ខ្លួនពួកចោរ នាំខ្លួនជនជាប់ចោទនិងអ្នកទោស កងក្រវែលខេត្តត្រូវបានបង្កើតឡើងនៅគ្រប់ខេត្តនៃប្រទេសកម្ពុជាតាមរយៈព្រះរាជប្រកាសចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៣១។

ការបង្កើតកងក្រវែលខេត្តនេះ គឺជាវិធានការនគរបាលថ្មីថ្នាក់ខេត្តមួយទៀតបន្ទាប់ពីការបង្កើតកងក្រវែលឃុំកាលពីឆ្នាំ១៩២៥។

### ការបង្កើតនគរបាលផ្លូវដែកភ្នំពេញ-បាត់ដំបង

នគរបាលផ្លូវដែកភ្នំពេញ និងបាត់ដំបង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣១ ដើម្បីបង្ក្រាបបទល្មើសដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គល និងសណ្តាប់ធ្នាប់សាធារណៈនៅតាមផ្លូវដែក ។

### ការបង្កើតកងនគរបាលទន្លេសាប

កងនេះត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យរបស់រ៉េស៊ីដង់ជាន់ខ្ពស់ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៣៣ និងត្រូវបានកែសម្រួលនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៣៧ ក្នុងគោលបំណងធានានូវការត្រួតពិនិត្យ និងការពារកន្លែងនេសាទនៅបឹងទន្លេសាប។ កងនគរបាលទន្លេសាបមានទីស្នាក់ការនៅក្រគរ(ពោធិសាត់) ដែលបែងចែកជា៥ តំបន់គឺ ក្រគរ(ពោធិសាត់) កំពង់ឆ្នាំង កំពង់ធំ កំពង់ឃ្លាំង(សៀមរាប) និងបាក់ព្រា(បាត់ដំបង)។

### នគរបាលព្រំដែនសៀម

កងកម្លាំងមួយនេះមានតួនាទីត្រួតពិនិត្យ និងរាយការណ៍ពីស្ថានភាពនៅតាមព្រំដែនខ្មែរ-ថៃ។

## ៨. ដំណើរការអភិវឌ្ឍស្ថាប័នវប្បធម៌ចាប់ពីទសវត្សរ៍ឆ្នាំ១៩២០

បារាំងបានសម្ពោធបណ្ណាល័យជាតិនៅឆ្នាំ១៩២៤ និងបណ្ណសារដ្ឋានជាតិនៅឆ្នាំ១៩២៦ ដើម្បីតម្កល់ទុកនូវសៀវភៅ និងឯកសារផ្សេងៗ។ ក្រៅពីនេះ បារាំងក៏បានអភិវឌ្ឍស្ថាប័នសាសនាតាមរយៈកិច្ចការផ្សេងៗដូចជា ៖

### ការបង្កើតពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ១៩៣០

ពុទ្ធសាសនបណ្ឌិត្យជាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាធំជាងគេនៅក្នុងសហភាពឥណ្ឌូចិន និងមានសាខាមួយនៅកូសាំងស៊ីន និងមួយទៀតនៅប្រទេសឡាវ។ នៅកន្លែងនេះក៏មានក្រុមជំនុំព្រះត្រៃបិដក(១៩២៩) និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ(១៩៣៤)ផងដែរ។

### ការពង្រីងអំណាចបារាំង-ខ្មែរទៅកាន់តំបន់ដាច់ស្រយាល

- **តំបន់ឆ្នេរសមុទ្រចាប់ពីក្រោយឆ្នាំ១៩០៤**

នៅឆ្នាំ១៩០៤-១៩០៦ តំបន់ឆ្នេរសមុទ្ររបស់កម្ពុជាមានខេត្តពីរ ដែលគ្រប់គ្រងដោយចៅហ្វាយខេត្តបារាំង គឺខេត្តកំពត និងខេត្តកោះកុង-ក្រាត។ នៅឆ្នាំ១៩៣៣-៣៤ មានព្រះសង្ឃពីរអង្គពីវត្តអង្គសុភី

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រុកកំពង់ត្រាច ខេត្តកំពត ដែលបានស្ម័គ្រចិត្តនិមន្តទៅខេត្តកោះកុង ដើម្បីបង្កើតវត្ត និងបង្រៀនភាសាខ្មែរនៅទីនោះ[35]។

- **ភូមិភាគឦសានចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩២០**

នៅឆ្នាំ១៩២៩ មានការចាប់ផ្ដើមធ្វើផ្លូវលំ(ពីស្នួល) ចូលទៅក្នុងភូមិភាគឦសានឡើងវិញ ដែលហៅថា«ការចូលទៅកាន់តំបន់ខ្ពង់រាប» គឺខេត្តមណ្ឌលគិរីសព្វថ្ងៃនេះ។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៣១ មន្ត្រីនៃដែនប្រតិភូស្នួល(Délégué de Snuol) ឈ្មោះហ្គាទីយ(Gatille)ដែលទទួលភារកិច្ចធ្វើផ្លូវចូលទៅកាន់ខ្ពង់រាប ត្រូវបានសម្លាប់ដោយពួកព្នង។

នៅឆ្នាំ១៩៣៣ មន្ត្រីនៃពុទ្ធសាសនបណ្ឌិត្យ លោកស្រីស៊ូហ្សាន ការប៉ែល(Suzanne Karpeles) និងព្រះភិក្ខុ ហួត តាតដែលជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់បានទៅកាន់តំបន់ខ្ពង់រាប នៅពេលដែលតំបន់នោះមិនទាន់មានសន្តិភាពទាំងស្រុងនៅឡើយ(ដោយសារការប្រឆាំងពីជនជាតិភាគតិច)ដើម្បីរៀបចំកម្មវិធីបង្រៀនភាសាខ្មែរ ដល់ជនជាតិភាគតិចនៅទីនោះ ដោយចាប់ផ្ដើមពីប៉ុស្តិ៍ឡឺ រ៉ូឡង់(Poste Le Rolland)[36]។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៣៤ ព្រះសង្ឃ៨អង្គបាននិមន្តពីភ្នំពេញ ទៅកាន់ប៉ុស្តិ៍ឡឺ រ៉ូឡង់ ដើម្បីរៀបចំសម្ពោធវត្តមួយនៅទីនោះ និងចាប់ផ្ដើមបង្រៀនភាសាខ្មែរ[37]។

ទន្ទឹមនឹងការពង្រឹងអំណាចរបស់បារាំង ចលនាជាតិនិយមខ្មែរក៏បានលេចរូបរាងផងដែរពីដើមទសវត្សរ៍ឆ្នាំ១៩៣០ តាមរយៈ ពុទ្ធសាសនបណ្ឌិត្យ វិទ្យាល័យស៊ីសុវត្ថិ(សមាគមអតីតសិស្សអនុវិទ្យាល័យ) កាសែតនគរវត្ត និងកវីជាតិនិយមក្រមង៉ុយ។

## IV. ដំណាក់កាលចុងក្រោយនៃអាណាព្យាបាល(១៩៤៦-១៩៥៣)

### ១. ឯករាជ្យជាតិលើកទី១ នៅឆ្នាំ១៩៤៥

- នៅរាត្រីថ្ងៃទី៩ ខែមីនាឆ្នាំ១៩៤៥ ជប៉ុនបានធ្វើពលប្រហារ និងចាប់បារាំងឃុំឃាំងទូទាំងឥណ្ឌូចិន
- ថ្ងៃទី១២ ខែមីនា សម្ដេច នរោត្តម សីហនុ បានប្រកាសឯករាជ្យជាតិពីបារាំង ដោយឯករាជ្យនេះមានរយៈពេល៧ខែ ៤ថ្ងៃ ៖
    - ថ្ងៃទី១៨ ខែមីនា សម្ដេច នរោត្តម សីហនុ បានបង្កើតរាជរដ្ឋាភិបាលឯករាជ្យ
    - រាជរដ្ឋាភិបាលនរោត្តម សីហនុ មានរយៈពេល ៤ខែ ២៥ថ្ងៃ(១៨ មីនា-១៣ សីហា ១៩៤៥)
    - រាជរដ្ឋាភិបាល សឺង ង៉ុកថាញ់ មានរយៈពេល ២ខែ ២ថ្ងៃ(១៣ សីហា-១៦តុលា)

---

[35] Sorn Samnang, L’évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse de Doctorat d’Histoire, Université Paris 7, Octobre 1995, p. 229.

[36]នៅតាមផ្លូវទៅកាន់ខ្ពង់រាបមានប៉ុស្តិ៍ដូចជា ប៉ុស្តិ៍ហ្គាទីយ ដែលជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់ និងប៉ុស្តិ៍នានាផ្សេងទៀត ដូចជាប៉ុស្តិ៍ឡឺ រ៉ូឡង់(Poste Le Rolland)និងប៉ុស្តិ៍ម៉ែត្រ(Poste Maître) ជាដើម។

[37]Sorn Samnang, L’évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse de Doctorat d’Histoire, Université Paris 7, Octobre 1995, p. 176.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បារាំងបានវិលមកវិញនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៤៥។

## ២. កិច្ចព្រមព្រៀងបណ្តោះអាសន្នថ្ងៃទី៧ ខែមករា ឆ្នាំ១៩៤៦(Modus Vivendi)

តាមរយៈកិច្ចព្រមព្រៀងនេះ បារាំងលែងគ្រប់គ្រងប្រទេសកម្ពុជាដូចពេលមុន៖

- លោករ៉េស៊ីដង់ជាន់ខ្ពស់ត្រូវបានជំនួសដោយស្នងការសាធារណរដ្ឋបារាំង[38]
- លោករ៉េស៊ីដង់ខេត្តត្រូវបានជំនួសដោយទីប្រឹក្សាតំបន់ចំនួន៧ ហើយតំបន់នីមួយៗមានខេត្តពីរ។

## ៣.ការតស៊ូដើម្បីឯករាជ្យជាតិពេញបរិបូរ

### ការតស៊ូដោយអាវុធ

ការតស៊ូដោយប្រដាប់អាវុធនេះដឹកនាំដោយខ្មែរឥស្សរៈដែលមាននិន្នាការសេរីនិងកុម្មុយនីស្ត និងខ្មែរវៀតមិញដែលគាំទ្រចលនាកុម្មុយនីស្ត។ នៅឆ្នាំ១៩៤៩ កងទ័ពខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាងសកម្ម និងពង្រឹងការត្រួតត្រារបស់ខ្លួនលើផ្ទៃដី ១/៣ នៃប្រទេស និងប្រជាជនប្រហែល១លាននាក់។ ព្រឹត្តិការណ៍នេះបានធ្វើឱ្យព្រះបាទ នរោត្តម សីហនុព្យាយាមចរចាជាមួយបារាំងដើម្បីឯករាជ្យ។

ជាលទ្ធផល បារាំងផ្តល់ឱ្យព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យមួយស្ថិតក្នុងសហព័ន្ធឥណ្ឌូចិន-បារាំងនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩[39]។

### ការតស៊ូដោយសន្តិវិធី

ការតស៊ូនេះដឹកនាំដោយសម្តេច នរោត្តម សីហនុ។

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ សម្តេច នរោត្តម សីហនុបានយាងទៅកាន់ប្រទេសបារាំង។ ក្រោយពីបានផ្ញើសារលិខិតចំនួន២ដងទៅកាន់ថ្នាក់ដឹកនាំបារាំងនៅថ្ងៃពុធ ទី២៥ ខែ មីនា ឆ្នាំ១៩៥៣ លោក វ៉ាំងសង់ អូរីយ៉ូលដែលជាប្រធានាធិបតីបារាំងបានទទួលបដិសណ្ឋារកិច្ចក្នុងពិធីលៀងសាយភោជន៍នៅវិមានអេលីហ្សេ ប៉ុន្តែពុំបានអនុញ្ញាតឱ្យព្រះអង្គជជែកពីបញ្ហានយោបាយកម្ពុជាទេ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣ ព្រះអង្គបានយាងទៅកាន់ប្រទេសកាណាដា។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៥៣ ព្រះអង្គបានធ្វើសន្និសីទកាសែតមួយតាមវិទ្យុកាណាដា ដោយបញ្ជាក់ថា ការផ្សព្វផ្សាយរបស់ពួកឥស្សរៈ និងកុម្មុយនីស្តមានឥទ្ធិពលខ្លាំងក្នុងការទាក់ទាញប្រជាជន ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាព

---

[38](Commissaire de la République française)
មន្ត្រីជាន់ខ្ពស់បារាំងនៅកម្ពុជា៖
-ពីឆ្នាំ១៨៦៣ ដល់១៨៨៥ មានឈ្មោះថាអ្នកតំណាងអាណាព្យាបាល(Représentant du Protectorat)
-ពីឆ្នាំ១៨៨៥ ដល់១៨៨៩មានឈ្មោះថាអគ្គរ៉េស៊ីដង់(Résident général)
-ពីឆ្នាំ១៨៨៩ ដល់១៩៤៥មានឈ្មោះថារ៉េស៊ីដង់ជាន់ខ្ពស់(Résident supérieur)។

[39]សន្ធិសញ្ញាបារាំង-ខ្មែរថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ត្រូវបានចុះហត្ថលេខានៅទីក្រុងប៉ារីសដោយមាន២០ មាត្រា។ មាត្រាទី១ចែងថា ៖ «សាធារណរដ្ឋបារាំងទទួលស្គាល់ថា ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ។ ព្រះរាជាណាចក្រកម្ពុជា អះអាងឡើងវិញនូវភាពជាសមាគតរដ្ឋ(រដ្ឋដែលចូលរួមផ្តុំជាមួយរដ្ឋផ្សេងៗគ្នា)។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃប្រទេសកម្ពុជា។ ព្រះអង្គប្រកាសថា លទ្ធផលនៅតែអវិជ្ជមានដដែល បើប្រជាជននៃប្រទេសជឿនលឿនមិនចូលរួមក្នុងបុព្វហេតុនៃការតស៊ូដ៏ត្រឹមត្រូវនេះ។

ព្រះអង្គយាងចាកចេញពីកាណាដា ទៅកាន់សហរដ្ឋអាមេរិក។ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកនិយាយថា«សហរដ្ឋអាមេរិកក៏មានការពេញចិត្តចំពោះការផ្តល់ឯករាជ្យដល់កម្ពុជាដែរ។ សហរដ្ឋអាមេរិកសន្យានឹងជួយកម្ពុជាឱ្យទទួលបានឯករាជ្យពេញលេញក្រោយសង្គ្រាមឥណ្ឌូចិនចប់។ សម្តេច នរោត្តម សីហនុខកព្រះទ័យ ប៉ុន្តែទ្រង់នៅតែមានក្តីសង្ឃឹមក្នុងការទាក់ទាញអ្នកនយោបាយបរទេសឱ្យយល់ពីបញ្ហារបស់ខ្មែរ។

នៅទីក្រុងញូវយ៉ក សម្តេច នរោត្តម សីហនុបានផ្តល់បទសម្ភាស ជាមួយភ្នាក់ងារកាសែតញូវយ៉កថៃម (New York Times)។ នៅថ្ងៃអាទិត្យ ទី១៩ ខែមេសា ឆ្នាំ១៩៥៣ កាសែតបានចុះផ្សាយនៅទំព័រមុខ ដោយបញ្ជាក់ថា «**ប្រសិនបើបារាំងមិនផ្តល់ឯករាជ្យឱ្យកម្ពុជាទេ នោះប្រជាជនខ្មែរទូទាំងប្រទេសនឹងក្រោកឡើងធ្វើការប្រឆាំងនឹងអាណាព្យាបាលដោយចូលរួមជាមួយចលនារបស់ពួកកុម្មុយនីស្ត**»។ នៅក្នុងបរិបទសង្គ្រាមត្រជាក់ ដោយខ្លាចកម្ពុជាធ្លាក់ទៅក្នុងប្លុកកុម្មុយនីស្ត បារាំងដែលជាសមាជិកប្លុកសេរីក៏ស្នើសុំចរចាជាមួយកម្ពុជានៅប៉ារីស។

នៅឯតំបន់ស្វយ័ត(ខេត្តសៀមរាប កំពង់ធំ(១៩៤៩) និងខេត្តបាត់ដំបង(១៩៥២))វិញ ប្រជាពលរដ្ឋប្រុស-ស្រី ចំនួន៤០០ ០០០នាក់ ស្ម័គ្រចិត្តចូលបម្រើក្នុងកងជីវពលនារីក្លាហាន ប្តេជ្ញាដើរតាមព្រះបាទនរោត្តម សីហនុ ដើម្បីទាមទារឯករាជ្យ។ ឯពួកប្រជាធិបតេយ្យនិយមស្តាំបានឈប់បង្កជម្លោះ ហើយងាកមកចូលរួមជាមួយរាជរដ្ឋាភិបាល។

ក្រោយពីមានការចរចារវាងបារាំង និងខ្មែរជាបន្តបន្ទាប់ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នៅមុខព្រះបរមរាជវាំង មានប្រារព្ធពិធីផ្ទេរអំណាចមេបញ្ជាការយោធាចុងក្រោយដោយឧត្តមសេនីយ ដឺ ឡង់ក្លាដថ្វាយព្រះមហាក្សត្រខ្មែរដែលជានិមិត្តរូបនៃឯករាជ្យពេញលេញរបស់កម្ពុជា។

## ៤. សន្និសញ្ញាក្រុងហ្សឺណែវ១៩៥៤

សន្និសីទក្រុងហ្សឺណែវ(សន្និសញ្ញាក្រុងហ្សឺណែវ)បានរៀបចំឡើងពីថ្ងៃទី២៦ ខែមេសាដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤។ លទ្ធផលសំខាន់ៗទាក់ទងនឹងកម្ពុជាគឺ ៖

### សកម្មភាពយោធា

- សកម្មភាពយោធាត្រូវបានបញ្ឈប់ទាំងស្រុងនៅលើទឹកដីប្រទេសកម្ពុជាចាប់ពីថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៤
- ការដកទ័ពបរទេសចេញពីទឹកដីប្រទេសកម្ពុជាឱ្យអស់ក្នុងអំឡុងពេល៩០ថ្ងៃ
- កម្លាំងកងទ័ពខ្មែរឥស្សរៈត្រូវបានរំសាយក្នុងអំឡុង៣០ថ្ងៃ

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានធានាដល់អតីតអ្នកចូលរួមក្នុងចលនាតស៊ូ ធានាដល់សិទ្ធិពលរដ្ឋ ការពារជីវិតទ្រព្យសម្បត្តិ និងធានាដល់សិទ្ធិក្នុងការអនុវត្តសេរីភាព និងប្រជាធិបតេយ្យ។

រាជរដ្ឋាភិបាលបានអះអាងចំពោះសេចក្តីសម្រេចរបស់ខ្លួនថា «ប្រជាពលរដ្ឋកម្ពុជាទាំងអស់រួមរស់នៅក្នុងសហគមន៍ជាតិតែមួយដោយមិនប្រកាន់ពូជសាសន៍ និងធានាដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួនដូចដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ»។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ការបោះឆ្នោតជាសកលនៅកម្ពុជាស្របតាមសន្និសីទក្រុងហ្សឺណែវក៏បានប្រព្រឹត្តឡើង។

## V. ចំណុចវិជ្ជមាន និងអវិជ្ជមាននៃអាណាព្យាបាលរបស់បារាំង

### ១. លទ្ធផលវិជ្ជមាន

- បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេសដើម្បីស្រាវជ្រាវ ចងក្រង ផ្សព្វផ្សាយពីអរិយធម៌ សិល្បៈចម្លាក់ ប្រវត្តិសាស្ត្ររបស់ខ្មែរ និងជួសជុលប្រាសាទបុរាណខ្មែរជាច្រើន...ធ្វើឱ្យមរតកអតីតកាលខ្មែរដែលកប់បាត់បានរស់ឡើងវិញ។ កិច្ចការនេះបានផ្តល់ប្រយោជន៍ជាច្រើនដល់ខ្មែរ ដូចជាការមានទំនុកចិត្ត និងមោទនភាពជាតិតាមរយៈភាពរុងរឿងនៃចក្រភពអង្គរ ព្រមទាំងពញ្ញាក់ស្មារតីខ្មែរឱ្យចេះសាមគ្គីតាមរយៈមេរៀនប្រវត្តិសាស្ត្រ
- ក្រោមការកៀបសង្កត់របស់បារាំង សៀមបានប្រគល់មកឱ្យខ្មែរវិញនូវខេត្តកោះកុង ម្លូព្រៃ ទន្លេរពៅ ស្ទឹងត្រែង បាត់ដំបង សៀមរាប សិរីសោភ័ណ...
- នៅឆ្នាំ១៩០៨ បារាំងបានធ្វើផែនទីដងរែកជាច្រើនផ្ទាំង ដែលទទួលស្គាល់ដោយរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលសៀម។ ផែនទីទាំងនេះបានផ្តល់សារៈប្រយោជន៍យ៉ាងខ្លាំងដល់កម្ពុជាក្នុងរឿងក្តីប្រាសាទព្រះវិហារនៅតុលាការអន្តរជាតិទីក្រុងឡាអេ ប្រទេសហូឡង់។
- កំណែទម្រង់ដែលនាំមកនូវទំនើបកម្មនៅកម្ពុជា៖
  - វិស័យរដ្ឋបាល៖ បារាំងបានកែទម្រង់វិស័យរដ្ឋបាលខ្មែរឱ្យមានប្រសិទ្ធភាព និងមានរបៀបរៀបរយ។
  - វិស័យសង្គម ៖
    - ការកែទម្រង់លើប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធិដីធ្លី និងការលុបបំបាត់ទាសភាពបានធ្វើឱ្យមានការប្រែប្រួលវិស័យចិត្តសាស្ត្រសង្គម
    - ការបង្កើតឡើងនូវការចុះបញ្ជីដីធ្លី និងការបង្កើតនូវកម្មសិទ្ធិលើដីធ្លីបានផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់បុរាណ

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការបង្កើតប្រព័ន្ធច្បាប់ថ្មីធ្វើឱ្យសង្គមខ្មែរមានភាពម្ចាស់ការ និងស្ថិរភាព ពិសេសម្ចាស់ដីតូចតាច

- វិស័យសិក្សាធិការ ៖
  - មានការបង្កើតសាលាតាមវត្ត សាលាតាមឃុំ និងសាលាបឋមសិក្សា រីឯសាលាមធ្យមសិក្សាដែលបង្កើតដំបូងមាន អនុវិទ្យាល័យព្រះស៊ីសុវត្ថិ
  - មានការដាក់ទោសដល់ឪពុកម្ដាយណាដែលមិនបញ្ជូនកូនទៅរៀន
  - មានការបង្កើតគណៈកម្មាធិការរៀបចំវចនានុក្រមខ្មែរ ដើម្បីធ្វើឱ្យភាសាជាតិមានលក្ខណៈប្រាកដនិយមនៅឆ្នាំ១៩១៥
- វិស័យសេដ្ឋកិច្ច៖ ពឹងផ្អែកលើកសិកម្ម និងកសិ-ឧស្សាហកម្មដូចជា ម្រេច ក្រចៅ ថ្នាំជក់ កៅស៊ូ...
- វិស័យកសិកម្ម ៖ បារាំងបានបង្កើនផ្ទៃដីកសិកម្ម និងដំណាំកៅស៊ូ។ កំណែទម្រង់នេះបានធ្វើឱ្យកម្ពុជាមានមុខមាត់លើទីផ្សារអន្តរជាតិ ព្រមទាំងបង្កើតបាននូវប្រព័ន្ធផ្គត់ផ្គង់ផលិតផលលើទីផ្សារ។
- វិស័យសុខាភិបាល៖ មានការបង្កើតមន្ទីរពេទ្យ
- វិស័យគមនាគមន៍ ៖ ការកសាងស្ពានព្រះមុនីវង្សឆ្លងកាត់ទន្លេបាសាក់ ផ្លូវរថភ្លើងមួយខ្សែប្រវែង២៧៥គីឡូម៉ែត្រដែលតភ្ជាប់ពីភ្នំពេញទៅអារញ្ញដោយកាត់តាមប៉ោយប៉ែត ព្រមទាំងផ្លូវថ្នល់ជាច្រើនដូចជាផ្លូវអាណានិគម(ផ្លូវជាតិ) ផ្លូវខេត្ត និងផ្លូវលំជនបទ...

## ២. លទ្ធផលអវិជ្ជមាន

- សង្គមខ្មែរបានលេចឡើងនូវសកម្មភាពពាណិជ្ជកម្មយ៉ាងសកម្មក្នុងការទិញដូរអចលនវត្ថុ ការដាក់បញ្ចាំ និងការធ្វើជំនួញស្រូវ-អង្ករនៅទីក្រុង ដែលជាទំនាក់ទំនងប្រព័ន្ធ«ទីផ្សារ»។ ស្របពេលជាមួយគ្នា យើងសង្កេតឃើញថា ពួកអ្នកមាន និងអ្នកជំនួញភាគច្រើនជាជនជាតិចិន និងយួន ឯកសិករខ្មែរភាគច្រើនក្លាយជាជនរងគ្រោះអស់ដីធ្លី ដោយការលក់-បញ្ចាំ។
- បារាំងបានធ្វើការជិះជាន់ គាបសង្កត់ និងប្រមូលពន្ធដារគ្រប់ប្រភេទយ៉ាងធ្ងន់ធ្ងរដែលធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រ
- បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឱ្យបម្រើយោធាបារាំងក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២
- ទឹកដីកម្ពុជាមួយចំនួនដែលស្ថិតនៅប៉ែកខាងកើតទន្លេមេគង្គដូចជាអាតាពើ(Attopeu)ត្រូវបានបារាំងសម្រេចប្រគល់ទៅឱ្យកូសាំងស៊ីននៅឆ្នាំ១៨៩៣។ ទឹកដីដ៏មានដីជាតិ និងសម្បូរទៅដោយធនធានធម្មជាតិនេះ ផ្ដល់សារៈសំខាន់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងនយោបាយ

facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់សៃហ្គុន ជាពិសេសកូសាំងស៊ីនដែលជាទឹកដីក្រោមការគ្រប់គ្រងផ្ទាល់របស់បារាំង។ បារាំងបានពន្យល់ពីហេតុផលនៃការកាត់ដីនេះទៅឱ្យកូសាំងស៊ីនថា ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តមបដិសេធមិនព្រមទទួលដោយសារកង្វះខាតថវិកាក្នុងការគ្រប់គ្រង។ ក្រោយមក ទឹកដីអាតាពើត្រូវបានបារាំងកាត់ទៅឱ្យឡាវវិញ[40]។

- នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បារាំងបានដាក់បញ្ចូលកោះត្រល់ទៅក្នុងដែនរដ្ឋបាលកូសាំង-ស៊ីន[41]
- បារាំងបានកាត់ទឹកដីកម្ពុជាក្រោម(កូសាំងស៊ីន)[42]ទៅឱ្យអំណាចស្តេចបាវដាយវៀតណាមនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩
- បារាំងប្រមូលយកវត្ថុកេតនភណ្ឌរបស់ខ្មែរទៅស្រុកបារាំង។

[40] Sarin Chhak, Les frontiers du Cambodge, Dalloz, 1966, pp26-35.

[41] លិខិតរបស់លោកប្រឺវីយេ ចុះថ្ងៃទីថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩។

[42] សូមពិនិត្យសាររបស់ព្រះបាទអង្គដួងក្នុងទំព័រទី៦។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មេរៀនទី២

# របបសង្គមរាស្ត្រនិយម
# (១៩៥៥-១៩៧០)

## I.ការបង្កើតរបបសង្គមរាស្ត្រនិយម

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានកំណត់ឱ្យកម្ពុជាជាប្រទេសរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ
- រាល់ទស្សនៈនយោបាយ ព្រះមហាក្សត្រត្រូវធ្វើសេចក្ដីស្នើទៅសភាទើបមានសុពលភាព
- គណបក្សក្នុងសភាជារបាំងរាំងជានិច្ចទោះបីកម្មវិធីព្រះមហាក្សត្រល្អយ៉ាងណាក៏ដោយ
- ព្រះរាជតម្រិះរបស់ព្រះបាទ នរោត្តម សីហនុ គឺចង់ឱ្យគណបក្សនយោបាយមហាជនរស់ជុំវិញព្រះមហាក្សត្រ។ ព្រះអង្គមិនចង់ឃើញបញ្ហាផ្ទៃក្នុងដែលនៅតែប្រេះស្រាំ គ្មានឯកភាពជាតិ។

អាស្រ័យហេតុនេះទើបនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះបាទ នរោត្តម សីហនុ បានថ្វាយរាជបល្ល័ង្កទៅព្រះបិតានាម នរោត្តម សុរាម្រឹត[43]។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ សម្ដេច នរោត្តម សីហនុ បានបង្កើតអង្គការនយោបាយ«សង្គមរាស្ត្រនិយម» ហៅកាត់ថា«សង្គម»[44]។ អង្គការនេះចូលរួមបោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ដែលមានបក្សជាច្រើនចូលរួមប្រកួតប្រជែង។

## II.កត្តាដែលធ្វើឱ្យប្រជាជនជឿជាក់លើ«សង្គមរាស្ត្រនិយម»

- សម្ដេច នរោត្តម សីហនុដែលជាស្ថាបនិក និងជាប្រធានមានប្រជាប្រិយភាពខ្លាំង ព្រោះប្រជារាស្ត្រទទួលស្គាល់ព្រះអង្គជាបិតាឯករាជជាតិ និងសន្តិភាព
- ភាពរឹងមាំនៃរចនាសម្ពន្ធដឹកនាំរបស់«សង្គមរាស្ត្រនិយម»ថ្នាក់មូលដ្ឋាន ៖ កត្តានេះធ្វើឱ្យមានការគាំទ្រពីមហាជនថ្នាក់មូលដ្ឋាន និងមន្ត្រីរាជការដែលជាកម្លាំងចលករធ្វើឱ្យមានជ័យជម្នះក្នុងការបោះឆ្នោត
- ក្រៅពីសម្ដេច នរោត្តម សីហនុ ដែលជាអ្នកដឹកនាំ មានឥស្សរជននយោបាយសំខាន់ៗជាច្រើនទៀតបានចូលរួមក្នុង«សង្គមរាស្ត្រនិយម»ដូចជាលោក ស៊ឹម វ៉ារ លោក សឺន សាន ព្រះអង្គម្ចាស់ នរិន្ទដេត លោក យ៉ែម សំបូរ ជាដើម
- គណបក្សសង្គមរាស្ត្រនិយមមានហិរញ្ញវត្ថុរឹងមាំ ដែលបានមកពីការបរិច្ចាគរបស់សមាជិក និងអ្នកមានទ្រព្យសម្បត្តិភាគច្រើនក្នុងស្រុក។

---

[43] ពុយ គា, *រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០*, បោះពុម្ពលើកទីពីរ, រាហ៊ុ, ២០១០, ភ្នំពេញ, ទំព័រទី៣៤។
[44] Raoul Marc Jennar, *Le clé du Cambodge*, Maisonneuve & Larose, 326 p, p.58.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងការបោះឆ្នោតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ គណបក្សសង្គមរាស្ត្រនិយម ដណ្ដើមបានសំឡេងជាង៨៣ភាគរយក្នុងសភាដែលបង្កើតរាជរដ្ឋាភិបាលឯកតោភាគី។ ប្រព័ន្ធពហុបក្សត្រូវបានបញ្ចប់ និងជំនួសដោយប្រព័ន្ធឯកបក្ស«សង្គមរាស្ត្រនិយម»រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

## III.សមាជជាតិ[45]

- សមាជជាតិគឺជាវេទិកានៃលទ្ធិប្រជាធិបតេយ្យដែលប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ គ្រប់និន្នាការនយោបាយ ជួបជាមួយរាជរដ្ឋាភិបាលដើម្បីពិភាក្សាពីប្រយោជន៍រួមរបស់ជាតិ ។
- សមាជជាតិប្រារព្ធឡើងក្នុង១ឆ្នាំ២ដង ដោយមានសម្ដេច នរោត្តម សីហនុ ជាព្រះប្រធាន ។ សមាជជាតិត្រូវបានសង្គមរាស្ត្រនិយមរៀបចំឡើងជាលើកដំបូងនាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៥ ដែលមានការចូលរួមពីមហាជនគ្រប់ស្រទាប់វណ្ណៈ គ្រប់និន្នាការនយោបាយ និងតំណាងបក្សផ្សេងៗ ។ នៅថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ១៩៥៥ សមាជជាតិបានប្រារព្ធឡើងជាលើកទី២ដោយបានពិភាក្សាគ្នាពីការផ្ដល់សិទ្ធិបោះឆ្នោតឱ្យស្ត្រី និងគោលការណ៍នៃការជ្រើសរើសសភាខេត្ត។
- ក្រោយមក សមាជជាតិបានក្លាយជាស្ថាប័នរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។
- សមាជជាតិសម្រេចបានសមិទ្ធផលជាច្រើនដូចជា៖
    - ការប្រឆាំងនឹងអំពើពុករលួយ
    - ការកំណត់ភាសាខ្មែរជាផ្លូវការ
    - សភាតំណាងរាស្ត្រមានសិទ្ធិចូលរួមក្នុងការកែលំអសកម្មភាពរដ្ឋបាល និងទាមទារឱ្យដាក់ទណ្ឌកម្មចំពោះមន្ត្រីអសកម្ម។
    - ផ្តល់សិទ្ធិដល់ស្ត្រីក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត (ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៥៨)។

## IV.នយោបាយអព្យាក្រឹត

នៅពេលដែលពិភពលោកកំពុងតែរងការគំរាមកំហែងពីការប្រណាំងប្រជែងរបស់មហាអំណាចសេរី និងលោកកុម្មុយនីស្ត កម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រឹត និងចូលក្នុងចលនាមិនចូលបក្សសម្ពន្ធ ទាត់ចោលការចូលក្នុងអង្គការយោធាសេអាតូ។

### ១. មូលហេតុនៃការប្រកាន់យកនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម

នយោបាយអព្យាក្រឹតជាស្មារតីនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤។ សេចក្ដីសម្រេចនេះគឺជាការទាមទាររបស់ចិន និងសូវៀតដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាមេរិកកសាងមូលដ្ឋានទ័ពនៅកម្ពុជា។

ដើម្បីពង្រឹងនយោបាយអព្យាក្រឹតនៅកម្ពុជា សង្គមរាស្ត្រនិយមបានធ្វើកិច្ចការដូចតទៅ ៖

---

[45]សមាជជាតិគឺជាមហាសន្និបាតថ្នាក់ជាតិ ឬការប្រជុំពិភាក្សាអំពីបញ្ហាផ្សេងៗដែលមានផលប្រយោជន៍ជាទូទៅសម្រាប់ជាតិ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌា សម្តេច នរោត្តម សីហនុ បានចុះហត្ថលេខាជាមួយលោក នេរុ(នាយករដ្ឋមន្ត្រីឥណ្ឌា) លើសេចក្តីប្រកាសរួមតីការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព
- នៅថ្ងៃទី១៨-២៤ ខែមេសា ឆ្នាំ១៩៥៥ ក្នុងសន្និសីទប្រទេសអាស៊ី-អាហ្វ្រិកនាក្រុងបានឌុង(ឥណ្ឌូណេស៊ី) សម្តេច នរោត្តម សីហនុបានធ្វើសេចក្តីអះអាងអំពីកម្មវិធីនយោបាយអព្យាក្រឹតរបស់កម្ពុជា និងការរួមរស់ជាមួយគ្នាដោយសន្តិភាព។ ក្នុងឱកាសនោះ ទ្រង់បានជួបជាមួយមេដឹកនាំចិន ជូ អេនឡាយ និងមេដឹកនាំវៀតណាម ផាម វ៉ាន់ដុង ដែលប្រទេសទាំងពីរសុទ្ធតែបានប្រកាសពីការកសាងទំនាក់ទំនងជាមួយកម្ពុជា ដោយឈរលើគោលការណ៍គោរពសិទ្ធិគ្នាទៅវិញទៅមក គោរពអធិបតេយ្យភាព បូរណភាពទឹកដី និងមិនលូកដៃចូលបញ្ហាផ្ទៃក្នុងរបស់ប្រទេសជិតខាង
- នៅក្នុងឱកាសដែលកម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ នោះ តំណាងរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការដើរលើមាគ៌ានយោបាយអព្យាក្រឹត។

## ២. លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត

### ជំហានដំបូង

- ធ្វើឱ្យកិត្យានុភាពកម្ពុជាល្បីសុះសាយក្នុងតំបន់
- ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ ហើយទទួលស្គាល់គុណសម្បត្តិនៃនយោបាយអព្យាក្រឹត
- ប្រទេសកម្ពុជារស់ក្នុងសុខសន្តិភាពអស់រយៈពេល១៥ឆ្នាំ ក្នុងខណៈដែលប្រទេសជិតខាងដូចជាវៀតណាមស្ថិតក្នុងភ្លើងសង្គ្រាម។

### ដំណាក់កាលនៃសង្គ្រាមត្រជាក់

នយោបាយអព្យាក្រឹតរបស់កម្ពុជាចុះខ្សោយ ដោយសារតែប្រទេសជាមហាអំណាចនៃប្លុកទាំងពីរមិនទុកកម្ពុជាក្នុងមាគ៌ាសន្តិភាព ហើយគេបានធ្វើសកម្មភាពប្រឆាំងនឹងនយោបាយអព្យាក្រឹតដូចជា៖

- **សហរដ្ឋអាមេរិក**ផ្តល់ជំនួយដល់កម្ពុជា ពិសេសជំនួយផ្នែកយោធាដែលជំនួយនេះមានទិសដៅចិញ្ចឹមពួកស្តាំនិយម[46]
- **ប្រទេសថៃ**បានគាំទ្រសកម្មភាពខ្មែរសេរី ដែលជាកងទ័ពប្រឆាំងរាជរដ្ឋាភិបាល ដោយផ្តល់ដីឱ្យកសាងជំរំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម
- កងទ័ព**វៀតណាមខាងត្បូង**បានធ្វើសកម្មភាពឈ្លានពានលើទឹកដីខ្មែរតាមព្រំដែន

[46]ពួកស្តាំនិយមនៅទីនេះសំដៅយកអ្នកដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិក(សេរីនិយម)។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កងទ័ព**វៀតណាមខាងជើង**បានបង្កើតមូលដ្ឋានទ័ពលើទឹកដីខ្មែរនៅតាមព្រំដែន។ ពួកនេះបានបណ្តុះបណ្តាលកងកម្លាំងខ្មែរក្រហមដើម្បីធ្វើបដិវត្តន៍។

សកម្មភាពរបស់ប្រទេសខាងលើមានទិសដៅប្រឆាំងនឹងនយោបាយអព្យាក្រឹត។

### ការបញ្ចប់នយោបាយអព្យាក្រឹត

នយោបាយអព្យាក្រឹតត្រូវបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ដោយលោក លន់ នល់ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិក ដើម្បីទម្លាក់សម្តេចនរោត្តម សីហនុ ពីប្រមុខរដ្ឋ។

## V.ការឡើងកាន់អំណាចជាប្រមុខរដ្ឋរបស់សម្តេចនរោត្តម សីហនុ

### ១. ការជ្រើសតាំងព្រះមហាក្សត្រថ្មី

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៦០ ព្រះមហាក្សត្រ នរោត្តម សុរាម្រឹត សោយទិវង្គត។ ការជ្រើសរើសអ្នកបន្តរាជ្យគឺជាបញ្ហាស្មុគស្មាញ។ តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ អ្នកបន្តរាជ្យសម្បត្តិត្រូវតែជាក្សត្រដែលមានខ្សែលោហិតព្រះបាទអង្គដួង ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សារាជ្យសម្បត្តិ។

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៦០ ការប្រជុំក្រុមប្រឹក្សារាជ្យសម្បត្តិ ពុំអាចជ្រើសរើសបេក្ខជនណាមួយជាមហាក្សត្រថ្មីបាន។ គេក៏បង្កើត«ក្រុមប្រឹក្សារាជានុសិទ្ធិ» ដោយមានទ្រង់ស៊ីសុវត្ថិ មុនីរ៉េត ជាប្រធានដែលមានតួនាទីបំពេញការងារជាព្រះមហាក្សត្របណ្តោះអាសន្ន។

### ២. ការធ្វើប្រជាមតិ កម្មវិធីនយោបាយសង្គមរាស្ត្រនិយម

ដើម្បីពង្រឹងជំហរនយោបាយសង្គមរាស្ត្រនិយមក្រោយពីសម្តេច នរោត្តម សីហនុ សុំលាលែងពីតំណែងក្រុមប្រឹក្សារដ្ឋមន្ត្រី រាជរដ្ឋាភិបាលក៏បានសម្រេចចិត្តរៀបចំធ្វើប្រជាមតិ។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ ១៩៦០ ការធ្វើប្រជាមតិត្រូវបានប្រព្រឹត្តឡើង។ ប្រជាជន៩៩.៩៨ភាគរយបានបោះឆ្នោតឱ្យកម្មវិធីនយោបាយសង្គមរាស្ត្រនិយម និងសម្តេច នរោត្តម សីហនុ ។

### ៣. ការជ្រើសរើសប្រមុខរដ្ឋ

យោងតាមរដ្ឋធម្មនុញ្ញ នៅពេលដែលកម្ពុជាមិនទាន់មានព្រះមហាក្សត្រថ្មី តួនាទីប្រមុខរដ្ឋត្រូវបំពេញដោយប្រធានសភា។

ក្រោយពីបានលទ្ធផលនៃការធ្វើប្រជាមតិ សម្តេច នរោត្តម សីហនុ បានថ្លែងសុន្ទរកថាចំពោះមុខប្រជាជនក្រុងកែប អំពីបំណងរបស់ទ្រង់ចង់កាន់តំណែងជា«ព្រះប្រមុខរដ្ឋ» បើប្រជារាស្ត្រស្នើសុំព្រះអង្គ។ សេចក្តីថ្លែងការណ៍នេះធ្វើឱ្យមានព្យុហយាត្រាគាំទ្ររបស់ប្រជាជននៅក្រុងកែប និងរាជធានីភ្នំពេញ។ សភាជាតិ និងក្រុមប្រឹក្សារាជានុសិទ្ធិក៏បានអនុម័តសេចក្តីសម្រេចចិត្តស្នើសុំឱ្យសម្តេច នរោត្តម សីហនុ កាន់តំណែងជាប្រមុខរដ្ឋ ដោយបានបង្កើតមាត្រាពិសេសនៅក្នុងរដ្ឋធម្មនុញ្ញ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំនាស់ជុំវិញបញ្ហារាជបល្ល័ង្កបានបញ្ចប់ ហើយព្រះមហាក្សត្រិយានី កុសមៈនារីរតន៍ គង់ប្រថាប់ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក។

## VI.សមិទ្ធផលសង្គមរាស្ត្រនិយម

### ១. វិស័យសេដ្ឋកិច្ច

- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ធ្វើការជ្រើសរើសពូជ ធ្វើនយោបាយទឹក ប្រើប្រាស់ជី ចាក់ថ្នាំបង្ការដល់សត្វពាហនៈដែលជាកម្លាំងអូសទាញ បង្កើតវត្ថុទិវាគ្រប់ខេត្ត-ក្រុង
- វិស័យនេសាទមានការរីកចម្រើនដែលអាចបម្រើជីវភាពប្រជាជនប្រចាំថ្ងៃ និងនាំចេញទៅលក់នៅបរទេសថែមទៀត។

### ២. វិស័យគមនាគមន៍

- ពង្រីកកំពង់ផែភ្នំពេញ និងកសាងកំពង់ផែនៅក្រុងព្រះសីហនុ
- កសាងផ្លូវជាតិលេខ៤ ប្រវែង២២៦គីឡូម៉ែត្រ
- ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង(បច្ចុប្បន្នអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) និងកសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប...
- កសាងផ្លូវរថភ្លើងខ្សែទី២ ពីភ្នំពេញ ទៅក្រុងព្រះសីហនុ ប្រវែង២៧០គីឡូម៉ែត្រ និងកសាងស្ពានជ្រោយចង្វារ(ស្ពានមិត្តភាពកម្ពុជា-ជប៉ុន)
- ភ្ជាប់ខ្សែទូរសព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ ក្រុងអូសាកា...។

### ៣. វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម

#### វិស័យពាណិជ្ជកម្ម

- ក្រុមហ៊ុនធំៗរបស់បារាំង និងសាខាក្រុមហ៊ុនសហរដ្ឋអាមេរិកជាច្រើនបានដាក់ទុនវិនិយោគនៅកម្ពុជា
- នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ រាជរដ្ឋាភិបាលបានសម្រេច និងអនុវត្តការកែប្រែប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដោយធ្វើការហាមឃាត់ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេស និងធនាគារឯកជនខាងពាណិជ្ជកម្មនៅក្នុងស្រុក។ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសខ្លះបន្តសកម្មភាពរបស់ខ្លួនដូចជាក្រុមហ៊ុន សែល ក្រុមហ៊ុនអេសូ និងកាល់តិច
- រដ្ឋបានបង្កើតក្រុមហ៊ុនឈ្មោះ ក្រុមហ៊ុនអាហរ័ណនីហរ័ណជាតិ ហៅកាត់ថា «សូណិចស៊ីម» ដែលមាន៦០ភាគរយជាទុនរបស់រដ្ឋ និង៤០ភាគរយជាទុនពាណិជ្ជករកម្ពុជា

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នៅឆ្នាំ១៩៦៤ ក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋពីរទៀតត្រូវបានបង្កើតឡើងគឺ ៖ ក្រុមហ៊ុនខ្មែរនៃការទិញផលិតផលកសិកម្ម ហៅកាត់ថា សូរ៉ាប៉ា និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល ហៅកាត់ថា សូណាព្រីម។

### វិស័យធនាគារ

ប្រាក់រៀលដែលជារូបិយវត្ថុក្នុងស្រុកត្រូវបានចរាចរទូទាំងប្រទេស។ ចំពោះវិស័យធនាគារ គេឃើញមានក្រុមហ៊ុនបរទេសពីរគឺ៖

- អង់គ្លេសមានធនាគារឆាទែរិច និងហុងកុងសៀងហៃ
- ជប៉ុនមានធនាគារអូហូតូក្យូ។

ធនាគារទាំងនេះបានបញ្ចប់បេសកម្មរបស់ខ្លួនក្រោយពីរាជរដ្ឋាភិបាលអនុវត្តការកែប្រែប្រព័ន្ធធនាគារ។ ការផ្តល់ឥណទានត្រូវបានធ្វើដោយធនាគារពាណិជ្ជកម្មរដ្ឋឈ្មោះឥណទានជាតិ។

### វិស័យឧស្សាហកម្ម

រាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា រោងចក្រវាយនភណ្ឌ រោងចក្រក្តារបន្ទះ រោងចក្រកែវ រោងចក្រក្រដាស រោងចក្រស៊ីម៉ងត៍ រោងចក្របាវក្រចៅ រោងចក្រស្ករស រោងចក្រដំឡើងត្រាក់ទ័រ រោងចក្រចម្រាញ់ប្រេងកាត និងរោងចក្រស្រាបៀ។

ទន្ទឹមនឹងនោះក៏មានការកសាងទំនប់វារីអគ្គិសនីនៅស្ទឹងប្រាល គិរីរម្យ និងនៅព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ។

## ៤. វិស័យវប្បធម៌

### ការសិក្សា

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់វិស័យសិក្សាធិការដោយបណ្តុះបណ្តាលគ្រូបង្រៀន និងកសាងសាលារៀនពីបឋមដល់សាកលវិទ្យាល័យ ព្រមទាំងធ្វើយុទ្ធនាការបំបាត់អនក្ខរភាព។

រាជរដ្ឋាភិបាលក៏បានបញ្ជូននិស្សិតទៅសិក្សានៅបរទេសពិសេសប្រទេសបារាំង ព្រមទាំងកសាងអន្តេវាសិកដ្ឋាននៅទីនោះផងដែរ។

### វិស័យកីឡា

រាជរដ្ឋាភិបាលបានលើកស្ទួយវិស័យកីឡាឱ្យមានសន្ទុះខ្លាំងក្លា ដោយបណ្តុះបណ្តាលកីឡាគ្រប់ខេត្តក្រុង និងជួលគ្រូមកពីបរទេសមកបង្ហាត់បង្រៀន និងកសាងពហុកីឡដ្ឋានជាតិអូឡាំពិក។

### សាសនា

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះព្រះពុទ្ធសាសនាដោយបង្កើតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកមហាវិទ្យាល័យ។

facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### សិល្បៈ

រាជរដ្ឋាភិបាលបានចាត់វិធានការថែរក្សាសម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ព្រមទាំងបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាលមហោស្រពតាមខេត្ត-ក្រុង។

## ៥. វិស័យសង្គមកិច្ច

### វិស័យសុខាភិបាល

សុខភាពជាបញ្ហាចម្បង ដូចនេះរាជរដ្ឋាភិបាលបាន៖

- កសាងមន្ទីរពេទ្យជាច្រើនដូចជា៖ មន្ទីរពេទ្យកុមារគន្ធបុប្ផា ឱសថាល័យព្រះសុរាម្រឹត មហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យ មន្ទីរសម្ភពផះង៉ាង៉ាម(មន្ទីរពេទ្យព្រះកេតុមាលា) មន្ទីរពេទ្យព្រះកុសុមៈ(ពេទ្យលោកសង្ឃ)
- ចាត់វិធានការការពារ ដោយចាក់ថ្នាំការពាររោគរាតត្បាត ព្រមទាំងរក្សាអនាម័យតាមលំនៅដ្ឋាន ជីកអណ្តូងទឹក សង់ផ្ទះ ជីកស្រះ។

### ការអនុវត្តច្បាប់

- ទប់ស្កាត់អំពើពេស្យាចារ និងបង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគោក
- ផ្តល់សិទ្ធិឱ្យស្ត្រីមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត(៦ មករា ១៩៥៨)។

ការអនុវត្តគោលនយោបាយជាតូបនីយកម្មសេដ្ឋកិច្ចធ្វើឱ្យហិរញ្ញវត្ថុសាធារណៈជាពិសេសថវិកាជាតិជួបនឹងឱនភាព រូបិយវត្ថុជាតិ«ប្រាក់រៀល»បាត់បង់តម្លៃបន្តិចម្តងៗ និងការគ្រប់គ្រងក្រុមហ៊ុនរដ្ឋគ្មានប្រសិទ្ធភាព។ បរិបទនៃសង្គ្រាមត្រជាក់ និងសម្ពាធពីសង្គ្រាមវៀតណាមបានជំរុញឱ្យសម្តេចព្រះនរោត្តមសីហនុចាប់ផ្តើមងាកមករកប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាមេរិកនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ប៉ុន្តែការសម្រេចចិត្តនេះមិនបានធ្វើឱ្យស្ថានភាពនៅកម្ពុជាប្រសើរឡើងឡើយ[47]។

របបសង្គមរាស្ត្រនិយមបានដួលរលំដោយសារវិបត្តិសេដ្ឋកិច្ចវិបត្តិនយោបាយផ្ទៃក្នុងវត្តមានកងទ័ពវៀតណាមខាងជើងលើទឹកដីខ្មែរ និងការប្រឈមគ្នារវាងពួកមហាអំណាចសេរី និងកុម្មុយនីស្តក្នុងបរិបទនៃសង្គ្រាមត្រជាក់ ហើយរបបសាធារណរដ្ឋខ្មែរក៏បានកើតឡើង។

[47] Alain FOREST, Cambodge comptemporain, IRASEC-Les indes savants, 2008, p.68.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មេរៀនទី៣

# សាធារណរដ្ឋខ្មែរ
# ( ១៩៧០-១៩៧៥ )

## I.ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ

### ១. ស្ថានភាពប្រទេសកម្ពុជាមុនព្រឹត្តិការណ៍១៨ មីនា ១៩៧០

**វិស័យសេដ្ឋកិច្ច**

- បញ្ហាកសិកម្ម ៖ ជួបវិបត្តិដោយប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ជាហេតុធ្វើឱ្យទិន្នផលកសិកម្មទាប
- បញ្ហាឧស្សាហកម្ម ៖ រដ្ឋគ្រប់គ្រងឧស្សាហកម្មមិនបានល្អ ហើយការចំណាយខ្វះតុល្យភាព
- បញ្ហាពាណិជ្ជកម្ម ៖ សម្តេច នរោត្តម សីហនុ បានធ្វើជាតូបនីយកម្មក្នុងវិស័យនីហរ័ណ អាហរ័ណផ្នែកសេដ្ឋកិច្ច និងបិទទ្វារធនាគារឯកជនខ្មែរទាំងឡាយ
    - ការធ្វើជាតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេសបានជំរុញឱ្យមានពាណិជ្ជកម្មលួចលាក់ជាមួយពួកបះបោរកុម្មុយនីស្តនៅវៀតណាម
    - ឆ្នាំ១៩៦៧ ផលស្រូវកម្ពុជាមួយភាគបួនត្រូវបានលក់ដោយគេចពន្ធទៅឱ្យកម្លាំងកុម្មុយនីស្តវៀតណាម ព្រោះពួកគេបានឱ្យតម្លៃខ្ពស់ជាងរដ្ឋ

បញ្ហាខាងលើនេះបានធ្វើឱ្យរាជរដ្ឋាភិបាលបាត់បង់ប្រាក់ចំណូល។

- បញ្ហាជំនួយពីបរទេស ៖ ដើម្បីគេចចេញពីសង្គ្រាមនៅវៀតណាមនៅឆ្នាំ១៩៦៣ សម្តេច នរោត្តម សីហនុ បានបដិសេធជំនួយយោធាពីអាមេរិក ដែលមានតម្លៃចំនួន១៥ភាគរយនៃថវិកាជាតិ ឯជំនួយពីប្រទេសចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ។

នៅក្នុងឆ្នាំ១៩៦៧-១៩៦៨ សេដ្ឋកិច្ចរបស់កម្ពុជាមានដំណើរាំងស្ទះ ឯប្រជាប្រិយភាពរបស់សម្តេច នរោត្តម សីហនុក៏មានការថយចុះ។

**ការពង្រឹងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា**

- ក្នុងឆ្នាំ១៩៦៥ សាឡុត ស(ប៉ុល ពត) ទៅវៀតណាមខាងជើងដើម្បីចូលរួមការពិគ្រោះយោបល់
- ក្នុងដំណើរទស្សនកិច្ចនៅប្រទេសចិនឆ្នាំ១៩៦៦ សាឡុត ស បានឃើញបដិវត្តន៍វប្បធម៌ចិន ដែលធ្វើឱ្យគាត់យកគំរូតាម

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ក្រោយពីត្រឡប់មកពីប្រទេសចិនវិញ សាឡុត ស បានតាំងបញ្ជាការដ្ឋាននៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ហើយដាក់ឈ្មោះចលនារបស់ខ្លួនថា បក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក.)ដែលមានមូលដ្ឋាននៅភូមិភាគឦសាន និងពាយ័ព្យ។

នៅដើមឆ្នាំ១៩៧០ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា(ទ័ពរបស់ខ្មែរក្រហម) បានបង្កអសន្តិសុខ និងបានកាន់កាប់ទឹកដីស្មើ១/៥ លើទឹកដីកម្ពុជាទាំងមូល។ ក្នុងពេលនោះ ពួកនិស្សិត និងគ្រូបង្រៀនជាច្រើននៅទីក្រុងភ្នំពេញពេញចិត្តនឹងមនោគមវិជ្ជាថ្មី ដែលជាលទ្ធផលនៃបដិវត្តន៍វប្បធម៌ចិន។

### វិបត្តិផ្ទៃក្នុងរាជរដ្ឋាភិបាល

- នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួន ជាពិសេសទ្រង់ ស៊ីសុវត្ថិ សិរីមតៈបានចាប់ផ្តើមធ្វើផែនការក្បត់សម្តេច នរោត្តម សីហនុ
- ចំណែកលោកលន់ នល់ ដែលជានាយករដ្ឋមន្ត្រីពុំបានជំទាស់នឹងសម្តេច នរោត្តម សីហនុ ចំពោះការបដិសេធជំនួយពីសហរដ្ឋអាមេរិក និងចងសម្ពន្ធភាពជាមួយកុម្មុយនីស្តក្នុងការដឹកជញ្ជូនអាវុធឆ្លងទឹកដីកម្ពុជាទេ។

គេសង្កេតឃើញមន្ត្រីរបស់លោក លន់ នល់ ក្លាយជាអ្នកមានស្តុកស្តម្ភ ដោយសារការរកស៊ីលក់អាវុធ ថ្នាំពេទ្យ និងផ្គត់ផ្គង់គ្រឿងផ្សេងៗដល់កុម្មុយនីស្តវៀតណាម។

នៅឆ្នាំ១៩៦៩ កងខេមរភូមិន្ទរងការវាយប្រហារពីចលនាបះបោររបស់ក្រុមកុម្មុយនីស្ត ហើយប្រជាជនបានប្តឹងពីវត្តមានវៀតណាម។ លោក លន់ នល់មានសុទិដ្ឋិនិយមក្នុងការជួយសង្គ្រោះប្រទេសកម្ពុជាឱ្យផុតពីការឈ្លានពានរបស់ប្រទេសជិតខាង។

## ២. រដ្ឋប្រហារ១៨ មីនា ១៩៧០

### រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ

- ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩ សម្តេចនរោត្តម សីហនុ បានផ្តល់អំណាចឱ្យលោក លន់ នល់ និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ក្នុងការដឹកនាំរាជរដ្ឋាភិបាលដែលមានឈ្មោះថា «រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ»
- នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៩ ព្រះអង្គម្ចាស់ សិរីមតៈ បានកាន់តំណែងជំនួសលោក លន់ នល់។ ក្នុងកំឡុងជាងពីរខែបន្ទាប់មកទៀត អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ និងសហសេវិកបានខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈក្នុងប្រទេសដូចជា៖
    - បិទទ្វារកាស៊ីណូ បង្កើតសេវាសាធារណៈ និងឯកជន
    - ធ្វើឯកជនូបនីយកម្មធនាគារ...

facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### បាតុកម្មប្រឆាំងវៀតណាម

- ថ្ងៃទី៨-៩ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងវៀតណាមខាងជើង និងវៀតកុងដែលបំផុសដោយកងទ័ពនៅខេត្តស្វាយរៀង
- ថ្ងៃទី១១-១៦ខែមីនា ឆ្នាំ១៩៧០ មានកុប្បកម្មវាយកម្ទេច បំផ្លិចបំផ្លាញអគារស្ថានទូតវៀតណាមខាងជើងនិងការិយាល័យរណសិរ្សសេរីកាជាតិវៀតណាមខាងត្បូងនៅក្រុងភ្នំពេញ។

ស្ថានការណ៍ និងភាពចលាចលបានឈានទៅរករដ្ឋប្រហារ។

### រដ្ឋប្រហារ

- ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ព្រឹត្តិការណ៍រដ្ឋប្រហារផ្ទុះឡើងយ៉ាងស្ងៀមស្ងាត់ដឹកនាំដោយលោក លន់ នល់ និងទ្រង់ សិរីមតៈ
- គេរក្សាទុកសភាជាឧបករណ៍ពង្រឹងអំណាច ដោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ដដែល គេបានកោះប្រជុំសភាទាំងពីរដើម្បីបោះឆ្នោតអនុម័ត។ ក្នុងការប្រជុំនោះសំឡេង៨៦ ក្នុងចំណោម៨៩គាំទ្រឱ្យ៖
  - ដកសេចក្តីទុកចិត្ត និងដកសម្តេច នរោត្តម សីហនុចេញពីប្រមុខរដ្ឋ
  - តែងតាំងលោក ចេង ហេង ដែលជាប្រធានសភា ជាប្រមុខរដ្ឋស្តីទីរហូតមានការបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋថ្មី
  - លោក លន់ នល់ បន្តជានាយករដ្ឋមន្ត្រីដដែល ឯអ្នកអង្គម្ចាស់ សិរីមតៈ ជាជំនួយការ។

មុនថ្ងៃរដ្ឋប្រហារ សម្តេចនរោត្តម សីហនុ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ កំឡុងពេលរដ្ឋប្រហារព្រះអង្គនៅបរទេស។

## II.សង្គមសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរ

### ១. សង្គម

### កម្ពុជារងនូវការវាយប្រហារ

- ការវាយប្រហាររបស់សហរដ្ឋអាមេរិក

ពីឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧៣ កម្ពុជារងការទម្លាក់គ្រាប់បែកប្រមាណជាងពីរលានតោនពីសំណាក់សហរដ្ឋអាមេរិក ។

- ការវាយប្រហាររបស់ខ្មែរក្រហម

ចាប់ពីឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានបង្កអសន្តិសុខ និងកាន់កាប់តំបន់ជនបទ និងទីប្រជុំជនតូចៗនៅពាសពេញផ្ទៃប្រទេស។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាប់ពីឆ្នាំ១៩៧២ ពួកខ្មែរក្រហមបានចាប់ផ្ដើមផ្ដោតទៅលើទីប្រជុំជនធំៗ ដោយបាញ់ផ្លោងចូលភ្នំពេញ និងកម្ទេចស្ពានជ្រោយចង្វារ...។

### ស្ថានភាពប្រជាពលរដ្ឋ

ការទម្លាក់គ្រាប់បែក ការបាញ់ផ្លោង ការបាញ់រះ ការបាញ់ផ្ដក់រវាងភាគីជម្លោះកម្ពុជាបានធ្វើឱ្យប្រជាជននាំគ្នាភៀសខ្លួនមករស់នៅទីរួមខេត្ត និងទីក្រុងភ្នំពេញ។

ក្នុងអំឡុងសង្គ្រាម៥ឆ្នាំ ក្រុងភ្នំពេញដូចជាបន្ទាយមួយដែលត្រូវខ្មាំងឡោមព័ទ្ធ និងបានជួបនូវ ៖

- កំណើនប្រជាជនហួសប្រមាណ ព្រោះប្រជាជន១/៣ ភៀសខ្លួនមកកាន់ទីក្រុង
- ប្រជាជនរងទុក្ខលំបាកវេទនា និងកំសត់ទុរគត ព្រោះខ្វះស្បៀង ម្ហូបអាហារឡើងថ្លៃហួសប្រមាណ...
- អ្នកស្រែចម្ការដែលឃ្លាតពីភូមិស្រុកបាត់បង់មុខរបរ គ្មានការងារធ្វើ ព្រាត់ប្រាសគ្រួសារ...
- សង្គ្រាមបានបន្សល់នូវស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នកមានជំងឺ អ្នករបួស ជនពិការជាច្រើនសែននាក់។

ក្រុងភ្នំពេញដែលធ្លាប់តែធើតឆាយ និងជាគជ់នៅអាស៊ីអាគ្នេយ៍បានក្លាយជាទីប្រជុំជនដែលមានប្រជាជនជាងពីរលាននាក់រស់នៅយ៉ាងលំបាកតោកយ៉ាកបំផុត។

### ២. ស្ថានភាពសេដ្ឋកិច្ច

ក្នុងកំឡុងពេលសង្គ្រាម សេដ្ឋកិច្ចនៅទ្រឹងគ្មានសកម្មភាព និងជួបនូវ ៖

- ជនភៀសខ្លួនគ្មានការងារធ្វើ និងជួបប្រទះនូវកង្វះស្បៀងអាហារប្រចាំថ្ងៃ
- អតិផរណាប្រាក់រៀលចេះតែបន្ត
- តម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត។

ដើម្បីផ្គត់ផ្គង់ទីក្រុងភ្នំពេញ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរពឹងផ្អែកលើស្បៀងមួយចំនួន ដែលរដ្ឋាភិបាលអាមេរិកផ្ដល់ឱ្យដោយដឹកតាមកងនាវាតាមដងទន្លេមេគង្គ។ ប៉ុន្តែនៅខែមករា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាត់ផ្ដាច់ស្បៀងដែលឡើងតាមដងទន្លេ ដូច្នេះគឺនៅសល់តែផ្លូវអាកាសប៉ុណ្ណោះ។

## III.សង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្ដេច នរោត្តម សីហនុបានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុង កង់តុង ប្រទេសចិន នៅថ្ងៃទី២៣ មីនា ១៩៧០ ចំណែកឯក្រុមរបស់លោក លន់ នល់ ក៏បានប្រកាសរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ ។

រដ្ឋាភិបាលសាធារណរដ្ឋខ្មែរបានបន្តរស់ក្នុងរយៈពេល៤ឆ្នាំ ដោយសារជំនួយយោធា និងសេដ្ឋកិច្ចពីអាមេរិក។ ប្រទេសជួបសង្គ្រាម និងពោរពេញដោយអំពើហិង្សានិងទុក្ខក្រៀមក្រំ ព្រមទាំងជួបស្ថានភាពជាច្រើនទៀតដូចជា ៖

- សេដ្ឋកិច្ចជាតិត្រូវរាំងស្ទះដោយសង្គ្រាម



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ទីក្រុង និងទីប្រជុំជនមួយចំនួនធំត្រូវកាត់ផ្ដាច់ពីគ្នាដោយកម្លាំងខ្មែរក្រហម
- រដ្ឋាភិបាលលន់ នល់គ្រប់គ្រងបានតែទីក្រុង និងទីប្រជុំជនមួយចំនួន

ដោយស្ថានភាពជំងឺ(ស្លាប់មួយចំហៀងខ្លួននៅឆ្នាំ១៩៧១) លោក លន់ នល់ មិនអាចគ្រប់គ្រងនយោបាយដូចមុនឡើយ។ គេសង្កេតឃើញថា៖

- ឥស្សរជននយោបាយច្រើនរូបនៅភ្នំពេញបង្កើតបក្សពួក និងប្រមូលទ្រព្យសម្បត្តិ ភ្លេចប្រយោជន៍ជាតិ ក្នុងនោះក៏មានលោកលន់ ណុន (ប្អូនប្រុស លន់ នល់) ដែរ
- នាយទាហានខ្លះលក់យុទ្ធោបករណ៍ឱ្យពួកខ្មែរក្រហម។

បញ្ហាខាងលើធ្វើឱ្យលោក លន់ នល់ អល់អែកក្នុងការដាក់ទណ្ឌកម្មលើទាហាន និងមន្ត្រីពុករលួយដែលមានស្វាមីភក្ដិចំពោះលោក។

នៅដើមឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានពិសោធសហករណ៍បនីយកម្ម និងអនុវត្តដោយបង្ខំក្នុងតំបន់មួយចំនួនដែលពួកគេគ្រប់គ្រង ស្របពេលដែលសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក។

## IV.ការដួលរលំរបបសាធារណរដ្ឋខ្មែរ

### ១. ដំណាក់កាលចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ

- ប្រជាជនតំបន់រំដោះ និងក្រុងភ្នំពេញនឿយណាយនឹងរបបសាធារណរដ្ឋខ្មែរដែលប្រកបដោយអំពើពុករលួយ និងពោរពេញដោយភាពអាប់អួរ
- ប្រជាជនភៀសសឹកមកកាន់ទីក្រុងភ្នំពេញដែលកើនប្រមាណពីរលាននាក់រស់នៅដោយបាត់បង់ការងារ ខ្វះស្បៀងអាហារ...
- ទំនិញឡើងថ្លៃ
- ការដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវរបស់សហរដ្ឋអាមេរិកមកឧបត្ថម្ភប្រជាជនក្រុងភ្នំពេញ និងរបបលន់ នល់ ត្រូវខ្មែរក្រហមកាត់ផ្ដាច់ទាំងស្រុង
- នៅដើមខែមេសា ឆ្នាំ១៩៧៥ លោកលន់ នល់ បានភៀសខ្លួនតាមយន្តហោះចេញពីកម្ពុជា និងទៅរស់នៅសហរដ្ឋអាមេរិក
- ពួកខ្មែរក្រហមបានធ្វើការរឹតបន្តឹងការឡោមព័ទ្ធទីក្រុងភ្នំពេញ ពិសេសការនាំស្បៀងចូល
- ការចរចារវាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ និងរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាដឹកនាំដោយសម្ដេច នរោត្ដម សីហនុពុំទទួលបានលទ្ធផល។

ក្នុងដំណាក់កាលចុងក្រោយ សាឡុត ស បានសម្រេចចិត្តដណ្ដើមយកក្រុងភ្នំពេញ ដោយមិនចាំបាច់រង់ចាំការយល់ព្រមពីសម្ពន្ធមិត្តវៀតណាម ប្រកបដោយជោគជ័យថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២. ជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥

នៅវេលាម៉ោង៩និង៣០នាទីព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទ័ពខ្មែរក្រហមបានដើរជាជួរចូលមកក្រុងភ្នំពេញដោយ ៖

- ស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ និងពណ៌អាចម៍សេះ
- ប្រុងប្រយ័ត្ន និងមានអាវុធគ្រប់ៗគ្នា
- ភាគច្រើនមានអាយុពី១៥ឆ្នាំឡើង
- មានទឹកមុខមាំមិនរីករាយនឹងការស្វាគមន៍ពីប្រជាជន។

ជ័យជម្នះនេះមិនមែនជាការចែជន្យទេ។ ពួកខ្មែរក្រហមមានគំនិតថា ឆ្នាំខាងមុខចាត់ទុកដូចជាឆ្នាំទីមួយនៃបដិវត្តន៍ ហើយកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយបដិវត្តន៍នៅក្នុងប្រទេសវៀតណាម។

## V.ការខូចខាតដោយសារសង្គ្រាម និងផលវិបាក

សង្គ្រាមស៊ីវិលឆាបឆេះអស់រយៈពេល៥ឆ្នាំ(១៩៧០-១៩៧៥) ដែលបង្កនូវការខូចខាត និងផលវិបាកដូចតទៅ ៖

### សង្គម

- សង្គ្រាមបានសម្លាប់ប្រជាជនកម្ពុជាជាងមួយលាននាក់ ព្រមទាំងបន្សល់ទុកនូវអ្នករបួស ជនពិការ ក្មេងកំព្រា ស្ត្រីមេម៉ាយ...
- ប្រជាជនភៀសខ្លួនពីជនបទចូលទីក្រុង រស់ដោយខ្វះស្បៀង ជួបភាពអនាធិបតេយ្យ អំពើហិង្សា ចោរកម្ម...
- អំពើសុកប៉ាន់រីកដុះដាលដល់វិស័យសិក្សាធិការ
- បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម លំនៅដ្ឋាន...

### សេដ្ឋកិច្ច

- ដីស្រែចម្ការត្រូវបោះបង់ចោល ព្រមទាំងក្លាយទៅជាចម្ការមីន និងរណ្តៅគ្រាប់ B ៥២
- រោងចក្រឧស្សាហកម្ម៧៥ភាគរយ ត្រូវបំផ្លិចបំផ្លាញ
- ចម្ការកៅស៊ូត្រូវបាត់បង់
- ផ្លូវថ្នល់ និងស្ពានពី៧០ភាគរយ ទៅ៨០ភាគរយត្រូវអន្តរាយ។

### នយោបាយ

អស្ថិរភាពនយោបាយដោយសង្គ្រាមស៊ីវិល បានបង្កវិនាសកម្មលើគ្រប់វិស័យដែលជាឱកាសឱ្យខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។

ដូចនេះសង្គ្រាមបានបង្កមហន្តរាយ និងបំផ្លាញហេដ្ឋារចនាសម្ពន្ធ គ្រឹះសេដ្ឋកិច្ច សង្គម និងនាំកម្ពុជាទៅរកបេបប្រល័យពូជសាសន៍។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មេរៀនទី៤

# កម្ពុជាប្រជាធិបតេយ្យ
# (១៩៧៥-១៩៧៩)

## I .របបនាសម្ពន្ធដឹកនាំ

### ១. ការចូលកាន់អំណាចរបស់ខ្មែរក្រហម

#### ការចូលកាន់កាប់ទីក្រុងភ្នំពេញ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយលុកចូលទីក្រុងភ្នំពេញពីគ្រប់ទិសទី។ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ ក្រោមលេសថា អង្គការខ្លាចអាមេរិកមកទម្លាក់គ្រាប់បែក ចង់បោសសម្អាតខ្មាំង និងខ្វះមធ្យោបាយដឹកស្បៀងឱ្យប្រជាជននៅក្នុងក្រុងភ្នំពេញ។ អ្នករឹងទទឹងនឹងបញ្ជាអង្គការនឹងត្រូវចាប់ចង ឬបាញ់ចោលភ្លាមៗនៅនឹងកន្លែង។

#### គោលការណ៍របស់ពួកខ្មែរក្រហម

នៅថ្ងៃទី២០ ដល់២៥ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំការប្រជុំធំមួយ និងបានប្រកាសគោលការណ៍៨ចំណុចសម្រាប់ការអនុវត្តនៅទូទាំងប្រទេស។ គោលការណ៍ទាំងនោះរួមមាន ៖

- ជម្លៀសប្រជាជនឱ្យចេញពីទីប្រជុំជនទាំងអស់ ជាពិសេសពីទីក្រុងភ្នំពេញ
- លុបបំបាត់ទីផ្សារ
- លុបបំបាត់ការប្រើប្រាស់រូបិយប័ណ្ណ
- ផ្សឹកលោកសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឱ្យទៅធ្វើស្រែចម្ការនៅតំបន់មូលដ្ឋានជនបទ
- ប្រហារជីវិតមេដឹកនាំរបស់របប លន់ នល់
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
- បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់
- បញ្ជូនទ័ពទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម។

### ២. ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

#### អង្គការ

ពាក្យអង្គការមួយម៉ាត់គ្របដណ្តប់ទាំងបក្សកុម្មុយនីស្ត ទាំងអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ អង្គការបដិវត្តន៍ត្រូវបានបង្កើតឡើងដោយសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ នៅខែ

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កញ្ញា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជារួមមាន ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី, សុន សេន, ឈិត ជឿន(ហៅតាម៉ុក) និងវន វ៉េត។

## រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

- ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ មហាសន្និបាតជាតិប្រារព្ធឡើងនៅភ្នំពេញ ដែលមានសមាជិកចូលរួមចំនួន១ ០០០នាក់ និងបានអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ
- ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ រដ្ឋធម្មនុញ្ញត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយមាន១៦ជំពូក និងចែកចេញជា២១មាត្រា
- តាមរយៈរដ្ឋធម្មនុញ្ញនេះ កម្ពុជាត្រូវបានប្តូរឈ្មោះជាផ្លូវការថា «កម្ពុជាប្រជាធិបតេយ្យ»
- រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជនចំនួន២៥០អាសនៈ ដែលក្នុងនោះ១៥០អាសនៈតំណាងវណ្ណៈកសិករ ៥០អាសនៈតំណាងវណ្ណៈពលករនិងកម្មករ និង៥០អាសនៈតំណាងកងទ័ពបដិវត្តន៍កម្ពុជា

  ចម្រៀងជាតិកម្ពុជាប្រជាធិបតេយ្យមានឈ្មោះថា «១៧ មេសា មហាជោគជ័យ»។

## របនាសម្ពន្ធគ្រប់គ្រងរដ្ឋ

- បក្សកុម្មុយនីស្តកម្ពុជាគឺជាអង្គការតែមួយគត់ ដែលមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
- បក្សនេះមានប៉ុល ពត(សាឡុត ស) ជាលេខាបក្ស[48] និងនួន ជា ជាអនុលេខាបក្ស
- គណៈកម្មាធិការអចិន្ត្រៃយ៍បក្សគឺជា«អង្គការ»តែមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តអនុម័តគោលនយោបាយរដ្ឋាភិបាល និងលក្ខន្តិកៈផ្សេងៗ។

## ៣. ភូមិសាស្ត្ររដ្ឋបាល

- បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកតំបន់រដ្ឋបាលនៃរដ្ឋកម្ពុជាប្រជាធិបតេយ្យជា៧ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគទាំងនោះរួមមាន ៖ ភូមិភាគបូព៌ា(ភូមិភាគ២០៣) ភូមិភាគនិរតី(ភូមិភាគ៤០៥) ភូមិភាគឧត្តរ(ភូមិភាគ៣០៣) ភូមិភាគពាយ័ព្យ(ភូមិភាគ៥៦០) ភូមិភាគបស្ចិម(ភូមិភាគ៤០១) ភូមិភាគឦសាន(ភូមិភាគ១០៨)[49] ហើយនៅឆ្នាំ១៩៧៧ ភូមិភាគកណ្តាលត្រូវបានបង្កើតឡើង ដែលមានទីតាំងនៅត្រង់ភូមិភាគឧត្តរចាស់ ហើយភូមិភាគឧត្តរត្រូវបានប្តូរទៅកាន់តំបន់សៀមរាប-ឧត្តរមានជ័យ និងតំបន់ព្រះវិហារវិញ។

---

[48] ប្រធានបក្ស។

[49] មកដល់ឆ្នាំ១៩៧៥ ភ្នំពេញត្រូវគេហៅថា ភូមិភាគពិសេស។ ចាប់ពីឆ្នាំ១៩៧៧ ភូមិភាគពិសេសគឺសំដៅលើ៖ កំពង់ធំ និងកំពង់ចាមត្រើយខាងលិចដងទន្លេមេគង្គ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ភូមិភាគ តំបន់ និងស្រុកមួយចំនួនត្រូវបានដាក់លេខសម្គាល់
- នៅក្រោមភូមិភាគ មានតំបន់ស្រុក ឃុំ(សហករណ៍កម្រិតខ្ពស់) និងភូមិ(សហករណ៍កម្រិតទាប)។

## II. នយោបាយមហាលោតផ្លោះមហាអស្ចារ្យ

### ១. គម្រោងផែនការបួនឆ្នាំ(១៩៧៧-១៩៨០)

### គោលនយោបាយ

គោលនយោបាយសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យគឺសន្តិសុខជាតិ និងសមូហភាវូបនីយកម្ម។

នៅក្នុងគម្រោងផែនការបួនឆ្នាំ អង្គការបានអនុវត្តនយោបាយសមូហភាវូបនីយកម្ម ដោយប្រមូលយកទ្រព្យសម្បត្តិឯកជនទាំងអស់(រួមទាំងសម្ភារផ្ទះបាយ)ទុកជាសម្បត្តិសមូហភាពនិងប្រើប្រាស់រួម និងបែងចែកកម្លាំងពលកម្មទៅតាមក្រុមរៀងៗខ្លួនទៅតាមអាយុ ភេទ និងវណ្ណៈសង្គម ដូចជា បុរស ស្ត្រី យុវជន កុមារ។

តាមរយៈផែនការនេះ ខ្មែរក្រហមក្រហមចង់ឱ្យប្រទេសកម្ពុជារីកចម្រើន ក្លាយជាប្រទេសសង្គមកសិកម្មទំនើបក្នុងរយៈពេល១០ ទៅ១៥ឆ្នាំ ហើយក្លាយជាសង្គមឧស្សាហកម្មមួយក្នុងរយៈពេល១៥ ទៅ២០ឆ្នាំ[50]។

### គោលដៅ

- គោលដៅរបស់ផែនការបួនឆ្នាំ គឺធ្វើយ៉ាងណាឱ្យទទួលបានលទ្ធផលស្រូវជាមធ្យមបីតោនក្នុងមួយហិកតាសម្រាប់ដីស្រែធម្មតា និងពី៦ទៅ៧តោនក្នុងមួយហិកតាសម្រាប់ដីស្រែលេខ១ ដែលអាចធ្វើស្រូវបានពីរដងក្នុងមួយឆ្នាំ។
- ទិន្នផលស្រូវក្នុងផែនការបួនឆ្នាំចែកជាបួនចំណែកគឺ ៖
  - សម្រាប់ជាស្បៀងរបស់ប្រជាជន
  - សម្រាប់ធ្វើពូជ
  - សម្រាប់បម្រុងទុក
  - សម្រាប់នាំចេញទៅក្រៅប្រទេស ហើយនាំចូលមកវិញនូវម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ គ្រឿងសញ្ញាវុធ និងសម្ភារប្រើប្រាស់ផ្សេងៗ

មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថានឹងធ្វើឱ្យកម្ពុជាមានឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនឧបត្ថម្ភខ្លួនទាំងសេដ្ឋកិច្ចនិងនយោបាយ ព្រមទាំងប្រែក្លាយវិស័យកសិកម្មអន់ថយឱ្យទៅជាវិស័យកសិកម្មបែបទំនើប។

[50] ទស្សនាវដ្ដីទង់បដិវត្តលេខ ៣៩ ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៦។



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ការបង្កើតសហករណ៍

- សហករណ៍ខ្មែរក្រហមមានន័យថា ប្រជាជនរស់នៅរួម ធ្វើការរួម ហូបរួម និងចែករំលែកការកំសាន្ត ជាសមូហភាព គ្មានការរស់នៅជាបុគ្គល និងគ្មានកម្មសិទ្ធិឯកជន
- សហករណ៍ត្រូវបានបង្កើតឡើងដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ ដោយឆ្ពោះទៅរកការលុបបំបាត់កម្មសិទ្ធិឯកជន និងរបបទាំងឡាយដែលមិនមែនសង្គមនិយម
- សហករណ៍ខ្មែរក្រហម គឺធ្វើយ៉ាងណាឱ្យខ្លួនអាចឧបត្ថម្ភខ្លួនដោយខ្លួនឯងបាន (ឯករាជម្ចាស់ការ)
- ការរៀបចំសហករណ៍មាន៣ដំណាក់កាល ៖
  - នៅអំឡុងឆ្នាំ១៩៧០-១៩៧៥ ខ្មែរក្រហមបានរៀបចំប្រជាជននៅតំបន់រំដោះជា«ក្រុមប្រវាស់ដៃ» មានសមាជិកពី១០ទៅ៣០គ្រួសារ
  - បន្ទាប់ពីបានជ័យជម្នះនៅឆ្នាំ១៩៧៥ ក្រុមប្រវាស់ដៃត្រូវរៀបចំជា«សហករណ៍កម្រិតទាប» ដែលមានសមាជិកច្រើនគ្រួសារ ឬមួយភូមិទាំងមូល
  - នៅឆ្នាំ១៩៧៧ សហករណ៍កម្រិតទាប ត្រូវរៀបចំជាសហករណ៍កម្រិតខ្ពស់ ដែលមានគ្រួសារចាប់ពី៣ ទៅ៤ភូមិ ឬឃុំមួយទាំងមូល។

### វណ្ណៈសង្គមថ្មីពីរ

ខ្មែរក្រហមបានបង្កើតនូវវណ្ណៈថ្មីពីរ គឺ«ប្រជាជនចាស់» និង«ប្រជាជនថ្មី» ៖

- ប្រជាជនចាស់ (ប្រជាជនមូលដ្ឋាន) គឺប្រជាជនដែលរស់នៅតាមជនបទ គ្រប់គ្រងដោយបក្សកុម្មុយ-នីស្តកម្ពុជាមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រជាជនប្រភេទនេះអាចក្លាយជាប្រធានសហករណ៍ ឬប្រធានកងផ្សេងៗ។
- ប្រជាជនថ្មី (ប្រជាជន១៧មេសា) ជាប្រជាជនដែលជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានា ក្រោយថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥។ អង្គការគ្មានទំនុកចិត្តលើប្រជាជនថ្មីនេះទេ ព្រោះអង្គការចាត់ទុកថា ពួក១៧ មេសាជាជនបញ្ញើក្អែក ជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក។ អ្នកដែលនៅរស់បានចងចាំនូវពាក្យស្លោក«ទុកក៏មិនចំណេញ ដកចេញក៏មិនខាត»។

### ពិធីរៀបមង្គលការ ឬអាពាហ៍ពិពាហ៍

ពិធីរៀបការនៅក្នុងរបបខ្មែរក្រហមមានលក្ខណៈខុសពីប្រពៃណីទាំងស្រុង។ ពិធីរៀបការតម្រូវឱ្យកូនប្រុស-ស្រីឈរឬអង្គុយជាពីជួរ ហើយគូនីមួយៗបែរមុខរកគ្នា ដែលមានចាប់ពី៣ ទៅ១០គូសម្រាប់ពិធីតូច ឬពី៣០ ទៅ៥០គូ និងឈានទៅដល់ជាង១០០គូសម្រាប់ពិធីធំ។ បន្ទាប់មកប្រធានអង្គប្រជុំបញ្ជាឱ្យគូទាំងនោះចាប់ដៃគ្នា ធ្វើការប្ដេជ្ញាចិត្តថានឹងរួមរស់ជាមួយគ្នា និងបម្រើអង្គការអស់មួយជីវិត។ គូស្រករមួយចំនួនមិនបានស្គាល់ ឬស្រឡាញ់គ្នាពីមុនមកនោះទេ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ការអប់រំ

ប្រព័ន្ធអប់រំត្រូវបានបំផ្លាញចោល សាលារៀនត្រូវបានបិទទ្វារ គ្រូបង្រៀនត្រូវបានរំលាយក្របខណ្ឌ ហើយអង្គការអប់រំកុមារា កុមារីទាំងអស់ដែលត្រូវចាត់ទុកជាកូនអង្គការឱ្យ៖

- ស្រឡាញ់ និងដឹងគុណអង្គការតែមួយគត់
- មានឆន្ទៈដាច់ខាត និងជឿជាក់លើអង្គការតែមួយគត់
- យកការណ៍ពីឪពុកម្ដាយរបស់ខ្លួន ហើយពេលខ្លះកុមារហ៊ានសម្លាប់ឪពុកម្ដាយរបស់ខ្លួនដោយចោទថាខ្មាំង
- ហ៊ានធ្វើពលីកម្មគ្រប់យ៉ាងចំពោះអង្គការ។

ប្រព័ន្ធអប់រំកម្ពុជាប្រជាធិបតេយ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះកុមារ។ សម័យនោះ កុមារត្រូវចែកតាមកង និងបង្ខំឱ្យធ្វើការដូចជា រើសអាចម៍គោ កាត់ទន្រ្ទានខេត្ត ប្រមូលជីលាមកមនុស្ស ជញ្ជូនសម្ភារសឹកទៅសមរភូមិ។ល។ កុមារមួយចំនួនត្រូវបានជ្រើសរើសឱ្យចូលបម្រើក្នុងជួរកងទ័ពរបស់ខ្មែរក្រហម។

## III. សោកនាដកម្ម

### ១. ការបង្ខំឱ្យធ្វើការជាទម្ងន់

- ប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការជាង១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ ដោយគ្មានពេលសម្រាកគ្រប់គ្រាន់ ហើយទទួលបានរបបអាហារតិចតួចបំផុត
- ប្រធានសហករណ៍ មានភារកិច្ចគ្រប់គ្រងសកម្មភាព និងទង្វើរបស់ប្រជាជន
- ជនណាមានកំហុស ឬត្រូវបានចោទថាជាខ្មាំងប្រឆាំងបដិវត្តន៍ និងត្រូវបញ្ជូនទៅដាក់គុក ឬសម្លាប់ចោល។

### ២. ការសម្រិតសម្រាំង និងការសម្លាប់រង្គាល

- ខ្មែរក្រហមតែងតែស្រាវជ្រាវរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងគ្រប់ទីកន្លែង
- ប្រជាជនជាច្រើនត្រូវស្លាប់ដោយការចោទថាជាភ្នាក់ងារសម្ងាត់របស់អាមេរិក(សេ.អ៊ី.អា) ភ្នាក់ងារសម្ងាត់របស់សូវៀត(កា.ហ្សេ.បេ)និងភ្នាក់ងារសម្ងាត់របស់វៀតណាម។ ប្រជាជនទាំងនេះត្រូវបានចាប់ខ្លួន និងសម្លាប់ចោលជាប្រព័ន្ធ
- នៅឆ្នាំ១៩៧៨ មានការសម្រិតសម្រាំងដ៏សាហាវយង់ឃ្នងបំផុតទៅលើប្រជាជននិងកម្មាភិបាលនៅភូមិភាគបូព៌ា។ ខ្មែរក្រហមបានចោទកម្មាភិបាល និងប្រជាជននៅក្នុងភូមិភាគនេះថាជាមនុស្ស «ក្បាលយួន ខ្លួនខ្មែរ»។ កម្ពុជាប្រជាធិបតេយ្យបានបញ្ជូនទ័ពពីភូមិភាគនិរតីទៅបង្ក្រាបភូមិភាគបូព៌ា ហើយដាក់កម្មាភិបាលពីភូមិភាគនិរតី ទៅកាន់អំណាចជំនួសកម្មាភិបាលនៅភូមិភាគបូព៌ា ដែលធ្វើ

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យមានការសម្លាប់ប្រជាពលរដ្ឋជាងមួយសែននាក់។ ប្រជាជនរាប់ពាន់នាក់ទៀតបានគេចទៅវៀតណាម។

## ៣. ប្រព័ន្ធសន្តិសុខ

### មន្ទីរសន្តិសុខ

- ប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហម គឺគុកសម្រាប់ដាក់មនុស្ស ដែលគុកទាំងនោះគេហៅថា មន្ទីរសន្តិសុខ
- នៅទូទាំងប្រទេសមានមន្ទីរសន្តិសុខជិត២០០កន្លែងសម្រាប់ឃុំឃាំង សួរចម្លើយ និងសម្លាប់មនុស្ស
- អ្នកទោសភាគច្រើនគឺជាប្រជាជនស្លូតត្រង់ ដែលត្រូវបានចោទប្រកាន់ដោយគ្មានភស្តុតាងថាជាអតីតទាហាន និងមន្ត្រីរាជការស៊ីវិលរបស់របបលន់ នល់ ជាភ្នាក់ងារស៊ើបការសម្ងាត់ ឬជាខ្មាំងជាដើម។

### មន្ទីរស-២១(គុកទួលស្លែង)

- អក្សរ«ស»តំណាងឱ្យពាក្យសន្តិបាលហើយលេខ«២១»តំណាងឱ្យលេខសម្ងាត់
- មន្ទីរនេះមានទីតាំងស្ថិតនៅក្នុងវិទ្យាល័យទួលស្វាយព្រៃ(អតីតវិទ្យាល័យពញាយ៉ាត)។
- មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមនៅភ្នំពេញ និងជាគុកដែលសំខាន់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទីនេះជាគុកសម្ងាត់សម្រាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសប្រមាណ១៤ ០០០នាក់។
- អ្នកទោសភាគច្រើននៅមន្ទីស-២១ជាកម្មាភិបាល និងកងទ័ពខ្មែរក្រហម ដែលត្រូវបានចោទថាក្បត់បដិវត្តន៍។

### ថ្នាក់ដឹកនាំមន្ទីរស-២១

- មន្ទីរស-២១ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ដឹកនាំដោយលោកសុន សេន ហៅសមមិត្តខៀវ
- កាំង ហ្គេចអ៊ាវ ហៅឌុច ជាប្រធាន, ឃឹម វ៉ាត ហៅ ហ៊ អនុប្រធាន, ប៉េង បញ្ជាការលើអ្នកយាម, ចាន់ ប្រធានអង្គភាពសួរចម្លើយ និង ប៉ុន អ្នកសួរចម្លើយ
- កម្មាភិបាលមន្ទីរស-២១មួយចំនួនជាអតីតគ្រូបង្រៀន។

### វេចនាសម្ពន្ធចាត់តាំងនៅក្នុងស-២១

មន្ទីរស-២១មានបុគ្គលិកប្រមាណជាង១ ០០០នាក់ក្នុងនោះ៖

- ប្រមាណ៣០០-៤០០នាក់បម្រើការជាបុគ្គលិកទូទៅ អ្នកដាំស្ល ដាំបន្លែ...សម្រាប់បម្រើតម្រូវការក្នុងគុក។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **អង្គភាពរៀបចំឯកសារ**មានតួនាទីចម្លងចម្លើយសារភាពចេញពីកាសែ្សត វាយអត្ថបទចម្លើយសារភាព សង្ខេបអត្ថបទចម្លើយសារភាព និងរៀបចំទុកដាក់ឯកសារ។ ក្នុងនោះក៏មានអង្គភាពរងផ្នែកថតរូបដែរ
- **អង្គភាពការពារ**ជាអង្គភាពធំបំផុតនៅមន្ទីរស-២១។ អង្គភាពនេះភាគច្រើនជាក្មេងជំទង់ដែលត្រូវគោរពបទបញ្ជាដ៏តឹងរឹង
- **អង្គភាពសួរចម្លើយ**ចែកចេញជាក្រុមរងក្តៅ(ហៅកងកាច) ក្រុមរងត្រជាក់(ហៅកងស្លូត) និងក្រុមអង្កៀម។

## ខ្មាំងរបស់អង្គការ

ខ្មែរក្រហមបានបែងចែកសត្រូវជាពីរប្រភេទ គឺសត្រូវខាងក្នុង និងសត្រូវខាងក្រៅ៖

- **សត្រូវខាងក្នុង** ៖ គឺជាប្រជាជនថ្មី ឬប្រជាជន១៧មេសា និងអ្នកធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្លាប់ចាប់ពីមន្ត្រីជាន់ខ្ពស់ នាយទាហានដល់កូនទាហានរបស់របបចាស់ ព្រមទាំងក្រុមគ្រួសារ។ ក្រុមជនជាតិភាគតិចក៏ត្រូវបានធ្វើទុក្ខបុកម្នេញ និងសម្លាប់ចោលដែរ ដោយត្រូវចោទថាជាខ្មាំងរបស់អង្គការ។ នៅទីបញ្ចប់កម្មាភិបាលខ្មែរក្រហមជាច្រើននាក់ត្រូវបានចោទថាជាខ្មាំងក្បត់បដិវត្តន៍ និងត្រូវបានកម្ទេចចោល។
- **សត្រូវខាងក្រៅ៖** រួមមានសហរដ្ឋអាមេរិក ថៃ ពិសេសវៀតណាម និងសូវៀត និងសម្ពន្ធមិត្តរបស់ប្រទេសទាំងនេះ។ ខ្មែរក្រហមបានចោទប្រជាជន កម្មាភិបាល និងកងទ័ពរបស់ខ្លួនជាច្រើន ថាបានបម្រើមនោគមវិជ្ជាប្រតិកិរិយាប្រឆាំងបដិវត្តន៍ជា«ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» និងបម្រើនយោបាយបរទេស។ អ្នកទាំងនេះត្រូវបានកម្ទេចចោល។

## IV.ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

មានមូលហេតុជាច្រើនដែលបណ្តាលឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។

### ១. ការស្អប់ខ្ពើមរបបប៉ុលពតរបស់ប្រជាជនកម្ពុជា

ការអនុវត្តផែនការផលិតស្រូវបីតោនក្នុងមួយហិចតាពុំបានជោគជ័យទេ។ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមបានធ្វើរបាយការណ៍ក្លែងក្លាយ និងបញ្ជូនស្រូវតាមផែនការកំណត់ទៅមជ្ឈិម។ មេដឹកនាំមជ្ឈិមតែងជឿលើរបាយការណ៍ ឯថ្នាក់ក្រោមមិនហ៊ានរាយការណ៍ព័ត៌មានមិនល្អ ហើយតំបន់នីមួយៗមិនអនុញ្ញាតឱ្យរំលែកព័ត៌មានគ្នា។ ប្រជាជនទទួលរងគ្រោះអត់ឃ្លាន សុខភាពទ្រុឌទ្រោម និងស្លាប់ដោយកង្វះអាហារ។ ជាងនេះទៅទៀត ប្រជាជនធ្វើការងារហួសកម្លាំង និងរងនូវការកាប់សម្លាប់។ លក្ខខណ្ឌទាំងនេះធ្វើឱ្យប្រជាជនអស់ជំនឿទៅលើរបបកម្ពុជាប្រជាធិបតេយ្យ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២. ការសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធ

នៅពាក់កណ្តាលឆ្នាំ១៩៧៦ មានការសម្រិតសម្រាំងយកមនុស្សបដិវត្តន៍បរិសុទ្ធក្នុងចំណោមសមាជិកសំខាន់ៗនៃបក្សកុំម្មុយនីស្តកម្ពុជា ដែលធ្វើឱ្យមានការបែកបាក់ផ្ទៃក្នុងជាពិសេសក្នុងជួរអ្នកដឹកនាំបក្ស។

## ៣.ការធ្វើសង្គ្រាមជាមួយវៀតណាម

នៅឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមបង្កជម្លោះតាមព្រំដែនជាមួយវៀតណាម។ ចាប់ពីដើមឆ្នាំរហូតពាក់កណ្តាលឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមបានវាយប្រហារទៅលើខេត្តចូវដុក ស្រុកហាទៀង និងខេត្តផ្សេងៗទៀតរបស់វៀតណាម។ នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមប្រើយន្តហោះ និងកាំភ្លើងធំបើកការវាយប្រហារជាទ្រង់ទ្រាយធំ រហូតកាន់កាប់បានតំបន់ចំពុះទាក្នុងខេត្តស្វាយរៀង។ ពេលនោះកម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងការទូតជាមួយវៀតណាម។

## ៤. កំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្តបួនរូប បានសម្រេចចិត្តភៀសខ្លួនចេញពីកម្ពុជាប្រជាធិបតេយ្យឆ្ពោះទៅកាន់ប្រទេសវៀតណាម ដើម្បីស្វែងរកការគាំទ្រវាយរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងរំដោះប្រជាជននិងប្រទេសជាតិពីរបបនេះ។ ដំណើរភៀសខ្លួនជាប្រវត្តិសាស្ត្រនេះ គឺជាការយកជីវិតធ្វើជាដើមទុន ដើម្បីប្តូរមកវិញនូវអាយុជីវិត សិទ្ធិ និងសេរីភាពរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស។ ដោយមានការគាំទ្រពីខ្មែរអ្នកស្នេហាជាតិ និងវៀតណាម សមមិត្ត ហ៊ុន សែន បានបង្កើតចលនាតស៊ូមួយដែលមានឈ្មោះថាអង្គភាព១២៥ ឬកងទ័ពសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។ ការបង្កើតអង្គភាពនេះគឺជាចំណុចចាប់ផ្តើមដំបូងបង្អស់នៃចលនាតស៊ូរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយផ្សាយជាភាសាខ្មែរ បានអំពាវនាវឱ្យប្រជាជនក្រោកឈរប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យ។ ពេលនោះ កម្មាភិបាល កងទ័ព ប្រជាជន បានស្ម័គ្រចិត្តចូលបម្រើទ័ព។ ចលនាតស៊ូខ្មែរផ្សេងទៀតក៏ត្រូវបានបង្កើតឡើងបន្តបន្ទាប់គ្នា ដូចជាចលនាតស៊ូដែលដឹកនាំដោយ សមមិត្ត ហេង សំរិន និងសមមិត្ត ជា ស៊ីម នៅភូមិភាគបូព៌ា សមមិត្ត ប៊ូ ថង នៅភូមិភាគឦសាន និងសមមិត្ត សាយ ភូថង នៅភូមិភាគបស្ចិម។ ចលនាតស៊ូទាំងនេះបានរួមគ្នាបង្កើតបានទៅជាចលនាតស៊ូរួមរបស់ជាតិ ដែលមានឈ្មោះថារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ នៅក្នុងទឹកដីស្រុកស្នួល ខេត្តក្រចេះ។ រណសិរ្សនេះដឹកនាំដោយសមមិត្ត ហេង សំរិន។ កងទ័ព

facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់របណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានចាប់ផ្តើមវាយប្រហារលើកងទ័ពកម្ពុជាប្រជាធិបតេយ្យ ហើយបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជាត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍។

## V. ការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម

ដើម្បីឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍របស់របបខ្មែរក្រហម និងជាផ្នែកមួយនៃការចូលរួមយុទ្ធនាការជាសាកលក្នុងទប់ស្កាត់ការកើតឡើងវិញនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជា ការផ្សះផ្សារបួសផ្លូវចិត្ត និងការបញ្ចប់និទណ្ឌភាព រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានព្រមព្រៀងគ្នាបង្កើតច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អវតក) ដែលត្រូវបានស្គាល់ថា«សាលាក្តីខ្មែរក្រហម»។ ច្បាប់នេះត្រូវបានរដ្ឋសភាជាតិអនុម័ត និងឡាយព្រះហស្តលេខាចូលជាធរមានដោយព្រះមហាក្សត្រនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១។ ទោះជាយ៉ាងនេះក្តី តុលាការនេះចាប់ផ្តើមដំណើរការជាលើកដំបូងរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦។ តុលាការនេះមានយុត្តាធិការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលនៅក្នុងរយៈកាលនេះ ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់ត្រូវបានសម្លាប់ និងស្លាប់ដោយការធ្វើទារុណកម្ម ការអត់អាហារ ការធ្វើការហួសកម្លាំង និងជំងឺគ្មានថ្នាំព្យាបាល។ បញ្ញវន្ត និងជាពិសេសគ្រូបង្រៀនប្រមាណ៨០ភាគរយក៏បានបាត់បង់ជីវិតនៅក្នុងរបបនេះផងដែរ

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងនៃអវតក កាត់ទោសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអវតកបានកាត់ទោសឌុចឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មដដែល។ មកត្រឹមឆ្នាំ២០១៧ អតីតមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់ខ្មែរក្រហមចំនួនប្រាំនាក់ត្រូវបានតុលាការអវតកចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌នៅក្នុងកំឡុងពេលជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១។ អ្នកទាំងនេះរួមមាន ឌុច, ខៀវ សំផន (អតីតប្រធានគណៈប្រធានរដ្ឋ) នួន ជា (អតីតប្រធានសភាតំណាងប្រជាជនកម្ពុជា) ចំណែក អៀង សារី (រដ្ឋមន្ត្រីការបរទេស)បានស្លាប់ក្នុងអំឡុងពេលដំណើរការសាលាក្តី រីឯអៀង ធីរិទ្ធ(រដ្ឋមន្ត្រីសង្គមកិច្ច)ត្រូវបានដាក់ឱ្យនៅក្រៅឃុំដោយសារតែជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តទៅមុខ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មេរៀនទី៥

# សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

## I.ការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ

### ១. កំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា[51]

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុងមូលដ្ឋានតស៊ូក្នុងស្រុកស្នួល ខេត្តក្រចេះ មហាសន្និបាតបានប្រារព្ធឡើងដោយមានតំណាងកម្លាំងរំដោះគ្រប់តំបន់ទូទាំងប្រទេសចូលរួម។ មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការមជ្ឈិមរណសិរ្សដែលមានសមាជិក១៤រូប ក្នុងនោះ សមមិត្ត ហេង សំរិន ជាប្រធាន។

មហាសន្និបាតបានអនុម័តកម្មវិធីនយោបាយដូចតទៅ៖

- គោរពឆន្ទៈ និងគោលបំណងរបស់ប្រជាពលរដ្ឋ
- ផ្តួលរំលំពួកប្រតិកិរិយាប៉ុល ពត ដែលជាពួកឃាតក
- កសាងប្រទេសកម្ពុជាប្រកបដោយឯករាជ្យសន្តិភាព សេរីភាព និងសុភមង្គល។

### ២. ជ័យជម្នះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

ដោយមានជំនួយពីកងទ័ពវៀតណាម និងការគាំទ្រពីប្រជាជនកម្ពុជា នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានធ្វើការរំដោះប្រជាជននិងប្រទេសពីរបបកម្ពុជាប្រជាធិបតេយ្យជាបន្តបន្ទាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ភ្នំពេញត្រូវបានរំដោះ។ កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមប្រើរយៈពេលបីសប្តាហ៍ក្នុងការរំដោះប្រទេសកម្ពុជាស្ទើរតែទាំងស្រុង។

## II.សាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩)

ក្រោយពីទទួលបានជោគជ័យក្នុងការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបថ្មីមួយដែលបានចាប់បដិសន្ធិឡើងក្រោមជំនួយឧបត្ថម្ភពីកម្លាំងកងទ័ពវៀតណាម គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

កិច្ចការចាំបាច់ចំនួនពីរដែលរដ្ឋាភិបាលថ្មីមួយនេះត្រូវធ្វើ គឺការកសាងសន្តិភាព និងការស្តាបនាជាតិឡើងវិញ។

---

[51] រណសិស្សសាមគ្គីសង្គ្រោះជាតិកម្ពុជាប្តូរជារណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជានៅឆ្នាំ១៩៨៥ និងប្តូរជារណសិស្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជានៅឆ្នាំ២០០៥។



facebook.com/moeyscambodia www.moeys.gov.kh YouTube youtube.com/moeyscambodia www.moeys.gov.kh

## ១. អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

របបថ្មីនេះគ្រប់គ្រងដោយបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអង្គការគ្រប់គ្រងសំខាន់ៗចំនួន៤គឺ ៖

- **គណបក្សប្រជាជនបដិវត្តន៍កម្ពុជា**ដឹកនាំដោយសមមិត្ត ប៉ែន សុវណ្ណដែលជាអគ្គលេខាធិការ(អតីតខ្មែរឥស្សរៈដែលបានរៀនសូត្រទ្រឹស្តីកុម្មុយនីស្តនៅវៀតណាម)។ នៅខែធ្នូ ឆ្នាំ១៩៨១ សមមិត្ត ហេង សំរិន បានកាន់តំណែងនេះជំនួសវិញ
- **ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី**មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចទិសដៅសំខាន់ៗរបស់បក្ស។ ក្រុមប្រឹក្សានេះមានសមមិត្ត ប៉ែន សុវណ្ណជាប្រធាន។ ចុងឆ្នាំ១៩៨១ សមមិត្ត ចាន់ ស៊ី (អតីតខ្មែរឥស្សរៈសិក្សានៅហាណូយ)បានឡើងជំនួសសមមិត្ត ប៉ែន សុវណ្ណ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវកំណត់ការប្រជុំយ៉ាងទៀងទាត់ដើម្បី៖
    - ចាត់វិធានការរដ្ឋបាលយ៉ាងច្បាស់លាស់សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួងមន្ទីរនានាចៀសវាងការអនុវត្តខុសទិសដៅ
    - ឱ្យតំណាងក្រសួងនីមួយៗឡើងរាយការណ៍បង្ហាញពីសមិទ្ធផល និងបញ្ហាផ្សេងៗដែលកើតមាន។
- **ក្រុមប្រឹក្សារដ្ឋ**ដែលមានសមមិត្ត ហេង សំរិន ជាប្រធាន មានតួនាទីធ្វើការវិនិច្ឆ័យ លើបញ្ហាច្បាប់របស់រដ្ឋដូចជារៀបចំច្បាប់-ក្រមព្រហ្មទណ្ឌ និងកែប្រែទោសប្រហារជីវិតជាដើម
- **រដ្ឋសភាជាតិ**មាន១១៧អាសនៈ។ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ សភាជាតិបានអនុម័តរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងតែងតាំងសមមិត្ត ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋ និងសមមិត្ត ប៉ែនសុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។

## ២. សមាសភាពអ្នកគ្រប់គ្រង

### រដ្ឋអំណាចខ្មែរ

ក្នុងដំណាក់កាលដំបូង ក្រសួងសំខាន់ៗកាន់កាប់ដោយមនុស្សពីរក្រុមគឺ៖

- ក្រុមអ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ា ពិសេសមកពីខេត្តកំពង់ចាម ស្វាយរៀង មានដូចជាសមមិត្ត ហេង សំរិន, សមមិត្ត ជា ស៊ីម, សមមិត្ត ហ៊ុន សែន...
- ក្រុមអ្នកបានទៅហាត់រៀននៅប្រទេសវៀតណាមក្រោយសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ មានដូចជាសមមិត្ត ប៉ែន សុវណ្ណ, សមមិត្ត ចាន់ ស៊ី។

ក្រុមទាំងពីរនេះមានឋានៈជារដ្ឋមន្ត្រី និងមានតួនាទីតាមស្ថាប័នសំខាន់ៗ ដូចជាក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ គណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្តក្រុង។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់ពីសន្តិសុខក្នុងប្រទេសមានលំនឹង សាធារណរដ្ឋប្រជាមានិតកម្ពុជាបានជ្រើសរើសអ្នកមានសមត្ថភាពដែលនៅរស់ឱ្យចូលបម្រើការក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

## ជំនាញការ និងកងទ័ពវៀតណាម

នៅក្នុងដំណាក់កាលនេះ មានវត្តមានកងទ័ពវៀតណាមនៅពាសពេញផ្ទៃប្រទេសដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍ប៉ុលពត និងអ្នកជំនាញការវៀតណាមជាច្រើនរូបដែលធ្វើការអមរដ្ឋអំណាចខ្មែរតាំងពីថ្នាក់ក្រសួង រហូតដល់ថ្នាក់មូលដ្ឋានដើម្បីជួយពង្រឹងរដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។

## III.ការកសាងសន្តិភាព និងការកសាងជាតិឡើងវិញ

ប្រទេសកម្ពុជាត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យក៏ពិតមែន តែកម្ពុជាបានបែកខ្ញែកជា៤ភាគី។

### ១. ខ្មែរទាំង៤ភាគី

**ភាគីទី១**គឺរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលដឹកនាំដោយហេង សំរិន ៖ ភាគីទី១នេះជាអ្នករំដោះកម្ពុជាពីរបបខ្មែរក្រហម និងមានទិសដៅកសាងជាតិឡើងវិញ ព្រមទាំងទប់ស្កាត់ការវិលត្រឡប់របស់ខ្មែរក្រហម។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាកាន់កាប់ទឹកដីភាគច្រើននៃប្រទេសកម្ពុជាដោយមានរាជធានីនៅទីក្រុងភ្នំពេញ។ ភាគីនេះទទួលការឧបត្ថម្ភគាំទ្រពីវៀតណាម សហភាពសូវៀតនិងសម្ពន្ធមិត្តរបស់សូវៀត។

**ភាគីទី២**គឺកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម ដែលដឹកនាំដោយប៉ុល ពត ៖ ទោះបីជាខ្មែរក្រហមលែងគ្រប់គ្រងកម្ពុជាក៏ពិតមែន ក៏ប៉ុន្តែពួកគេនៅតែរក្សាអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិ។ កងទ័ពខ្មែរក្រហមនៅតែបន្តគ្រប់គ្រងទឹកដីកម្ពុជាមួយភាគ និងជំរំជនភៀសខ្លួនមួយចំនួនដែលស្ថិតនៅតាមព្រំដែនខ្មែរ-ថៃ។ ភាគីនេះបានទទួលជំនួយជាច្រើនពីបរទេស ជាពិសេសប្រទេសចិន។ ថវិកាដែលបានមកពីជំនួយបរទេស ការលក់ព្រៃឈើនិងរ៉ែត្បូងនៅប៉ៃលិន បានធ្វើឱ្យកម្លាំងខ្មែរក្រហមនៅតែរឹងមាំ និងគំរាមកំហែងសន្តិសុខជាតិគ្រប់ពេលវេលា។ ខ្មែរក្រហមនៅតែព្យាយាមវិលត្រឡប់មកកាន់អំណាចវិញ។

**ភាគីទី៣**គឺរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរប្រជាធិបតេយ្យ ដែលដឹកនាំដោយ សឺន សាន ៖ ភាគីនេះបង្កើតឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩។ អ្នកចូលរួមក្នុងរណសិរ្សនេះមានប្រភពខុសៗគ្នា។ រណសិរ្សនេះមានទិសដៅសំខាន់៣គឺ រំដោះប្រទេសកម្ពុជាពីអំណាចរបស់វៀតណាម ប្រឆាំងការវិលត្រឡប់មកកាន់អំណាចរបស់ខ្មែរក្រហម និងកសាងជាតិឡើងវិញ។ រណសិរ្សនេះកាន់កាប់ទឹកដី និងជំរំជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ភាគីទី៤**គឺក្រុមរាជានិយមរបស់សម្តេច នរោត្តម សីហនុ(FUNCINPEC-ហ៊្វុនស៊ិនប៉ិច)[52] ៖ ភាគីទី៤នេះបង្កើតឡើងនៅខែមីនា ឆ្នាំ១៩៨១ ដោយមានការចូលរួមពីក្រុមម៉ូលីណាកាដែលបង្កើតតាំងពីឆ្នាំ១៩៧៩។ ទិសដៅសំខាន់របស់ហ៊្វុនស៊ិនប៉ិចគឺប្រឆាំងនឹងវត្តមានរបស់វៀតណាមនៅលើទឹកដីកម្ពុជា។ ភាគីទី៤នេះកាន់កាប់ទឹកដី និងជំរំជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ ហើយជំរំដែលសំខាន់ជាងគេរបស់ក្រុមនេះគឺស្ថិតនៅអូរស្មាច់ ខេត្តឧត្តរមានជ័យ។

នៅឆ្នាំ១៩៨២ ក្រុមខ្មែរក្រហម(ភាគីទី២) ក្រុមសឺន សាន(ភាគីទី៣) និងក្រុមរាជានិយម(ភាគីទី៤)**បានរួបរួមគ្នាបង្កើតជារដ្ឋាភិបាលសម្ពន្ធត្រីភាគី** ហើយដឹកនាំដោយសម្តេច នរោត្តម សីហនុ។ គោលជំហររបស់រដ្ឋាភិបាលត្រីភាគីនេះ គឺប្រឆាំងនឹងវត្តមានវៀតណាមនៅកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា(ភាគីទី១) តាមរយៈការទូត និងសង្គ្រាមឈ្លប។ ហេតុដូច្នេះ សង្គ្រាមក្នុងស្រុកនៅតែបន្តឥតឈប់ឈរ។

## ២. សង្គ្រាមក្នុងស្រុក

ក្រុមខ្មែរក្រហមដែលនៅសេសសល់លាក់ខ្លួននៅតាមតំបន់ព្រៃក្រាស់ដែលពិបាកចូលទៅដល់។ ពួកគេតែងធ្វើសកម្មភាពជាក្រុមតូចៗក្នុងទ្រង់ទ្រាយជាសង្គ្រាមឈ្លប ដើម្បីធក់ប្លន់ស្បៀង អុកឡុកបង្កអសន្តិសុខដល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងផ្តួលរំលំរដ្ឋអំណាចភូមិ ឃុំ ក្នុងគោលបំណងវិលមកកាន់អំណាចឡើងវិញ។ តាមបណ្តោយព្រំដែនខ្មែរ-ថៃ និងជុំវិញបឹងទន្លេសាបបានក្លាយទៅជាតំបន់អសន្តិសុខ រីឯតំបន់ផ្សេងទៀតក្រៅពីនោះ ក៏រងការគំរាមកំហែងជាញឹកញាប់ផងដែរ។

## ៣. ការទប់ស្កាត់ការវិលត្រឡប់របស់ពួកខ្មែរក្រហម

### ការរំដោះតំបន់នៅតាមព្រំដែន

ដើម្បីការពារសន្តិសុខ ប្រជាជននិងមន្ត្រីរដ្ឋការគ្រប់ជាន់ថ្នាក់បានចូលរួមជាមួយកងកម្លាំងប្រដាប់អាវុធក្នុងការយាមកាមនៅតាមតំបន់ដែលខ្លួនរស់នៅ។

រៀងរាល់រដូវប្រាំង រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាតែងវាយសម្រុកទៅលើពួកខ្មែរក្រហម និងគ្រប់គ្រងតំបន់មួយចំនួននៅតាមព្រំដែន។ ក៏ប៉ុន្តែ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវដកទ័ពមកវិញនៅរដូវវស្សា ជាហេតុធ្វើឱ្យពួកខ្មែរក្រហមដណ្តើមយកបានវិញនូវទីតាំងដែលវាយបាន។

មូលហេតុដែលរដ្ឋាភិបាលត្រូវដកទ័ពត្រលប់មកវិញនៅរដូវវស្សាគឺ ៖

- ប្រព័ន្ធផ្លូវថ្នល់មានការលំបាកខ្លាំង ពិបាកក្នុងការដឹកជញ្ជូនផ្គត់ផ្គង់ស្បៀង និងសព្វាវុធ

[52]FUNCINPECមកពីអក្សរកាត់ជាភាសាបារាំងFront uni national pour un Cambodge indépendant, neutre, pacifique et coopératifដែលមានអត្ថន័យជាភាសាខ្មែរថារណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រិត សន្តិភាព និងសហប្រតិបត្តិការ។



facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កម្លាំងនៅសមរភូមិក្រោយនៅមិនទាន់រឹងមាំ ដែលទាមទារការដកកម្លាំងពីព្រំដែន ឬសមរភូមិមុខមកពង្រឹង។

នៅឆ្នាំ១៩៨៤ កងកម្លាំងនៅសមរភូមិក្រោយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាមានការរីកចម្រើនច្រើនដែលអាចបន្តវាយលុកនៅរដូវវស្សា និងការពារទីតាំងដែលដណ្ដើមបានកាលពីរដូវប្រាំង។

## ផែនការ ក៥

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៨៤ ការិយាល័យនយោបាយមជ្ឈិមបក្សបានចេញសេចក្ដីសម្រេចចិត្តមួយស្ដីពីការបង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃដោយឱ្យឈ្មោះថា «ផែនការ ក៥» ឬ «កែនកម្លាំងកាប់ឆ្ការព្រៃការពារព្រំដែនកម្ពុជា»។

ផែនការនេះតម្រូវឱ្យមានការចូលរួមពីប្រជាជនខ្មែរដើម្បី៖

- សាងសង់ផ្លូវនៅតាមព្រំដែនដើម្បីសម្រួលក្នុងការដឹកជញ្ជូនកងទ័ព អាវុធ ស្បៀង ។ល។
- កាប់ឆ្ការព្រៃនៅក្បែរភូមិ ជុំវិញផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក តាមជនបទ និងតាមតំបន់ព្រំដែនដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ពួកកងទ័ពនៃរដ្ឋាភិបាលត្រីភាគី
- រៀបចំកសាងប្រព័ន្ធការពារនៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃដោយក្នុងនោះមានការដាក់ចម្រូងឬស្សី ដាក់មីន លើកទំនប់ និងជីកលេណដ្ឋានជាដើម។

នៅរដូវប្រាំងចុងឆ្នាំ១៩៨៤ ដើមឆ្នាំ១៩៨៥ កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានទទួលជោគជ័យច្រើនជាងមុននៅតាមព្រំដែន ក៏ប៉ុន្តែពួកកងទ័ពត្រីភាគីបានឆ្លៀតឱកាសនោះប្រើប្រាស់ក្រុមតូចៗក្នុងការបំផ្លាញ និងបង្កអស្ថិរភាពនៅសមរភូមិក្រោយ។

ក្នុងស្ថានភាពបែបនេះ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកំណត់នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៨៥ នូវកាតព្វកិច្ចយោធារយៈពេល៥ឆ្នាំសម្រាប់ពលរដ្ឋខ្មែរដែលមានអាយុចាប់ពី១៨ឆ្នាំឡើង។

សង្គ្រាមស៊ីវិលនៅតែអូសបន្លាយដោយគ្មានអ្នកឈ្នះអ្នកចាញ់ គឺមានតែជនរងគ្រោះ និងអ្នកស្លាប់ដោយសារសង្គ្រាម ដោយជនទាំងនោះសុទ្ធសឹងតែជាជនជាតិខ្មែរ។

## ៤. ការកសាងជាតិឡើងវិញ

រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបង្កើតឡើងតាមរយៈការជួយជ្រោមជ្រែងរបស់វៀតណាម មិនត្រូវបានអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិ ព្រមទាំងប្រទេសសមាជិកអាស៊ានទទួលស្គាល់នោះទេ។ ជំនួយមនុស្សធម៌ទាំងប៉ុន្មានត្រូវបង្វែរទៅផ្គត់ផ្គង់ប្រជាជនខ្មែរដែលរស់នៅតាមជំរំជនភៀសខ្លួននៅតាមព្រំដែនខ្មែរ-ថៃ ដែលជំរំនីមួយៗស្ថិតនៅក្រោមអំណាចរបស់ក្រុមដឹកនាំ៣ផ្សេងទៀត គឺក្រុមខ្មែរក្រហម, ក្រុមរាជានិយមដឹកនាំដោយសម្ដេច នរោត្ដម សីហនុ ឬក្រុមរបស់លោកសឺន សាន។ រដ្ឋា-

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវកសាងប្រទេសឡើងវិញពីចំណុចសូន្យ ដោយពឹងផ្អែកទាំងស្រុងលើជំនួយពីវៀតណាម សហភាពសូវៀត និងប្រទេសសង្គមនិយម។

## ស្ថានភាពសង្គមកម្ពុជាក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩

ប្រជាជនដែលបានរួចផុតពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមភាគច្រើនជាស្ត្រីមេម៉ាយ ក្មេងកំព្រា មនុស្សចាស់ជរា និងមនុស្សបាក់កម្លាំង។ ពួកគេមានតែបាតដៃទទេ ពុំមានគោ ក្របី រទេះ នង្គ័ល សម្រាប់ធ្វើស្រែចម្ការបង្កបង្កើនផលនោះទេ។ អ្នកខ្លះវិលមកស្រុកកំណើតរបស់ខ្លួនវិញ។ អ្នកខ្លះបានជួបជុំឪពុកម្ដាយសាច់ញាតិ អ្នកខ្លះព្រាត់ប្រាស់ឪពុកម្ដាយសាច់ញាតិ អ្នកខ្លះស្លាប់ស្ទើរផុតពូជតែម្ដង។ អ្នកដែលអស់សង្ឃឹមនឹងរស់នៅស្រុកខ្មែរ បាននាំគ្នាភៀសខ្លួនទៅកាន់ជំរំជនភៀសខ្លួនតាមព្រំដែនកម្ពុជា-ថៃ។

ស្បៀងអាហារ និងស្រូវមួយភាគធំត្រូវពួកខ្មែរក្រហមបំផ្លាញចោលមុនពេលចាកចេញ សូម្បីតែវាលស្រែដែលពោរពេញទៅដោយស្រូវទុំក៏ត្រូវពួកខ្មែរក្រហមដុតកម្ទេចដែរ។ រីឯខែមករាដែលជាពេលរំដោះគឺជារដូវប្រាំងដែលមិនអាចបង្កបង្កើនផលបាន។

ប្រទេសទាំងមូលគ្មានចរាចរណ៍ទំនិញ និងគ្មានរូបិយវត្ថុ។ ប្រជាជនប្រមាណ៨០ភាគរយកំពុងស្វែងរកញាតិមិត្ត និងមិនអាចបង្កបង្កើនផលបាន។ សាលារៀន មន្ទីរពេទ្យ និងវត្តអារាមកំពុងតែក្លាយទៅជាទីស្នាក់អាស្រ័យរបស់ប្រជាជនដែលមិនទាន់អាចរកជម្រកបាន...។

## ការស្ដាបនាសេដ្ឋកិច្ច

ក្រោយសម័យខ្មែរក្រហម កម្ពុជាទទួលរងនូវការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងប្រឈមទៅនឹងគ្រោះទុរ្ភិក្ស។ បញ្ហាចម្បងដែលរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវធ្វើគឺដោះស្រាយបញ្ហាស្បៀងរបស់ប្រជាជនទូទាំងប្រទេស។

សហភាពសូវៀត វៀតណាម និងប្រទេសសង្គមនិយមបានផ្ដត់ផ្គង់ស្បៀងអាហារ សម្ភារប្រើប្រាស់បច្ចេកទេស ពូជស្រូវ ដំណាំ វត្ថុធាតុដើម និងបច្ចេកទេស ដើម្បីចាប់ផ្ដើមឱ្យមានផលិតកម្ម សិប្បកម្ម និងឧស្សាហកម្មនៅកម្ពុជា។

ជំហានដំបូងក្នុងការស្ដាបនាសេដ្ឋកិច្ច រដ្ឋាភិបាលបានបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃក្នុងគោលបំណងឱ្យប្រជាជនចេះជួយគ្នាក្នុងកាលៈទេសៈដែលខ្វះខាតឧបករណ៍និងមធ្យោបាយបង្កបង្កើនផល កម្លាំងពលកម្ម គោក្របី គ្រាប់ពូជ និងធនធាន។ ការបង្កើតក្រុមសាមគ្គីនេះក៏ដើម្បីជួយសម្រាលបន្ទុកដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា មនុស្សចាស់ជរា អ្នកបាក់កម្លាំងដែលគ្មានឧបករណ៍បង្កបង្កើនផលផងដែរ។ ក្រុមសាមគ្គីនីមួយៗមានសមាជិក១០គ្រួសារ ឬអាចច្រើនជាងនេះ។

សេដ្ឋកិច្ចប្រទេសកម្ពុជាបានពឹងផ្អែកលើវិស័យកសិកម្មបែបយថាផល។ ប្រជាជនខ្មែរ៩០ភាគរយប្រកបមុខរបរកសិកម្មពិសេសដំណាំស្រូវ។ ក្រៅពីដំណាំស្រូវ មានដំណាំស្បៀង និងដំណាំឧស្សាហកម្មផ្សេងទៀតសម្រាប់ឧបត្ថម្ភក្នុងស្រុក និងសម្រាប់នាំចេញដូចជា ផលិតកម្មកៅស៊ូ អាជីវកម្មព្រៃឈើ ការនេសាទ ការដាំក្រចៅ...។

facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅឆ្នាំ១៩៨០ រដ្ឋាភិបាលបានបោះពុម្ពក្រដាសប្រាក់ និងដាក់ឱ្យប្រើប្រាស់ឡើងវិញ។ ក៏ប៉ុន្តែល្បឿននៃការដាក់លុយឱ្យប្រើប្រាស់មានល្បឿនយឺត។ ប្រជាជនត្រូវប្រើការដោះដូរដោយយកអង្ករជាគោល។

ក្រោយមក នៅឆ្នាំ១៩៨៣-១៩៨៦ គោលនយោបាយរបស់រណសិរ្សបានប្តូរពីក្រុមសាមគ្គីទៅជាម្ចាស់ការទាំងស្រុង ដោយឈានទៅរករបបកម្មសិទ្ធិឯកជន។

## ការស្តារបនាសង្គម

តម្រូវការ និងកិច្ចការដែលត្រូវធ្វើដើម្បីស្តាបនាសង្គមលើគ្រប់វិស័យមានទំហំធំធេង ប៉ុន្តែកម្ពុជាជួបប្រទះនូវបញ្ហាកង្វះខាតធនធានមនុស្ស កង្វះខាតថវិកា កង្វះខាតធនធានគ្រប់សព្វបែបយ៉ាង និងរងគំនាបរបស់មហាអំណាចសេរី និងប្រទេសដែលជាសម្ពន្ធមិត្ត។

### វិស័យអប់រំ

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិស័យអប់រំ និងវប្បធម៌ដែលពួកខ្មែរក្រហមព្យាយាមកម្ទេចចោលត្រូវបានស្តារឡើងវិញភ្លាមៗ។ ការប្រមូលគ្រូបង្រៀនដែលនៅរស់ និងសិស្សានុសិស្សត្រូវបានប្រព្រឹត្តទៅគ្រប់ទិសទី។ រដ្ឋាភិបាលបានប្រើគោលនយោបាយមួយគឺ«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះ»។ ការបង្រៀន និងផ្ទេរចំណេះដឹងបានចាប់ផ្តើមឡើងយ៉ាងផុសផុលក្នុងសាលារៀន វត្តអារាម តាមផ្ទះប្រជាជន និងក្រោមដើមឈើជាដើម។ សិស្សានុសិស្សប្រើក្រដាសចាស់ៗ និងធ្យូងមកសរសេរ។

បន្តិចម្តងៗ

- រដ្ឋបានរៀបចំប្រព័ន្ធអប់រំឱ្យបើកទូលាយ និងពង្រីងបន្ថែមពីទីក្រុងរហូតដល់តំបន់ដាច់ស្រយាល
- សាលារៀនបានបើកទ្វារទទួលសិស្សពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា
- រដ្ឋបានបំផុសចលនាអក្ខរកម្ម ព្រមទាំងបណ្តុះបណ្តាលគ្រូ និងអ្នកជំនាញផ្សេងៗ
- សម្ភារសិក្សាក៏មានសមរម្យតាមរយៈអំណោយរបស់វៀតណាម សហភាពសូវៀត និងប្រទេសសង្គមនិយមដទៃទៀត។

### វិស័យវប្បធម៌

- រដ្ឋបានប្រមូលផ្តុំអ្នកសិល្បៈ និងសាស្ត្រាចារ្យផ្នែកសិល្បៈដែលនៅសេសសល់
- សាលាវិចិត្រសិល្បៈបានបើកទ្វារឡើងវិញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១
- រោងភាពយន្តមួយចំនួនចាប់ផ្តើមបើកទ្វារឡើងវិញជាបណ្តើរៗ
- វត្តអារាមត្រូវបានជួសជុល និងដំណើរការឡើងវិញ
- ការរើសគូស្រករ និងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមានការបើកទូលាយឡើងវិញ។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### វិស័យសង្គមកិច្ច

- មជ្ឈមណ្ឌលកុមារកំព្រាជាច្រើនបានបើកទ្វារ និងទទួលកុមារប្រមាណ ៦ ០០០នាក់នៅទូទាំងប្រទេស
- ជនពិការ និងស្ត្រីមេម៉ាយត្រូវបានបែងចែកទៅតាមក្រុមសាមគ្គី ឯសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការមួយចំនួនក៏បានបើកទ្វារ
- ការផ្គត់ផ្គង់ទឹកស្អាត និងភ្លើងអគ្គិសនីបានចាប់ផ្តើមបន្តិចម្តងៗ
- ច្បាប់ការពារកម្មសិទ្ធិឯកជនដោយផ្តល់កម្មសិទ្ធិដល់ប្រជាពលរដ្ឋខ្មែរត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨៧។

### វិស័យសុខាភិបាល

- មន្ទីរពេទ្យជាច្រើនបានដំណើរការឡើងវិញ ប៉ុន្តែកង្វះខាតធនធានមនុស្ស គ្រឿងបរិក្ខារ ថ្នាំសង្កូវនៅតែជាបញ្ហាប្រឈមដ៏សំខាន់
- មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រត្រូវបើកឱ្យដំណើរការវិញនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៨០
- សាលាសុខាភិបាលមធ្យម និងខេត្តក្រុងបានបើកឱ្យដំណើរការវិញជាបន្តបន្ទាប់។

## ៥. ការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ

### ការចរចារកសន្តិភាព

នៅខែវិច្ឆិកា ឆ្នាំ១៩៨៤ គម្រោងជួបចរចានៅប្រទេសបារាំង រវាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្តេច នរោត្តម សីហនុ ដែលជាតំណាងរដ្ឋាភិបាលសម្ពន្ធត្រីភាគីត្រូវអាក់ខានដោយសារចិន និងខ្មែរក្រហមបានដាក់គំនាបលើសម្តេច នរោត្តម សីហនុ។

ចាប់ពីឆ្នាំ១៩៨៥ ស្ថានភាពនយោបាយនៅអាស៊ី និងក្នុងពិភពលោកមានភាពធូរស្រាលជាងមុន។ សហភាពសូវៀតបានប្រកាសយកកំណែទម្រង់សេដ្ឋកិច្ច និងសង្គមដែលមិនធ្លាប់មានពីមុនមកឈ្មោះថា «Perestroika» ព្រមទាំងដកទ័ពចេញពីអាហ្វហ្គានីស្ថាននៅឆ្នាំ១៩៨៩។ កត្តាទាំងនេះបានអនុគ្រោះដល់ការចរចាសន្តិភាពនៅកម្ពុជា។ ផែនការស្តីពីការដាក់កំហិតឱ្យកងទ័ពវៀតណាមដកចេញពីកម្ពុជាឱ្យអស់នៅឆ្នាំ១៩៨៩ត្រូវបានរៀបចំឡើង។

នៅឆ្នាំ១៩៨៧ ជំនួបកំពូលរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត បានធ្វើឱ្យស្ថានការណ៍នយោបាយនៅកម្ពុជាប្រសើរជាងមុន។

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ មានការជួបគ្នាលើកទី១នៅហ្វែអង់តាដឺន័រ ប្រទេសបារាំងរវាងសម្តេច នរោត្តម សីហនុ និងលោក ហ៊ុន សែន ដែលជាតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ភាគីទាំងពីរបាន

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចុះហត្ថលេខាព្រមព្រៀង និងចរចារកដំណោះស្រាយនៅកម្ពុជាដោយកំណត់កាលបរិច្ឆេទក្នុងការជួបគ្នាលើកទី២ និងទី៣។

ក្រោមអន្តរាគមន៍របស់បរទេស លោក សឺន សាន និងលោក ខៀវ សំផនក៏ព្រមចូលតុចរចា។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៨ ការចរចាលើកដំបូងដោយមានការចូលរួមទាំង៤ភាគី និងប្រទេសដែលពាក់ព័ន្ធបានប្រព្រឹត្តឡើងនៅប្រទេសឥណ្ឌូណេស៊ី។ ជំនួបនេះបានផ្តល់នូវលទ្ធផលជាច្រើនដូចជា ៖

- ការកំណត់ការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា
- ការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យវិលត្រឡប់មកវិញ
- ការបញ្ឈប់ជំនួយរបស់បរទេស ទៅឱ្យក្រុមដែលប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
- ការបញ្ឈប់ការជ្រៀតជ្រែកពីខាងក្រៅក្នុងកិច្ចការរបស់កម្ពុជា។

## ការដកទ័ពវៀតណាមចេញពីទឹកដីកម្ពុជា និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨៩ វៀតណាមបានប្រកាសថា កងទ័ពរបស់ខ្លួននឹងដកចេញឱ្យអស់ពីកម្ពុជានៅចុងខែកញ្ញា ឆ្នាំ១៩៨៩ ហើយនៅថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ សភាជាតិនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបើកសម័យប្រជុំវិសាមញ្ញមួយដោយសម្រេចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖

- ប្តូរឈ្មោះប្រទេសពី«សាធារណរដ្ឋប្រជាមានិតកម្ពុជា» ទៅជា«រដ្ឋកម្ពុជា»
- ប្តូរទង់ជាតិ និងភ្លេងជាតិ
- លុបបំបាត់ច្បាប់ប្រហារជីវិត(លុបទោសប្រហារជីវិត)
- ទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងលុបចោលការកំហិត(លក្ខខណ្ឌ) អ្នកសាងផ្នួស(អ្នកបួស)
- បង្កើតទីផ្សារសេរីផ្តល់សេរីភាពសារព័ត៌មាន និងការបង្កើតអង្គការសង្គមស៊ីវិល។

រដ្ឋធម្មនុញ្ញថ្មីនេះបានលុបបំបាត់ចោលនូវការប្រើប្រាស់ពាក្យសង្គមនិយម ព្រមទាំងបានចែងថាប្រទេសកម្ពុជាជាប្រទេសអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ។

## ដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជា

ក្រោយពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រោយពីការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨៩មក វេទិការបស់សម្តេច នរោត្តម សីហនុ និងលោក ហ៊ុន សែន ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបានប្រព្រឹត្តទៅជាបន្តបន្ទាប់នៅទីក្រុងប៉ារីស(ប្រទេសបារាំង) ទីក្រុងហ្សាការតា(ឥណ្ឌូណេស៊ី) ទីក្រុងតូក្យូ(ប្រទេសជប៉ុន) និងទីក្រុងប៉ាតាយ៉ា(ប្រទេសថៃ)។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈសន្និសីទអន្តរជាតិលើកទី១ នៅទីក្រុងប៉ារីសថ្ងៃទី៣០ កក្កដា-៣០ សីហា ១៩៨៩ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC: Supreme National Council) បានបង្កើតឡើងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ដែលមានសម្ដេច នរោត្ដម សីហនុជាប្រធាន និងមានសមាជិក១២រូប ដែលមកពីរដ្ឋកម្ពុជា៦រូប និងសម្ពន្ធត្រីភាគី៦រូប។ ក្រុមប្រឹក្សានេះបានធ្វើការប្រជុំចំនួន៦លើកនៅទីក្រុងបាងកក ក្រុងប៉ារីស ក្រុងញូវយ៉ក ក្រុងហ្សាការតា និងក្រុងប៉េកាំង។

ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ១៩៩១ នៅទីក្រុងប៉ាតាយ៉ា គូបដិបក្ខខ្មែរទាំងបួនបានជួបជុំគ្នា និងបានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ។

ក្រោយពីមានការជួបចរចារវាងបណ្ដាភាគីខ្មែរនិងប្រទេសពាក់ព័ន្ធ ភាគីជម្លោះទាំងបួននៅកម្ពុជា និងប្រទេសចំនួន១៨ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ បញ្ហាកម្ពុជាក៏បានដោះស្រាយ។

## កិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

កិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ផ្ដោតទៅលើចំណុចពីរសំខាន់ៗគឺ៖

- កិច្ចព្រមព្រៀងទាក់ទងទៅនឹងអធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹត ឯករាជ្យជាតិកម្ពុជា
- សេចក្ដីថ្លែងការណ៍ស្ដីពីការស្ដារ និងកសាងប្រទេសកម្ពុជាឡើងវិញ។

ភាគីជម្លោះបានចាប់ដៃគ្នា យល់ព្រមធ្វើការបោះឆ្នោតជាសកលដែលមានអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជាដែលហៅកាត់ថាអ៊ុនតាក់(UNTAC[53])មើលការទទួលខុសត្រូវ។

អ៊ុនតាក់មានថវិកាចំនួន ៣ ០០០ លានដុល្លារ ដើម្បីបំពេញបេសកកម្ម៤យ៉ាងគឺ ៖

- ដកអាវុធពីកងទ័ពរដ្ឋកម្ពុជា កងទ័ពខ្មែរក្រហមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ(FNLPK) និងកងទ័ពរាជានិយមហ្វ៊ុនស៊ិនប៉ិច
- បញ្ចូលរដ្ឋអំណាចទាំងសងខាងឱ្យរួមគ្នា(រដ្ឋកម្ពុជា និងរដ្ឋាភិបាលសម្ពន្ធត្រីភាគី)
- រៀបចំការបោះឆ្នោតដោយសេរីដោយអ៊ុនតាក់
- នាំជនភៀសខ្លួនប្រហែល៣៥០ ០០០ នាក់ត្រឡប់មកមាតុភូមិវិញ។

ព្រឹត្តិការណ៍មួយដ៏សំខាន់ និងសក្ខីភាពនៃការរួមរួមគ្នាឡើងវិញរបស់កម្ពុជា គឺការយាងត្រឡប់មកកម្ពុជាវិញរបស់សម្ដេច នរោត្ដម សីហនុ នៅខែវិច្ឆិកា ឆ្នាំ១៩៩១ ដោយមិនរង់ចាំការមកដល់នៃទាហានអ៊ុនតាក់ ឬការបោះឆ្នោត...។

[53] UNTAC: United Nations Transitional Authority in Cambodia.

facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មេរៀនទី៦

## ព្រះរាជាណាចក្រកម្ពុជា«ទី២»
## (១៩៩៣-បច្ចុប្បន្ន)

### I.របបគ្រប់គ្រងថ្មី

#### ១. ការបោះឆ្នោត

ការបោះឆ្នោតជាសកល និងដោយសេរីត្រូវបានរៀបចំឡើងដោយអ៊ុនតាក់។ ការបោះឆ្នោតមានគណបក្សចំនួន២០ចូលរួម ប៉ុន្តែក្រុមខ្មែរក្រហមបានធ្វើពហិកា។ ហេតុដូច្នេះ អសន្តិសុខនៅមានទូទាំងប្រទេស។ ការបោះឆ្នោតនេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ដែលបានទទួលលទ្ធផលដូចតទៅ៖

- គណបក្សហ៊្វុនស៊ិនប៉ិច(នរោត្តម រណឫទ្ធិ)ទទួលបាន ៥៨អាសនៈ
- គណបក្សប្រជាជនកម្ពុជា(អតីតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា)ទទួលបាន ៥១អាសនៈ
- គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា(សឺន សាន)ទទួលបាន ១០អាសនៈ
- គណបក្សម៉ូលីណាកា និងអ្នកតស៊ូខ្មែរទទួលបាន ១អាសនៈ។

#### ២. ការបង្កើតរាជរដ្ឋាភិបាលថ្មី

ក្រោយពីការបោះឆ្នោត សភាធម្មនុញ្ញបានរៀបចំតាក់តែងរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញថ្មីនេះត្រូវបានអនុម័តនាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

ផ្អែកលើរដ្ឋធម្មនុញ្ញ ៖

- ប្រទេសកម្ពុជាបានក្លាយជាព្រះរាជាណាចក្រកម្ពុជា ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងអាស្រ័យរដ្ឋធម្មនុញ្ញ
- ព្រះបាទ នរោត្តម សីហនុ បានឡើងសោយរាជ្យជាលើកទី២(១៩៩៣-២០០៤)
- រាជរដ្ឋាភិបាលថ្មីនៃព្រះរាជាណាចក្រកម្ពុជាដែលជារាជរដ្ឋាភិបាលចម្រុះបានកើតឡើងបន្ទាប់ពីមានការសម្របសម្រួលនយោបាយរវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា។ ព្រះបាទ នរោត្តម សីហនុ បានតែងតាំងនាយករដ្ឋមន្ត្រីពីររូប គឺសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២
- អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ(អ៊ុនតាក់) បានបញ្ចប់បេសកកម្ម។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## II.ការកសាងសន្តិភាពពិតប្រាកដ

របបថ្មីនៃប្រទេសកម្ពុជាមានការទទួលស្គាល់ជាផ្លូវការពីប្រទេសនានាលើសកលលោក ក៏ប៉ុន្តែកម្ពុជានៅមិនទាន់មានសន្តិភាពពេញលេញនៅឡើយទេ។ ពួកខ្មែរក្រហមដែលកាន់កាប់តំបន់មួយភាគធំតាមព្រំដែនខ្មែរ-ថៃ នៅប៉ែកខាងជើង និងប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា មិនព្រមចូលរួមក្នុងការបោះឆ្នោត និងនៅតែបន្តគំរាមកំហែងសន្តិសុខជាតិ។ រាជរដ្ឋាភិបាលខិតខំចរចាជាមួយពួកខ្មែរក្រហម ដើម្បីឱ្យពួកគេចុះចូល តែវាជាការឥតប្រយោជន៍។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៤ សភាជាតិបានសម្រេចដាក់ពួកខ្មែរក្រហមឱ្យនៅក្រៅច្បាប់។

### ១. អសន្តិសុខ និងអស្ថិរភាពនយោបាយនៅប្រទេសកម្ពុជា

ចាប់ពីឆ្នាំ១៩៩៤មក គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាចចាប់ផ្តើមមានភាពរង្គោះរង្គើ។ ពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានភាពនយោបាយកាន់តែតានតឹងឡើងៗ។ ឆ្លៀតឱកាសនោះ ពួកខ្មែរក្រហមបានបង្កវិនាសកម្ម និងសង្គ្រាមប្រឆាំងនឹងរាជរដ្ឋាភិបាលដែលបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិ និងអាយុជីវិតប្រជាជនយ៉ាងច្រើន។

ដើម្បីសន្តិសុខ និងការរួបរួមមួយដ៏ពិតប្រាកដ រាជរដ្ឋាភិបាលនៅតែបន្តចរចាជាមួយពួកខ្មែរក្រហមតាមគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន។ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៦ អៀង សារីបានប្រកាសផ្តាច់ទំនាក់ទំនងជាមួយប៉ុល ពត និងចុះចូលជាមួយរាជរដ្ឋាភិបាល និងស្នើសុំការលើកលែងទោសពីសំណាក់ព្រះបាទ នរោត្តម សីហនុ ។

នៅពាក់កណ្តាលឆ្នាំ១៩៩៧ គណបក្សហ៊្វុនស៊ិនប៉ិចបានបន្តចរចាជាមួយក្រុមខ្មែរក្រហមដែលដឹកនាំដោយតាម៉ុក និងខៀវ សំផន នៅអន្លង់វែង។ ស្របពេលជាមួយគ្នានោះ ពួកខ្មែរក្រហមកំពុងតែបែកបាក់គ្នា។ ដោយលែងទុកចិត្តសហការីរបស់ខ្លួន ប៉ុល ពតបានឃាត់ខ្លួនខៀវ សំផន និងសម្លាប់សុន សេន ព្រមទាំងក្រុមគ្រួសារ។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៧ តាម៉ុកក៏បានចុះចូលជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។

នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ មានព្រឹត្តិការណ៍ផ្ទុះអាវុធប្រយុទ្ធគ្នារវាងកងកម្លាំងស្មោះត្រង់នឹងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជននៅទីក្រុងភ្នំពេញ។ ជាលទ្ធផល ៖

- នៅទីក្រុងត្រូវបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ និងសន្តិសុខឡើងវិញ
- មន្ត្រី និងទាហានដែលស្មោះត្រង់នឹងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិបានភៀសខ្លួនទៅអូរស្មាច់ដើម្បីបន្តការប្រយុទ្ធពីជាយដែនប្រឆាំងនឹងកងទ័ពរាជរដ្ឋាភិបាល
- ឯកឧត្តម អ៊ឹង ហួតដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិចជាអ្នកឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីទី១ជំនួសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដើម្បីបន្តការងារក្នុងរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេច ហ៊ុន សែនជានាយករដ្ឋមន្ត្រីទី២។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពតបានស្លាប់ដោយសារជំងឺគាំងបេះដូង។ ពួកខ្មែរក្រហមក៏ចាប់ផ្តើមបែកបាក់គ្នា។ ក្រុមខ្មែរក្រហមដែលនៅសេសសល់ ជាពិសេសក្រុមខ្មែរក្រហមដែលនៅអន្លង់វែងបានចុះចូលជាបន្តបន្ទាប់។

## ២. ការបោះឆ្នោតឆ្នាំ១៩៩៨ និងអាណត្តិបន្ទាប់

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ការបោះឆ្នោតជាតិលើកទី២បានដំណើរការតាមការគ្រោងទុកដោយមានវត្តមានរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ។ គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដោយទទួលបាន ៦៤អាសនៈក្នុងរដ្ឋសភា រីឯគណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៤៣អាសនៈ។

តាមរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលត្រូវជ្រើសតាំងដោយសំឡេងគាំទ្រពីភាគបីនៃចំនួនតំណាងរាស្ត្រ។ កត្តានេះបានជំរុញឱ្យមានកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចក្នុងការបង្កើតរាជរដ្ឋាភិបាលមួយរួមគ្នា។ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិត្រូវបានតែងតាំងជាប្រធានរដ្ឋសភា សម្តេចជា ស៊ីមជាប្រធានព្រឹទ្ធសភា ឯសម្តេច ហ៊ុន សែនជានាយករដ្ឋមន្ត្រី។

នៅចុងឆ្នាំ១៩៩៨ និងដើមឆ្នាំ១៩៩៩ ក្រុមខ្មែរក្រហមបានធ្វើសមាហរណកម្មទាំងស្រុងជាមួយរាជរដ្ឋាភិបាល។ កម្ពុជាបានទទួលនូវសន្តិភាពពេញលេញបន្ទាប់ពីការអនុវត្តនូវគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេច ហ៊ុន សែន។

ក្នុងការបោះឆ្នោតជាតិលើកទី៣(២០០៣) លើកទី៤(២០០៨) និងលើកទី៥(២០១៣) គណបក្សប្រជាជនកម្ពុជាបានឈ្នះឆ្នោតជាបន្តបន្ទាប់។ សម្តេច ហ៊ុន សែនត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីរហូតមក។

# III.ការអភិវឌ្ឍប្រទេស

នៅក្នុងការអភិវឌ្ឍប្រទេស រាជរដ្ឋាភិបាលមានទិសដៅ និងផែនការច្បាស់លាស់។ យុទ្ធសាស្ត្រពីរដែលរាជរដ្ឋាភិបាលបាន និងកំពុងធ្វើគឺយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ។

## ១. យុទ្ធសាស្ត្រត្រីកោណ

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រត្រីកោណដែលមានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ៖

**មុំទីមួយ៖ សន្តិភាវូបនីយកម្ម**គឺការនាំសុខសន្តិភាពនិងស្ថិរភាពមកវិញ និងរក្សាបាននូវសន្តិសុខសម្រាប់ប្រទេស និងប្រជាជនខ្លួន។ ចំណុចនេះរាជរដ្ឋាភិបាលធ្វើបានសម្រេចហើយ។

**មុំទីពីរ៖ សមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងសហគមន៍អន្តរជាតិ**សម្រេចបានជោគជ័យដូចជា៖

- ប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិមកវិញដែលអាសនៈនេះបានបាត់បង់ក្រោយការប្រឈមគ្នាខាងប្រដាប់អាវុធនៅខែកក្កដា ឆ្នាំ១៩៩៧

facebook.com/moeyscambodia www.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- នៅឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាសមាជិកទី១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)។ ការដែលកម្ពុជាបានចូលជាសមាជិកអាស៊ានបានធ្វើឱ្យកម្ពុជាលែងជាប្រទេសឯកោតទៅទៀត។
    - **ខាងផ្នែកនយោបាយ** កម្ពុជាអាចឈរស្មើមុខស្មើមាត់ជាមួយប្រទេសដែលជាសមាជិក និងចូលរួមនូវរាល់ការសម្រេចចិត្តនៅក្នុងតំបន់។
    - **ខាងផ្នែកសេដ្ឋកិច្ច ៖** កម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ។ ការធ្វើពាណិជ្ជកម្មក៏មានភាពងាយស្រួលជាងមុន។ ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្នុងប្រទេស និងក្នុងតំបន់។ ទេសចរក៏មានការកើនឡើង។ ដូច្នេះការចូលជាសមាជិកអាស៊ានក៏ជាផ្នែកមួយដែលជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំផងដែរ។
    - **ខាងផ្នែកទំនាក់ទំនង** ៖ គឺជំរុញឱ្យមានការកសាងហេដ្ឋារចនាសម្ពន្ធនិងផ្លូវថ្នល់ ព្រមទាំងការលើកលែងទិដ្ឋាការ។
    - **ខាងផ្នែកសង្គម** ៖ កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម។ ការជួយគ្នាទៅវិញទៅមករវាងប្រទេសសមាជិកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹងអាហារូបករណ៍សម្រាប់និស្សិតបានធ្វើឱ្យមន្ត្រីរាជការ ប្រជាជន និងយុវជនកម្ពុជាបានរៀនសូត្រ និងទទួលបាននូវឱកាសល្អៗជាច្រើន...
- នៅខែតុលា ឆ្នាំ២០០៤កម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។

**មុំទី៣ ៖ ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច**ត្រូវធ្វើឡើងតាមរយៈកម្មវិធីកំណែទម្រង់ទូលំទូលាយដែលពាក់ព័ន្ធនឹងកំណែទម្រង់សាធារណៈ វិមជ្ឈការ ការរំសាយកងទ័ពកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ សមភាពយេនឌ័រ ហិរញ្ញវត្ថុសាធារណៈ ការលុបបំបាត់អំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

**ជារួម** យុទ្ធសាស្ត្រត្រីកោណ(១៩៩៨-២០០៣)ត្រូវបានអនុវត្តដោយជោគជ័យដូចមានក្នុងកំណើនសេដ្ឋកិច្ចខ្ពស់ការវិនិយោគកើនឡើង និងការគ្រប់គ្រងបានប្រសើរជាងមុនខាងគោលនយោបាយរូបិយវត្ថុសារពើពន្ធនិងហិរញ្ញវត្ថុសាធារណៈ ដែលជាលទ្ធផលនាំឱ្យមានអតិផរណារទាប ការកើនឡើងទុនបម្រុងអត្រាប្តូរប្រាក់មានស្ថិរភាព ការកើនឡើងទុនពីបរទេស កំណើនការវិនិយោគពីឯកជន និងការអភិវឌ្ឍវិស័យឯកជនបានយ៉ាងលឿន។

## ២. យុទ្ធសាស្ត្រចតុកោណ

នៅក្នុងឆ្នាំ២០០៤ សម្តេចតេជោ ហ៊ុន សែនបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ចំណុចស្នូលនៃយុទ្ធសាស្ត្រនេះគឺអភិបាលកិច្ចល្អ។ ជោគជ័យនៃ

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអនុវត្តយុទ្ធសាស្ត្រនេះគឺអាស្រ័យលើការបង្កើតនូវបរិយាកាសអំណោយផលមួយក្នុងផ្នែកសំខាន់ៗទាំងបួន៖

- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម
- ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ ជាពិសេសភាពជាដៃគូជាមួយវិស័យឯកជន សហគមន៍ ម្ចាស់ជំនួយ និងសង្គមស៊ីវិល
- ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សមាហរណកម្មកម្ពុជាចូលក្នុងតំបន់ និងពិភពលោក។

មុំទាំងបួននៃចតុកោណដែលផ្តោតលើកំណែទម្រង់មាន ៖

- ការលុបបំបាត់អំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ
- កំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេសការកាត់បន្ថយទ័ព។

មុំទាំងបួននៃចតុកោណសម្រាប់ការបង្កើតកំណើនសេដ្ឋកិច្ចគឺ ៖

- ការជំរុញវិស័យកសិកម្ម
- ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ
- ការស្តារនីតិសម្បទា និងការស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ
- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

នៅខែតុលា ឆ្នាំ២០០៤ ព្រះបាទ នរោត្តម សីហនុបានសុំចូលនិវត្តន៍។ ព្រះបរមនាថ នរោត្តម សីហមុនី ត្រូវបានក្រុមប្រឹក្សារាជបល្ល័ង្កជ្រើសតាំងជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះបាទ នរោត្តម សីហនុបានសោយទិវង្គតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ និងមានបច្ឆាមរណនាមថា ព្រះបរមរតនកោដ្ឋ។

មកទល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើយុទ្ធសាស្ត្រចតុកោណចំនួនបីដំណាក់កាល ៖

- ដំណាក់កាលទី១ (២០០៤-២០០៨)
- ដំណាក់កាលទី២ (២០០៨-២០១៣)
- ដំណាក់កាលទី៣ (២០១៣-២០១៨)។

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សរុបសេចក្តីមក ចាប់ពីឆ្នាំ១៩៩៣រហូតដល់ឆ្នាំ២០១៦ កម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់។

កម្ពុជាបានបញ្ចូលសម្បត្តិវប្បធម៌ជាច្រើនជាបេតិកភណ្ឌពិភពលោកដូចជា រមណីយដ្ឋានអង្គរ(១៤ ធ្នូ ១៩៩២) របាំព្រះរាជទ្រព្យ(៧ វិច្ឆិកា ២០០៣) ល្ខោនស្រមោលស្បែកធំ(២៥ វិច្ឆិកា ២០០៥) រមណីយដ្ឋានប្រាសាទព្រះវិហារ(៧ កក្កដា ២០០៨) ចាប៉ីដងវែង(៣០ វិច្ឆិកា ២០១៦) និងតំបន់ប្រាសាទសំបូរព្រៃគុក(៨ កក្កដា ២០១៧)។

ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាជាប្រទេសដែលមានប្រាក់ចំណូលទាប(២៦៨ដុល្លារក្នុងម្នាក់ក្នុង១ឆ្នាំ)[54]។ នៅឆ្នាំ២០១៦ កម្ពុជាបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបប្រមាណ(១២២៨ដុល្លារក្នុងម្នាក់ក្នុង១ឆ្នាំ)[55]។ កម្ពុជាមានបំណងក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ក៏ប៉ុន្តែគ្រប់ដំណាក់កាលនៃការឈានទៅសម្រេចបាននូវការអភិវឌ្ឍនេះគឺសុទ្ធតែមានបញ្ហាប្រឈមថ្មីៗ។

---

[54] Income GDP per Capital, World Bank 1998.
[55] Income GDP per Capital, World Bank 2016.



facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្តីថ្លែងអំណរគុណ

ឯកសារ«សេចក្តីសង្ខេបនៃមេរៀនប្រវត្តិសាស្ត្រខ្មែរសម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២» នេះមិនអាចលេចជារូបរាងបានទេប្រសិនបើមិនមានការចូលរួមទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃតាមភារកិច្ច តួនាទី និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្អូនៗនិស្សិតដែលមានរាយនាមដូចខាងក្រោម ៖

**ក.សមាជិកនៃអនុគណៈកម្មការប្រវត្តិវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡា ៖**

| | | | | | |
|---|---|---|---|---|---|
| - ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ ជួន | ណារ៉ុន | - ឯកឧត្តមបណ្ឌិតសភាចារ្យ | ស៊ន | សំណាង |
| - លោកស្រីបណ្ឌិត | ឃួន | វិច្ឆិកា | - លោកបណ្ឌិត | វង់ | សុធារ៉ា |
| - លោក | សំបូរ | មាណ្ណារ៉ា | - លោកបណ្ឌិត | ឱ | ខាំបូលី |
| - លោក | មួង | សុផាត | - លោក | មាស | ភិរុណ |
| - លោក | ចេង | ហុង | - លោក | ស៊ីវ | ធួន |
| - លោក | អ៊ីវ | សៅសុខា | - លោក | ណុប | សុខា |
| - លោក | ប៉ូ | សុខា | - លោកស្រី | សុន | វណ្ណា |
| - កញ្ញា | ហ៊ | ស៊ីវី | - លោក | ឈឹម | ឱណា |
| - លោកបណ្ឌិត | តឹក | ម៉េង | - លោកស្រី | ជា | កល្យាណ |
| - លោក | ទី | សុផល | - លោក | លី | រមនី |

**ខ.អ្នករៀបរៀង ៖**

| | | | |
|---|---|---|---|
| - ឯកឧត្តមបណ្ឌិតសភាចារ្យ | ស៊ន | សំណាង | ទីប្រឹក្សារាជរដ្ឋាភិបាល |
| - លោកស្រីបណ្ឌិត | ឃួន | វិច្ឆិកា | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |
| - លោកបណ្ឌិត | ឱ | ខាំបូលី | ប្រធាននាយកដ្ឋានគោលនយោបាយ |
| - លោក | មាស | ភិរុណ | គ្រូបង្រៀននៃវិទ្យាល័យព្រះស៊ីសុវត្ថិ |

**គ.និស្សិតដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ៖**

| | | | | | |
|---|---|---|---|---|---|
| - កញ្ញា | ស៊ាម | រីណា | - លោក | សុង | ភក្ត្រា |
| - កញ្ញា | វន | វន្នី | - លោក | កែវ | សីហា |
| - កញ្ញា | សុខ | គឹមសី | - លោក | មៀវ | សារ៉េត |
| - កញ្ញា | អ៊ូម | បូផាន់ណា | - លោក | គៀវ | ម៉េងគ័ង |
| - កញ្ញា | សួន | សុវណ្ណ | - លោក | វឿន | វណ្ណដេត |
| - លោក | សេង | សុវណ្ណរិទ្ធិ | | | |

facebook.com/moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia